# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

ឆ្នាំទី ៣៦ លេខ ៤ ខែ មេសា

ព. ស. ២៥០៦ គ. ស. ១៩៦៤

- ភ្នំពេញ -

## សេចក្តីថ្វាយព្រះពរសព្ទសាធុការ

## ក្នុងឱកាសចូលឆ្នាំថ្មី

សូមព្រះតេជៈគុណលើត្បូង

សូមព្រះរាជទាន ក្រាបបង្គំទូលថ្វាយសម្តេចព្រះមហាក្សត្រិយានី និង

សម្តេចព្រះឧបយុវរាជ ព្រះប្រមុខរដ្ឋ ក្រោមល្អងធូលីព្រះបាទ

សូមទ្រង់ជ្រាប ។

ក្នុងឱកាសចូលឆ្នាំថ្មី គឺឆ្នាំរោងឆស័ក ព.ស.២៥០៧ គ.ស.១៩៦៤នេះ

ទូលព្រះបង្គំជាខ្ញុំទាំងឡាយ ក្រុមពុទ្ធសាសនបណ្ឌិត្យ

សូមលំអុតលំឱនកាយវាចាចិត្ត ក្រាបបង្គំទូលថ្វាយ ដោយសេចក្តីគោរព ដ៏ជ្រាលជ្រៅនិងដ៏ស្មោះស្ម័គ្រ ចំពោះសម្តេចព្រះមហាក្សត្រិយានី ព្រះមាតាជាតិ ជាអម្ចាស់ជីវិតលើត្បូង និងសម្តេចព្រះឧបយុវរាជ ព្រះប្រមុខរដ្ឋកម្ពុជា នូវព្រះពរ សព្ទសាធុការមហាប្រសើរក្រៃលែង

សូមអានុភាពដ៏អស្ចារ្យនៃគុណព្រះរតនត្រៃ និងវត្ថុសក្តិសិទ្ធិក្នុងលោក មាន ទេព្តារក្សាព្រះមហាស្វេតច្ឆត្រជាដើម ជួយបីបាច់ថ្នាក់ថ្នមថែរក្សាការពារ សម្តេច ទាំងពីរព្រះអង្គជាទីស្នេហាស្មើជីវិត សូមព្រះអង្គទ្រង់ប្រកបដោយព្រះបរមសុខ សុភមង្គល សិរីសួស្តីគ្រប់យ៉ាងក្នុងព្រះសិរីរាជសម្បត្តិ មានព្រះជន្មាយុយឺនយូរ ជាងរយព្រះវស្សា ដើម្បីជាម្លប់ដ៏ត្រជាក់ដល់កូនចៅព្រះអង្គ សូមព្រះអង្គទ្រង់ឈ្នះ អស់មារសត្រូវគ្រប់ទិសទី សូមព្រះរាជបំណង មុតជួចអាវុធទិព្វ អាចពុះពារឧប- សគ្គគ្រប់បែបយ៉ាង ឲ្យវិនាសអន្តរាយខ្ចាត់ខ្ចាយ កុំបីមកពាំងបានឡើយ ។

ពុទ្ធសាសនបណ្ឌិត្យ

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយខាងសាសនា និងអក្សរសាស្ត្រ

ចេញរាល់ខែ ពីពុទ្ធសាសនបណ្ឌិត្យ

## បញ្ជីរឿង


*ផ្នែកសាសនា* — ទំព័រ

- ជយបរាជកថា រៀបរៀងដោយ ព្រះភិក្ខុ ពុទ - វ៉ន គង់វត្តកោះភ្នំពេញ . . . ៣៥១
- ព្រះអភិធម្មបិដក (គម្ពីរព្រះមហាបដ្ឋាន) លោក ប៊ូ - ប៊ូ តែងរៀបរៀង (ត) . . . ៣៦២
- អ្នកមានគុណ រៀបរៀងដោយលោក ហេង - សមអាន នៅសេនាធិការ ខេត្តកំពង់ចាម ៣៦៩
- ព្រះវិធូរជាតក (ត) . . . . . . . . . . . ៣៨១

*ផ្នែកអក្សរសាស្ត្រ*

- ចម្បាំងក្នុងលោក (វិចារណកថា) រៀបរៀងដោយ ប៊ូ - នរិន្ទ សង្កាត់លេខ ៥ ក្រុងភ្នំពេញ ៣៩២
- វចនានុក្រម សំស្ក្រឹត-ខ្មែរ ព្រះមហា ប៉ាង - ខាត់ រៀបរៀង (ត) . . . . ៣៩៩
- រឿងអាប៊ូលហ៊ាស៊្សរីស៍ លោក វ៉ាយ - ល្អុត ជំណាងរាស្ត្រ ប្រែរៀបរៀង (ត) . . ៤០១
- ល្បើកឃ្លាហ្លុងតែន លោក ផេង - ត្រីវ ប្រែពីភាសាបារាំង (ត) . . . . . ៤០៩
- រឿងសាមកុក អ្នកឧកញ៉ាវិបុលរាជសេនា នូ - កន ប្រែរៀបរៀង (ត) . . . ៤១៥
- ព្រះរាជនិពន្ធ រាមកេរ្តិ៍ ស្រាវជ្រាវ ដោយលោក ឌ - តាម (ត) . . . . ៤២៥
- រឿងព្រេងចិន (រឿងកូនអ្វដ្ឋ) លោក វ៉ាយ - ប៊ុក ប្រែពីភាសាបារាំង (ត) . . . ៤៣៤
- ទំនៀមទម្លាប់ខ្មែរ: រឿងព្រេងបឹងតេ . . . . . . . . ៤៣៩

*ផ្នែកកំណត់ទីនិងប្រវត្តិការណ៍*

- ប្រវត្តិនៃវត្តប្រាង្គ រៀបរៀង ដោយព្រះតេជព្រះគុណព្រះពោធិវង្ស ហួត-តាត (ត) . ៤៤[illegible]
- បុណ្យបញ្ចុះសីមា និងឆ្លងព្រះវិហារវត្តប្រាង្គ (តចប់) . . . . . . . ៤៥៤
- រឿងតាំងចៅអធិការ និងគ្រូសូត្រក្នុងវត្តនានា ក្នុងព្រះរាជអាណាចក្រ (ត) . . ៤៥៨
- សេចក្ដីផ្សេង ៗ . . . . . . . . . . . ៤៦៥

## ផ្នែកសាសនា

ពាក្យឃាត់មិនឲ្យ ធ្វើការអាក្រក់
ជាការណាមក ឲ្យធ្វើល្អទៅ
ឲ្យផុសខាត់ចិត្ត កុំឲ្យហ្មងសៅ
បីនេះលោកហៅ ពុទ្ធសាសនា

ប.ព.

# ជយបរាជយកថា

រៀបរៀងដោយភិក្ខុ ពុធ - សាវ៉ង គង់នៅវត្តកោះភ្នំពេញ

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស

សូមនមស្ការចំពោះ ព្រះសក្យមុនីអរហន្តសម្មាសម្ពុទ្ធព្រះអង្គនោះ ព្រមទាំងព្រះសទ្ធម្ម និងព្រះអរិយសង្ឃ ដោយសេចក្ដីគោរព ។

វេលានេះ អាត្មាភាព សូមសំដែងអំពី «ជយបរាជយគាថា» រៀបរាប់អំពីការឈ្នះ និងការចាញ់របស់មនុស្សលោក តាមន័យដែលមានមកក្នុងគម្ពីរធម្មបទ ខុទ្ទកនិកាយត្រង់សុខវគ្គ ដើម្បីជាគ្រឿងប្រដាប់សតិបញ្ញារបស់ពុទ្ធមាមកជនទូទៅ និងជាគ្រឿងពិចារណាក្នុងបញ្ហាជីវិតរបស់សត្វនិករ ឲ្យឃើញដោយប្រចក្សថា មានប្រយោជន៍ឬមិនមាន ទៀងទាត់ឬមិនទៀងទាត់ ដូចតទៅ ៖

កាលព្រះអនាវរណញ្ញាណ ទ្រង់គង់សម្រេចសម្រាន្តព្រះឥរិយាបថក្នុងវត្តជេតពន ជាអារាមរបស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី

ទ្រង់ប្រោសព្រះរាជទានធម៌ទេសនា ប្រារព្ធការបរាជ័យរបស់ព្រះបាទកោ.សលរាជ ។

សេចក្ដីដំណាលថា : ព្រះរាជាអង្គនោះ ទ្រង់ធ្វើពិធីយុទ្ធសាស្ត្រនឹងព្រះបាទអជាតសត្តុ ប៉ុន្តែទ្រង់បរាជ័យចាញ់ថ្វៃដៃព្រះបាទអជាតសត្តុអស់វារៈពីរដង លុះដល់លើកទី ៣ ព្រះអង្គទ្រង់មានតម្រិះក្នុងព្រះរាជចិន្តា "បើអាត្មាអញមិនអាចញ៉ាំងទារកដែលមានទឹកក្សីរក្នុងមាត់ឲ្យត្រឡប់ចាញ់វិញបានទេ តើការរស់នៅ មានប្រយោជន៍ដល់អាត្មាអញឬទេ ? ។

ព្រះអង្គក៏ទ្រង់អត់ព្រះស្ងោយ ផ្ទំជាទុក្ខក្រៀមក្រំ លើទែនទីសយនាក្រឡាព្រះបន្ទំ ។ ដំណឹងនោះ ក៏លេចឮរន្ទឺសុសសាយជ្រាបដល់ព្រះសម្មាសម្ពុទ្ធបរមគ្រូជាម្ចាស់ ទើបព្រះអង្គទ្រង់សម្ដែងព្រះគាថា ប្រារព្ធចំពោះភិក្ខុទាំងឡាយថា :

ជយំ វេរំ បសវតិ ទុក្ខំ សេតិ បរាជិតោ

ឧបសន្តោ សុខំ សេតិ ហិត្វា ជយបរាជយំ

ប្រែថា : បុគ្គលអ្នកឈ្នះរមែងបានទទួលនូវពៀរ បុគ្គលដែលត្រូវគេផ្ចាញ់ហើយ តែងនៅជាទុក្ខ (ឯព្រះខីណាស្រពដែលមានរាគាទិក្កិលេសស្ងប់រម្ងាប់ហើយ តែងនៅជាសុខ ព្រោះ (លោក) ជម្រុះចោលហើយនូវការឈ្នះនិងការចាញ់ ។

អធិប្បាយថា : បុគ្គលអ្នកមានជ័យជំនះ មានមេទ័ពជាដើមដែលឈ្នះកងទ័ពដទៃ ជាបច្ចាមិត្ត រមែងគង់បាននូវពៀរវេរា គឺមុខជានឹងមានថ្ងៃ ខែ ឆ្នាំ ណាមួយ ពួកបច្ចាមិត្តទាំងនោះនឹងឲ្យចាញ់វិញជាពុំខាន ។ អ្នកចាញ់គេគឺបុគ្គលដែលគេឲ្យបរាជ័យហើយ រមែងព្រួយបារម្ភជាទុក្ខគ្រប់ឥរិយាបថទាំងពួង ដោយមានការឈឺចាប់ក្ដៅក្រហល់ក្រហាយ អន្ទះអន្ទែងក្នុងចិត្ត ទើបគិតជានិច្ចថា : កាលណាហ្ន៎! អញនឹងអាចមើលឃើញខ្នងពួកបច្ចាមិត្ត គឺធ្វើពួកបច្ចាមិត្តឲ្យបរាជ័យ រត់ខ្ចាត់ខ្ចាយចេញពីមុខបាន ។

បុគ្គលដែលមានកាយ វាចា ចិត្តស្ងប់រម្ងាប់ សំដៅយកព្រះខីណាស្រព ដែលលោកមានរាគាទិក្កិលេសស្ងប់ហើយ ក្នុងសន្តាន លះបង់នូវការឈ្នះនិងការចាញ់បានហើយ គឺមិនមានសឹកសត្រូវអ្វីមួយដែលលោកត្រូវផ្ចាញ់ឬឧបសគ្គណាមួយដែលត្រូវផ្ចាញ់ ចំពោះលោកឡើយ ម៉្លោះហើយលោករមែងនៅជាសុខគ្រប់ឥរិយាបថទាំងពួង ទោះបីដើរ ឈរ អង្គុយដេកក្តីក៏ជាសុខឥតមានកង្វល់អ្វីឡើយ ។

ម្យ៉ាងទៀត ការធ្វើចម្បាំងនីមួយ ៗ មិនមែនមានសុទ្ធតែបរាជ័យ ឬក៏អបរាជ័យទាំងអស់នោះទេ រមែងមានស៊ីមានសង គឺជួនកាលក៏ខ្លួនមានជ័យជំនះលើពួកបច្ចាមិត្ត ជួនកាលក៏ត្រូវចាញ់វិញ សូម្បីតែអ្នកមានជ័យជំនះហើយ ក៏ពុំអាចរក្សាសិទ្ធិនោះ ឲ្យគង់វង្សស្ថិតស្ថេរជាស្ថាពរ

បានឡើយគង់មានឱកាសណាមួយ ពួកបច្ចាមិត្តទាំងនោះ នឹងមកផណ្តើមរឹបជាន់យកសិទ្ធិសេរីភាពនោះបានវិញជាពិតប្រាកដ ។

មានតែព្រះសម្ពុទ្ធបរមគ្រូជាម្ចាស់ទេ ដែលទ្រង់ឆ្ងាយចាកសឹកសត្រូវ ទ្រង់កំចាត់បង់ចោលស្រឡះ នូវសឹកសត្រូវពោលគឺកិលេស ដោយអំណាចអរិយមគ្គញាណ ឥតមានសេសសល់នៅក្នុងសរីរយន្តរបស់ព្រះអង្គ ដែលទ្រង់ពុំដែលឈ្នះអស់ជាតិជាអនេក ទ្រង់ឈ្នះហើយលែងត្រឡប់ចាញ់វិញ ទ្រង់គង់នៅជាសុខ ឥតមានកង្វល់អ្វី ដូចជាទេពតា ដែលស្ថិតនៅក្នុងព្រហ្មលោកជាន់អាភស្សរៈ សមដូចព្រះពុទ្ធដីកា ទ្រង់ត្រាស់ចំពោះមារធិរាជមានចិត្តបាប នៅក្នុងគម្ពីរធម្មបទខុទ្ទកនិកាយថា :

សុសុខំ វត ជីវាម យេសន្នោ នត្ថិ កិញ្ចនំ
បីតិភក្ខា ភវិស្សាម យថា ទេវា អាភស្សរា ។

ប្រែថា : ការមិនមានកង្វល់ ដល់ពួកយើងឯណា ពួកយើងនោះទឹបរស់នៅជាសុខស្រួលក្រៃពេក ពួកយើងនោះ នឹងជាអ្នកមានបីតិជាអាហារ ដូចជាពួកទេវតាដែលស្ថិតនៅក្នុងព្រហ្មលោកជាន់អាភស្សរៈ ។

សេចក្តីថា : កិលេសជាតិ ដែលដឹកនាំចិត្តគំនិតរបស់សព្វសត្វឲ្យរវេះរវាម ឲ្យមានកង្វល់ ហៅថា កិញ្ចនៈមាន ៣ យ៉ាងគឺ :

១– រាគកិញ្ចនំ កង្វល់គឺរាគៈ

២– ទោសកិញ្ចនំ កង្វល់គឺទោសៈ

៣- មោហាគតិញាណ  កន្លល់គឺមោហៈ

ទី ១- សេចក្ដីត្រេកត្រអាល រីករាយ ជាប់ចិត្ត ក្នុងវត្ថុកាម ផ្សេងៗ មានរូប សម្លេង ក្លិន រស សម្ផស្ស ដែលជាទីពេញចិត្ត អាច បណ្ដាលឲ្យមនុស្សស្រេកត្រូវល់ខ្វាយ អន្ទះអន្ទែងវវះវេម នេះលោកហៅថា រាគគតិញាណៈ កន្លល់គឺរាគៈ ។

បុគ្គលដែលត្រូវរាគៈធ្វើឲ្យជាប់ចិត្តហើយ ដែលត្រូវរាគៈគ្របសង្កត់ហើយ មានចិត្តត្រូវរាគៈញាំញីបានហើយ តែងគិតដើម្បីបៀតបៀនខ្លួនខ្លះ ដើម្បីបៀតបៀនអ្នកដទៃខ្លះ ដើម្បីបៀតបៀនខ្លួនឯង នឹងអ្នកដទៃទាំងពីរខ្លះ ។ បុគ្គលដែលត្រូវរាគៈធ្វើឲ្យជាប់ចិត្តហើយត្រូវរាគៈគ្របសង្កត់ហើយ មានចិត្តត្រូវរាគញាំញីបានហើយ យ៉ាងនេះរមែងហ៊ាន ប្រព្រឹត្តធ្វើនូវអំពើទុច្ចរិតដោយកាយ វាចា ចិត្ត មានសម្លាប់សត្វ លួច លាក់ឆក់ដណ្ដើម ទ្រព្យសម្បត្តិអ្នកដទៃ ហ៊ានប្រព្រឹត្តអនាចារចំពោះគូប្រពន្ធអ្នកដទៃ ហ៊ានបោកបញ្ឆោតប្រវញ្ចយកទ្រព្យសម្បត្តិអ្នកដទៃ ។

រាគៈនេះមានទោសក៏ច្រើន លះបង់ក៏បានដោយកម្រ ដោយយឺតយូរទៀតផង ។

ទី ២- សេចក្ដីប្រទូស្តចំពោះសត្វនិងសង្ខារ ដែលកើតអំពីបដិឃៈ ការក្រេវក្រោធ ការគក់អន់ចិត្ត ដែលដេកត្រាំសម្ងំនៅក្នុងសន្ដានចិត្តក្ដី បណ្ដាលចេញមកខាងក្រៅក្ដី មានអាការឃោរឃៅ នេះលោកហៅថា

ទោសកិញ្ចនៈ កង្វល់គឺទោសៈ ។

សត្វលោក កាលបើត្រូវទោសៈប្រទូស្តហើយ រមែងហ៊ានប្រទូស្ត ចំពោះបុព្វការីបុគ្គល មានមាតាបិតាបង្កើតរបស់ខ្លួនឯងក៏មាន ចំពោះគ្រូបាធ្យាយរបស់ខ្លួនក៏មាន ចំពោះញាតិ មិត្រ សាលោហិត មានបង ប្អូនប្រុសស្រីជាដើមក៏មាន ។ ដូចនិទានភិក្ខុទេវទត្តដែលមាននៅក្នុងគម្ពីរធម្មបទខុទ្ទកនិកាយ ត្រង់យមកវគ្គ សូមសំដែងដោយសង្ខេប ដើម្បីជាកស្តុតាងដូចតទៅនេះ :

មានសេចក្តីដំណាលថា : ភិក្ខុទេវទត្ត ត្រូវជាអនុជ ជីដូនមួយនឹងព្រះសក្យមុនីគោតមបរមសម្ពុទ្ធ ខាងព្រះវរមាតាព្រះអង្គ ។ ភិក្ខុអង្គនេះ កាលពីដើមឡើយ ជាអ្នកមានបសន្នចិត្តជ្រះថ្លាចំពោះលទ្ធិនៃព្រះពុទ្ធសាសនា បានស្ម័គ្រចិត្តចូលបួសជាមួយនឹងក្សត្រ ៥ អង្គ គឺ : ភទ្ទិយសក្យរាជ១ អនុរុទ្ធ ១ អានន្ទ១ ភគុ ១ កិម្ពិល១ លុះបួសហើយមិនយូរប៉ុន្មាន ក៏កើតទោសចិត្ត តាំងចិត្តជាបច្ចាមិត្ត ប្រឆាំងចំពោះព្រះអង្គដែលជាសាស្ត្រាចារ្យរបស់ខ្លួន ហើយខំប្រឹងប្រែងស្វែងរកកលោបាយផ្សេង ៗ ដើម្បីធ្វើឃាតព្រះអង្គគឺ :

លើកទី ១ – ទៅល្បួងលួងលោម ញុះញង់ បោកបញ្ឆោតព្រះរាជកុមារព្រះនាម អជាតសត្តុ ត្រូវជាបុត្រព្រះបាទពិម្ពិសារ ឲ្យទ្រង់ជឿដោយភ័ន្តច្រឡំថា : បើរាជកុមារត្រូវការសោយរាជសម្បត្តិ ត្រូវធ្វើ

គត់ព្រះវេចេតារបស់ខ្លួនចុះ មុខជានឹងបានសោយរាជ្យជាប្រាកដ ចំណែក យើងវិញ គឺបងពិឃាតព្រះមានព្រះភាគដែរ ដើម្បីឲ្យបានត្រាស់ជាព្រះពុទ្ធ ។

លើកទី ២– គឺបញ្ជាឲ្យពួកខ្មាន់ធ្នូ ទៅប្រហារព្រះអង្គទៀត

លើកទី ៣ – គឺឡើងលើកំពូលភ្នំគិជ្ឈកូដ ដោយខ្លួនឯង ហើយគ្រវែងដុំថ្ម ប្រមៀលចុះពីលើភ្នំមក ប៉ងឲ្យត្រូវខ្ទេចខ្ទីរូបកាយព្រះអង្គតែម្ដង តែពុំបានសំរេចដូចបំណង ។

លុះលើកទី ៤ - គឺបង្គាប់បញ្ជាហ្មដំរី ឲ្យលែងដំរីនាឡាគិរីដែលជាសត្វកាចសាហាវជាទីបំផុត ឲ្យទៅព្រួចព្រះអង្គទៀត តែអំពើអកុសលបាបលាមកទាំងប៉ុន្មាននោះ ពុំបានសម្រេចដូចបំណងឡើយ ។ ទេវទត្តនោះ ខាងក្រោយមក ក៏ក្លាយខ្លួនជាអនាថបុគ្គល សាបសូន្យអស់រិទ្ធិអំណាច លុះដល់ទីបំផុត ក៏ត្រូវព្រះធរណីស្រូបខ្លួនយកបាត់ទៅ ។

រឿងនេះបានសេចក្ដីថា: ទោសៈ តែងញុំាងសេចក្ដីវិនាសឲ្យកើតឡើងដល់ខ្លួនឯង ញុំាងអ្នកដទៃដែលសេគ្រស្នាគមជាមួយឲ្យទទួលទុក្ខព្រួយឲ្យវិនាសហិនហោច ដូចខ្លួនឯងផង ។ ទោសៈ រមែងបំភ័ន្ត ចិត្តគំនិត របស់ជនពាល មិនឲ្យស្គាល់ខូវកយន្តកាយដែលកើតឡើងក្នុងសន្ដានរបស់ខ្លួននឹងបំរុងកើតឡើងចំពោះខ្លួន ។ បុគ្គលដែលត្រូវទោសៈប្រទូស្តហើយ រមែងឃ្លាតចាកសុចរិតធម៌ រីករាលតែក្នុងអសប្បុរសធម៌ នឹងជា

អ្នកបង្កហេតុនៃកុប្បកម្ម ឲ្យកើតមានឡើងជានិច្ចនិរន្តរ៍ ថែមទាំងមិនស្គាល់នូវប្រយោជន៍របស់ខ្លួនជាដើម បុគ្គលដែលត្រូវទោសៈគ្របសង្កត់ហើយ រមែងមិនយល់នូវធម៌ សូម្បីត្រឹមតែកម្មបថ ១០ បុគ្គល កាលបើត្រូវទោសៈគ្របសង្កត់ហើយ ការងឹកងងល់ច្រួលច្របំ នឹងកើតមានឡើងដោយភ្លៀវភ្លា រមែងឲ្យទោសទៅជាខ្វល់វវះវាម ឥតអៀនខ្មាស់អ្នកដទៃ អាចបញ្ចេញអាកប្បកិរិយាដោយឥតលាក់លៀម ៗ ទោសកិញ្ចនៈនេះ មានទោសច្រើន ឃើញយ៉ាងប្រត្យក្សក្នុងបច្ចុប្បន្ន ប៉ុន្តែជាកិលេសជាតដែលបុគ្គលងាយនឹងលះបង់បានដោយឆាប់រហ័សដែរទេ ៗ

៣– ការវង្វេងភ័ន្តច្រឡំ ការងឹកងងល់មិនយល់សេចក្ដីពិត គឺមិនស្គាល់អរិយសច្ចតាំង ៤ មានទុក្ខសច្ចជាដើម ឬវង្វេងទៅក្នុងហេតុការណ៍ណាមួយ ដែលមិនស្មានថាខ្លួនជាអ្នកវង្វេង នេះលោកហៅថាមោហកិញ្ចនៈ កង្វល់គឺមោហៈ ៗ

មោហកិញ្ចនៈនេះ ជាកិលេសជាត សម្រាប់ដឹកនាំសត្វឲ្យលិចលង់នៅក្នុងសង្សារវដ្ដ ឲ្យទទួលនូវទុក្ខទោស ពៀរ វេរ បណ្ដាលឲ្យគានតឹងទង្គិះខ្សឹកខ្សួល អណ្ដែតអណ្ដក់នៅក្នុងលោកពុំបានឲ្យសត្វលោកឆ្លងនូវទីបំផុតនៃសេចក្ដីទុក្ខបានដោយងាយឡើយ ៗ បុគ្គលដែលត្រូវមោហៈ ជះជាន់ញាំញីបានហើយ ហ៊ានប្រទូស្តចំពោះមាតាបិតាក៏មានចំពោះព្រះចេតិយ៍ឬព្រះពោធិព្រឹក្សផងក៏មាន ចំពោះបព្វជិតក៏មាន ហើយ

តែងបាននូវពាក្យនិន្ទាក្នុងទីផ្សេង ៗ ដែលខ្លួនទៅហើយ ៗ មោហៈ កិច្ចានៈនេះ មានទោសក៏ច្រើន ថែមទាំងលះបង់ក៏បានដោយកម្រទៀតផង ។

ឧបក្កិលេសដទៃទៀត ដែលជាមេរោគ ច្រើនដេកត្រាំនៅក្នុងសន្តានចិត្ត តែងធ្វើចិត្តសត្វលោកឲ្យសៅហ្មង មិនឲ្យមានពន្លឺរស្មី ក៏ស្អាតរុងរឿងទៅបានឡើយ ។ ឧបក្កិលេសនោះមាន ១៦ យ៉ាងគឺ :

១– អភិជ្ឈាវិសមលោភៈ សេចក្តីលោភមិនស្មើ គឺ អភិជ្ឈា

២– ព្យាបាទៈ ចង់គំនុំគុំគួន បំរុងនឹងធ្វើគេឲ្យវិនាស

៣– កោធៈ ក្រោធ ខឹងហើយបញ្ចេញកាយ វាចា ដេរវាយ ជាដើម

៤– ឧបនាហៈ ខ្ចប់គំហឹងទុក

៥– មក្ខៈ លុបគុណ គឺបំភ្លេចគុណគេ

៦– បឡាសៈ ការវាយឫកស្មើ ឬប្រណាំងប្រជែងវាសនា

៧– ឥស្សាៈ សេចក្តីឫស្យា ច្រណែនឈ្នានិស

៨– មច្ឆរិយ សេចក្តីកំណាញ់ស្វិតស្វាញ

៩– មាយា ការប្រព្រឹត្តិ លាក់លៀមពុតត្បុត

១០– សាឋេយ្យៈ អំនួត ឬការវាយអែប

១១- ថម្ភៈ ការបេះរឹងត្អឹង

១២- សារម្ភៈ ការប្រណាំងប្រជែង

១៣- មានះ ការប្រកាន់ខ្លួន

១៤= អតិមានះ ការប្រកាន់ខ្លួនហួសប្រមាណ គឺមើលងាយគេ

១៥= មទះ ការស្រវឹង

១៦= បមាទះ ការធ្វេសប្រហែស

ឧបក្កិលេសទាំង ១៦ នេះ សុទ្ធតែជាឫសគល់នៃអកុសលធម៌ទាំងអស់ សម្រាប់ធ្វើសន្តានចិត្តរបស់សត្តនិករ ដែលកើតមកក្នុងពិភពលោកទាំងមូល ឲ្យកករល្អក់ ឲ្យសៅហ្មង ឲ្យមានមុខឈមទៅរកបាបអកុសល ហើយដឹកនាំសត្វទាំងឡាយ ឲ្យកប់ប្រសប់ជួបប្រទះតែនឹងសេចក្ដីទុក្ខគ្រប់យ៉ាង ទាំងក្នុងបច្ចុប្បន្ន ទាំងក្នុងបរលោក ។

ដូច្នេះ អស់លោក អ្នកសប្បុរសជាពុទ្ធបរិស័ទទាំងឡាយដែលប្រាថ្នាចង់បានសុខ និងវឌ្ឍនធម៌ គប្បីពិនិត្យពិចារណាក្នុងចិត្តរបស់ខ្លួន បើឃើញឧបក្កិលេសណាមួយ ជាប់ជំពាក់ជាមនៅក្នុងខន្ធសន្តានរបស់ខ្លួន ហើយ គួរខំប្រឹងប្រែងកំចាត់បោលចេញ ដើម្បីនឹងធ្វើចិត្តឲ្យបានបរិសុទ្ធស្អាត ឬមួយសេពគប់កប់រកពួកជនជាបណ្ឌិតអត្តកោវិទ ដែលលោកមានគំនិតដ៏ប្រសើរ មានអជ្ឈាស្រ័យដ៏បរិសុទ្ធ ព្រមទាំងមានសន្តានចិត្តបេះសន្តោស មិនស្វែងរកទោសគ្នីគ្នាជាមិត្រភក្តិ នេះបីបាច់ថែរក្សា

សេចក្ដីសុខទុក្ខរវាងញាតិមិត្រ មិនឲ្យបែកបាក់សាមគ្គី ព្រោះពួកជនជាបណ្ឌិតនោះ អាចដឹកនាំបង្ហាញផ្លូវ អាក្រក់ ល្អ បុណ្យបាប គុណទោស ចំរើន វិនាស ដល់ពួកជនរួបរួមជាមួយ ឲ្យទទួលការបដិវត្តន៍ គឺផ្លាស់ប្ដូរឋានៈពីមូឡ្ហភាព ទៅជាបណ្ឌិតភាព ពីហីនភាពទៅជាឧត្ដមភាព ពីទុក្ខភាព ទៅជាសុខភាព ទាំងក្នុងលោកនេះ និងលោកខាងមុខ ជាភិយ្យោភាពតទៅ ។

ការសំដែង «ជយបរាជយគាថា» រៀបរាប់អំពីការឈ្នះនិងការចាញ់របស់មនុស្សលោក ចប់ដោយសង្ខេបប៉ុណ្ណេះ ។

# ព្រះអភិធម្មបិដក

## (គម្ពីរព្រះមហាបដ្ឋាន)

លោក ប៊ូ-ប៉ូ រៀបរៀង

គមក

---

ឯបុគ្គលដែលមិនបានធ្វើនូវការកុសល ប្រៀបដូចបុគ្គលដើរផ្លូវឆ្ងាយគ្មានស្បៀង អទ្ធានមគ្គបដិបន្នោ នាម ឈ្មោះថាបុគ្គលធ្វើដំណើរដើរផ្លូវឆ្ងាយ ហើយគ្មានស្បៀងនោះ តែងមិនបានទៅដល់ទីកន្លែងដែលខ្លួនប្រាថ្នានឹងទៅ យថាបិណាម សេចក្តីនេះមានឧបមាដូចម្តេច ។ បុគ្គលនឹងធ្វើឲ្យផុតចាកសង្សារវដ្តបាន បើគ្មានស្បៀងគឺកុសលទេ ក៏មិនអាចនឹងធ្វើឲ្យផុតពីសង្សារវដ្តបានឡើយ មានឧបមេយ្យដូច្នោះ ។

ហេតុនោះឯង សាធុជនប្រាថ្នានឹងយាងខ្លួនឲ្យផុតពីសង្សារវដ្ត គប្បីរកស្បៀងគឺទានទុកសម្រាប់បរិភោគទៅក្នុងផ្លូវឆ្ងាយ នឹងចង់ឲ្យផុតពីសេចក្តីទាល់ក្រ នឹងចង់បានវត្ថុអ្វី ក៏បានវត្ថុនោះដូចបំណង ។ បើរកស្បៀងគឺសីល ដើម្បីនឹងដើរផ្លូវទៅបានចៀសផុតពីចម្រូងពីបន្លា គឺដើរទៅបានសុខស្រួល ។ បើរកស្បៀងគឺព្រះធម្មទេសនា កាលដើរទៅតាមផ្លូវមិនទាន់ដល់និព្វានទេ នឹងមិនទៅកាន់អបាយភូមិ ។ បើរកស្បៀងគឺបុណ្យ នឹងបានប្រាសចាករបស់លាមកទាំងឡាយ នឹងដើរទៅបានសុខសប្បាយដរាបដល់និព្វាន ។ បើរកស្បៀងគឺសទ្ធាការជឿក្នុងព្រះពុទ្ធ

គុណព្រះធម្មគុណនឹងព្រះសង្ឃគុណ ជឿមាំហេតុផលផលសីលទានការ
កុសលមិនគិតត្រឡប់ថយក្រោយ កាលមិនថយក្រោយហើយ ក៏ដល់
ត្រើយគឺព្រះនិព្វានបាន ៗ ឯផ្លូវព្រះនិព្វាននោះឆ្ងាយក្រៃលែង ឆ្ងាយជាង
ផ្លូវគន្តារទាំងពួង កម្រនឹងឆ្លងរំលងឲ្យផុតទៅបាន ទាល់តែមានស្បៀង
គឺកុសល ទើបនឹងឆ្លងទៅបាន ៗ

បុគ្គលខ្លះមានកុសលច្រើនក៏ពិតមែនហើយ ប៉ុន្តែមិនបានប្រាថ្នានូវ
ព្រះនិព្វាន ក៏មិនបានសម្រេចព្រះនិព្វានដែរ ព្រោះខ្លួនមានគំនិតយល់
ឃើញខុស គឺគិតឃើញថាព្រះនិព្វាននោះរលត់សូន្យទៅហើយ ពុំមាន
អ្នកណាម្នាក់ដឹងឃើញផងទេ គ្រាន់តែបានឮថាជាបរមសុខប៉ុណ្ណោះ លុះ
គិតឃើញដូច្នោះហើយ ក៏មិនចង់ទៅព្រះនិព្វាន កាលបើមិនចង់ទៅព្រះ
និព្វានហើយ ក៏មិនបានដល់ទៅព្រះនិព្វានដែរ ប្រៀបដូចអ្នកមានទ្រព្យ
សម្បត្តិច្រើនក៏មែនហើយ ប៉ុន្តែមិនចង់បរិភោគរបស់អ្វី ៗ សោះ ក៏មិន
បានសម្រេចដូចសេចក្តីប្រាថ្នាដែរ ៗ ឯបុគ្គលធ្វើការកុសលហើយមិន
ប្រាថ្នានូវនិព្វានសម្បត្តិទេ ប្រាថ្នាតែសុខក្នុងមនុស្សនឹងសួគ៌ប៉ុណ្ណោះបុគ្គល
នោះឈ្មោះថាប្រាថ្នាខុស ៗ អ្នកធ្វើកុសលហើយ បើតាំងចិត្តប្រាថ្នា
របស់អ្វី ៗ ក៏គង់តែបានសម្រេចរបស់នោះៗដូចប្រាថ្នា ប៉ុន្តែបុគ្គលដែល
ប្រាថ្នាតែមនុស្សសម្បត្តិនឹងសួគ៌សម្បត្តិ មិនប្រាថ្នាព្រះនិព្វានទេនោះសេចក្តី
សុខក្នុងមនុស្សក៏នឹងបាន សេចក្តីសុខក្នុងឋានសួគ៌ក៏នឹងបាន លុះអស់

ផលបុណ្យហើយជាបច្ច័យនឹងឲ្យកើតកុនត្រកូលមិច្ឆាទិដ្ឋិ ព្រោះខ្លួនយល់ឃើញថាព្រះនិព្វានគ្មានសេចក្តីសុខដូចមនុស្សនិងសួគ៌ ។ ហេតុនោះ អ្នកណាធ្វើកុសលហើយមិនប្រាថ្នាព្រះនិព្វាន អ្នកនោះឈ្មោះថាមានចិត្តប្រាថ្នាខុស ។ អ្នកណាធ្វើកុសលហើយប្រាថ្នាព្រះនិព្វាន អ្នកនោះឈ្មោះថាប្រាថ្នាត្រូវ ព្រោះធ្វើខ្លួនឲ្យផុតចាកកពាវដ្តសង្សារ កាលបើមិនទាន់ដល់ព្រះនិព្វានទេ ក៏នឹងបានទទួលសម្បត្តិមនុស្សនិងសួគ៌ ។ អ្នកធ្វើកុសលហើយ ប្រាថ្នាតែព្រះនិព្វានមួយមុខប៉ុណ្ណោះ មិនប្រាថ្នាសម្បត្តិមនុស្សនិងសួគ៌ផងទេ ក៏គង់តែបានសម្បត្តិមនុស្សនិងសួគ៌ទាំងពីរនោះពុំខានដែរ ព្រោះថាសម្បត្តិមនុស្សនិងសួគ៌ទាំងពីរប្រការនេះ នៅខាងដើមផ្លូវដែលនឹងទៅកាន់ព្រះនិព្វាន ។ អ្នកប្រាជ្ញមិនគួរប្រមាទថាកុសលតែបន្តិចបន្តួចស្តួចស្តើងនេះ មិនដឹងជាកាលណានឹងបានទៅដល់ព្រះនិព្វានទេ ស្រៀបដូចព្រះនិព្វាននោះនៅឆ្ងាយក្រៃលែង មិនងាយនឹងបានសម្រេចដូចប្រាថ្នាទេ ។ អ្នកខ្លះគិតឃើញថា បើទុកជាបានដល់ព្រះនិព្វានក៏យូរយារណាស់ ទើយ៉ាងតិចបំផុតក៏កប់សែនកល្បដែរ យល់ឃើញយ៉ាងនេះហើយក៏មិនប្រាថ្នាព្រះនិព្វាន ។ អ្នកធ្វើកុសលហើយមិនប្រាថ្នាព្រះនិព្វាន ប្រាថ្នាតែសម្បត្តិមនុស្ស និងសួគ៌ប៉ុណ្ណោះ ឈ្មោះថាអ្នកប្រាថ្នាខុស ។

អ្នកធ្វើកុសលហើយ តាំងចិត្តប្រាថ្នាព្រះនិព្វាន បើទុកជាមិនទាន់ដល់ព្រះនិព្វានភ្លាម ក៏គង់តែបានខិតទៅជិតព្រះនិព្វានរាល់ជាតិដែរ មាន

ព្រះបាលីក្នុងសង្ខារុបបត្តិសូត្រថា បុគ្គលធ្វើកុសលតែបន្តិចបន្តួច គឺបបរមួយបោយ បាយមួយវែកប៉ុណ្ណោះ ប៉ុន្តែតាំងចិត្តប្រាថ្នាថា ទានរបស់ខ្ញុំនេះ ចូរជាបច្ច័យនាំមកនូវអាសវក្ខ័យ គឺព្រះនិព្វាន ជាទីអស់នៃអាសវៈមកឲ្យដល់ខ្ញុំ គឺថាខ្ញុំសូមឲ្យបានដល់ព្រះនិព្វានជាទីអស់អាសវៈ បើប្រាថ្នាដូច្នេះហើយ ក៏អាចឲ្យសម្រេចសេចក្តីប្រាថ្នាបាន ឈ្មោះថាជាអ្នកប្រាថ្នាត្រូវ ព្រោះយោងខ្លួនឲ្យផុតចាកសង្សារវដ្ត ប្រៀបដូចអ្នកមានទ្រព្យតិចតួចប្រមាណមួយកាកទិក បើខំស្រាហ៍សន្សំទុក ក៏បានមានច្រើនស្តុកស្តម្ភ ទៅជាសេដ្ឋី ដូចមាណពម្នាក់ជាអន្តេវាសិកនៃចុល្លកសេដ្ឋី មុនដំបូងមានតែសត្វកណ្តុរមួយ ថ្លៃមួយកាកទិកប៉ុណ្ណោះ ប៉ុន្តែចិត្តមិនប្រមាទ ចេះតែខំសន្សំប្រមូលទ្រព្យបានច្រើនឡើង ៗ រហូតដល់បានទៅជាសេដ្ឋី ។

ឯអ្នកដែលធ្វើកងការកុសលកសិ ហើយតាំងសេចក្តីប្រាថ្នាក៏ដូចគ្នាដែរ ដើមដំបូងធ្វើតែបន្តិចបន្តួច លុះសន្សំញយ ៗ ទៅ ក៏ផ្គុំគ្នាទៅជាច្រើន កាលគ្រប់ចំនួនតាមអរិយប្រពៃណីមូលបណីធិ របស់ព្រះអរិយៈហើយ ក៏នឹងបានសម្រេចដូចចិត្តប្រាថ្នា ៗ ហេតុនោះ បានជាលោកសំដែងថា បុគ្គលអ្នកមានបញ្ញាកុំគប្បីប្រមាទនូវការកុសលឡើយ ។ អង្គសម្តេចព្រះបរមទសពលប្រទានព្រះសទ្ធម្មទេសនាទុកថា ៖

មាវមញ្ញេថ បុញ្ញស្ស ន មត្តំ អាគមិស្សតិ ប៉ុណ្ណោះ ជាដើម សេចក្តីថា បុគ្គលធ្វើការកុសលហើយ កុំគប្បីប្រមាទនូវការ

កុសលដែលបានធ្វើរួចហើយនោះថា កុសលមានប្រមាណប៉ុណ្ណោះ កាលណាទើបបានផល កាលណាទើបបានសោយនូវផលនៃកុសលមានប្រមាណប៉ុណ្ណោះ កុំគប្បីប្រមាទដូច្នេះឡើយ គប្បីតែញុំាងចិត្តឲ្យត្រេកអរថា ការកុសលដែលអញបានធ្វើរួចហើយនេះ កម្របុគ្គលនឹងធ្វើបាន អ្នកខ្លះបើទុកជាមានទ្រព្យសម្បត្តិច្រើនដល់ប៉ុន្មាន ៗ ក៏មិនអាចនឹងធ្វើកើតដែរ ថោកំ ថោកំបិ អាចិណំ លុះគិតឃើញដូច្នោះហើយក៏ចេះតែខំសន្សំរឿយ ៗ ទៅ តិច ៗ ផ្សំគ្នាទៅជាច្រើន ក៏នឹងពេញទៅដោយកុសលកម្ម ដូចក្អមទឹកដែលបុគ្គលបើកមាត់ចំហ ហើយដំកល់ទុកត្រង់កន្លែងទឹកភ្លៀងធ្លាក់ ទឹកភ្លៀងធ្លាក់ចុះក្នុងក្អមម្តងមួយដំណក់ ញយ ៗ ទៅ ក្អមក៏នឹងពេញពោរដោយទឹកភ្លៀង ៗ សេចក្តីនេះមានឧបមាដូចម្តេច បុគ្គលមិនប្រមាទក្នុងការកុសល ឧស្សាហ៍ធ្វើកុសលរឿយ ៗ ក៏នឹងបានពេញពោរទៅដោយកងការកុសលផលបុណ្យ កុសលនោះក៏នឹងទំនុកបម្រុងឲ្យបានទៅជិតព្រះនិព្វានកាលគ្រា ៗ

ប្រការមួយទៀត បណ្ឌិតជាតិអ្នកមានប្រាជ្ញាដ៏ល្អ ខាងអកុសលសោត ក៏កុំប្រមាទដូចគ្នា ៗ ឯអកុសលជាអំពើបាបអាក្រក់លាមកនោះ បើបុគ្គលណាធ្វើ ក៏អាចដឹកនាំបុគ្គលនោះទៅកាន់ចតុរាបាយ ៗ កុសលអំពើល្អប្រពៃ បើបុគ្គលណាធ្វើ ក៏នឹងដឹកនាំបុគ្គលនោះទៅកាន់សុគតិភពជាប្រាកដ ដែលជាឥតផលនោះពុំមែនទេ ៗ ខាងកុសលនេះមាន

ផលនាំឲ្យបានសុខ ៗ ខាងអកុសល មានផលនាំឲ្យបានទុក្ខ គ្រាន់តែ ថ្លៃកត្តាយ៉ាងនេះ ៗ ហេតុនោះ បុគ្គលអ្នកមានបញ្ញាដ៏ល្អ ចូរចៀសវាង ឲ្យផុតចាកអកុសល ស្វែងរកតែកុសលចុះ ប្រៀបដូចបុគ្គលដើរជាន់ អក់ហើយចំផុសលាងអក់នោះ ក៏គង់តែអស់អក់ពីជើងមិនខាន ៗ បើ បុគ្គលធ្វើកុសលអ្វី ៗ ត្រូវតែប្រាថ្នានូវព្រះនិព្វាន ៗ

ម្យ៉ាងទៀត បុគ្គលត្រូវធ្វើព្រះពុទ្ធគុណជាអារម្មណ៍ ព្រោះសម្ដេច ព្រះមានព្រះភាគទ្រង់ត្រាស់សរសើរថាមានផលនឹងកប់មិនអស់ឡើយ ៗ អគ្គមសោ ឧម្មារបុប្ផមត្តំ ដោយហោចទៅ បុគ្គលគ្រាន់តែបូជា ព្រះពុទ្ធដោយផ្កានោនផ្កាត្រកៀតមួយប៉ុណ្ណោះ កុសលកសិនឹងកប់មិន អស់ ៗ បើបុគ្គលឃើញអ្នកដទៃធ្វើកុសលអ្វី ៗ ត្រូវជួយរីករាយអនុមោទ- នា ៗ បើបុគ្គលធ្វើកុសលអ្វី ៗ ត្រូវផ្សាយផលបុណ្យឲ្យអ្នកដទៃផង ត្បិត ការផ្សាយផលបុណ្យឲ្យអ្នកដទៃនោះ រាប់ចូលក្នុងចិត្តមេត្តា ៗ បើបុគ្គល ឃើញអ្នកដទៃធ្វើកុសលហើយមានចិត្តរីករាយផង ជាហេតុនឹងញ៉ាំងខ្លួន ឲ្យបានទៅកើតនៅឋានសួគ៌ ដូចជាជុណ្ហៈអាមាត្យដែលមានចិត្តជ្រះថ្លា ក្នុងអសទិសទាន នៃព្រះបាទបសេនទិកោសល ៗ ចំណែកបុគ្គលកំ- ណាញ់ក្នុងទានរបស់អ្នកដទៃវិញ បើឃើញគេធ្វើទានក៏មានចិត្តប្រស្យាច្រ- ណែន ជាហេតុនឹងឲ្យទៅកើតក្នុងនរក ដូចជាកាឡៈអាមាត្យដែលកំណាញ់ ក្នុងអសទិសទានមានចិត្តប្រស្យា ៗ កម្មគឺកុសលនឹងអកុសលនេះ ជា

ហេតុជាបច្ច័យនឹងឲ្យសត្វអ្នកធ្វើបានសោយសុខនឹងទុក្ខតាំងពីរប្រការ ។

ហេតុនោះ សម្ដេចព្រះបរមសាស្ដាចារ្យទើបទ្រង់ប្រោសប្រទានព្រះសទ្ធម្មទេសនាថា កម្មនេះជាបច្ច័យរាប់ចូលក្នុងបច្ច័យ ២៤ ប្រការដូច្នេះ ៗ

កម្មបច្ច័យ ចប់តែប៉ុណ្ណោះ ៗ

(នៅមានត)

---

## ផាកកំផ្លែង (ពេលរៀនវេយ្យាករណ៍)

អ្នកគ្រូសួរសិស្សថា: ស្រៈនិស្ស័យមានប៉ុន្មានយ៉ាង? កូនសិស្សភាគច្រើនលើកដៃហើយថា: អ្នកគ្រូ ខ្ញុំ! អ្នកគ្រូ ខ្ញុំ! អ្នកគ្រូ ខ្ញុំ! រញ៉ . . . . ។

អ្នកគ្រូញញឹម ៗ ដោយនឹកថាកូនសិស្សអញភាគច្រើនចេះមេរៀនគ្រាន់បើ ។ ទើបគាត់ចង្អុលទៅអាម្នាក់អង្គុយចុងតុក្បែរជញ្ជាំង ។ សិស្សនោះក្រោកឈរហើយឆ្លើយថា: ស្រៈនិស្ស័យមានពីរយ៉ាងគឺស្រៈពេញតួ និងស្រៈព្យញ្ជនៈ ។ សិស្សឯទៀតសំឡឹងមុខៗអ្នកឆ្លើយ អ្នកគ្រូយើងឡើងមុខក្រហម ហើយគំហកឲ្យថា: អាចោលម្សៀត អង្គុយចុះ!

មានសិស្សម្នាក់ក្លាហានអង្គុយតុកណ្ដាល ក្រោកឈរឡើង ហើយឆ្លើយថា: ស្រៈនិស្ស័យមានពីរយ៉ាង គឺស្រៈឃោសៈ និងស្រៈអឃោសៈ ។

អ្នកគ្រូប្រែទឹកមុខឡើងស្រស់វិញ ព្រោះត្រូវត្រង់ចំណុចខ្លួន ហើយពោលថា: អើត្រូវហើយ

ខណៈនោះ ស្រាប់តែមានសិស្សម្នាក់អង្គុយក្រោយបង្អស់ក្រោកឈរ សួរថា: អ្នកគ្រូ! អ្នកគ្រូ! អក្សរ "គ" ដែលប្រើផ្សំនឹងស្រៈនិស្ស័យ "ឃោសៈ" គឺត្រីសព្ទ "ˉ" នៅពីលើស្រៈ "ˉ" វត់ទៅណាបាត់មិនឃើញទាន!

អ្នកគ្រូឆ្លើយថា: អាចំកួត! "ˉ" នៅលើអក្សរ "គ" ហ្នឹងហើយ ម្ដេចអាឯងថាទៅណាបាត់!

កូនសិស្សតបថា: ទាន! ត្រីសព្ទ "ˉ" ហ្នឹងជារបស់អក្សរ (គ) ពីកំណើតទេតើទាន! ឯត្រីសព្ទ (ˉ) ១ ទៀតរបស់ស្រៈ (ˉ) មិនឃើញផង!

អ្នកគ្រូយើងធ្វើមុខផ្អូរ . . . ហើយឆ្លើយប្រាប់ថា: ល្ងើយរឿងនេះ កុំនិយាយធ្វើអី អញមិនដឹងទេ :ង់ចាំបណ្ឌិតសភាខាងអក្សរសាស្ត្រកើត សឹមនិយាយ ។ ផេង.ជ្រីវ

# អ្នកមានគុណ

## បទពាក្យ ៧

រៀបរៀងដោយលោក ហោង-សមអាន នៅសេនាធិការយោធភូមិភាគទី ១ ខេត្តកំពង់ចាម អតីតគ្រូបង្រៀនយុទ្ធសាស្ត្រ នៃមជ្ឈមណ្ឌលសិក្សាថ្មើរជើង ខេត្តពោធិសាត់ :

(ក)

ទោសកាប់សម្លាប់ម្ដាយឪពុក មានរឿងតាំងទុកព្រេងព្រាវប្រាយ
លោកបានរៀបរៀងស្ដីបរិយាយ រំលងធ្លាយតមកជាសេចក្ដី :
ក្នុងធម្មបទយ៉ាងពិស្ដារ ស្រង់យកខ្លឹមសារបំព្រួញខ្លី
បទពាក្យប្រាំពីរទៅសេចក្ដី សំដីចាប់ជួនផ្ទួនគ្រប់ឃ្លា ។
ក្នុងកាលកន្លងយូរយារណាស់ មានរឿងរ៉ាវច្បាស់ចែងពណ៌នា
មានបុរសម្នាក់ស្ថិតនៅនា ក្នុងជាភពពារាណសី ។
អកពញ្ញាទុបទុំជួន ជឿពាក្យប្រពន្ធកាឡកណ្ណី
ញុះញង់អុជអាលរាល់រាត្រី ដើម្បីឲ្យស្អប់ឪពុក-ម្ដាយ ។
បុរសកំសាកស្មារតីខ្ទន់ ដោយតាមប្រពន្ធមិនគិតឆ្ងាយ
គិតតែត្រិះរិះរកឧបាយ កំចាត់កំចាយម្ដាយ-ឪពុក ។
ថ្ងៃមួយដើរទៅអង្គុយផឹក ប្រាប់ថាញាតិមិត្រនៅឯស្រុក
ឯណោះរឭកនឹកម៉ែ-ពុក កើតទុក្ខត្រូវតែពេលកុំរ៉ៃ ។

ផ្ដាំមកឲ្យខ្ញុំនាំពុក ម៉ែ ទៅលេងលំហែបាន ៣ ថ្ងៃ
កូនក៏ត្រេកឥតអាល័យ ពល់ ៗ តែថ្ងៃមិនដែលខាន ។
យាយ-តារីករាយសប្បាយចិត្ត នឹកពីអតីតញាតិសន្ដាន
មិត្តភក្ដិម្រាក់ក្មេកទាំងប៉ុន្មាន ដែលធ្លាប់រាប់អានស្និទ្ធស្នេហា ។
ក៏សួរទៅកូនប្រុសសម្លាញ់ តើកូននាំអញទៅថ្ងៃណា
ម៉ែ-ឪអរណាស់ប្រុសស្នេហា ត្រេកម៉ង-មាចាពល់ថ្ងៃ ។
កូនប្រុសគំរក់អឥតរិយ លុងដោយសំដីស្រើចស្រៃ
ប្រាប់ថា " ម៉ែ-ពុកកុំសង្ស័យ ខ្ញុំនាំទៅថ្ងៃនេះឯងណា " ។
ហើយរៀបរទេះទឹមក្របី កាន់មោងខ្សែតីដាប់ហត្ថា
បរនាំមាតានឹងបិតា ចូលព្រៃព្រឹក្សាមហាសែនឆ្ងាយ ។
លុះដល់ព្រៃស្ងាត់បាត់សូរសត្វ ក៏និយាយប្រាប់ឪពុក-ម្ដាយ
" ម៉ែ-ឪ ! ព្រៃនេះមានអន្ដរាយ ពួកចោរទាំងឡាយតែងពាលា ។
ឪកាន់ខ្សែបរកុំភិតភ័យ កូនដើរក្នុងព្រៃចាំមើលវា
បើចោរព្រៃឃើញឪជក ទ្រុឌព្រោមគ្រាំគ្រាវ៉ាអាណិត ,, ។
ថាហើយហុចខ្សែទៅឲ្យឪ ចុះដើរតាមផ្លូវនៅប្រកិត
តាំងស្រែកសំឡុតតាមតែចិត្ត គ្មានគិតអាណិតឪពុក-ម្ដាយ ។
ហើយស្ទុះចូលវាយដំជ្រាំណាក់ បែកឈាមសស្រាក់ធ្លាក់ហូរខ្ចាយ
គ្មានចិត្តអាណិតឪពុក-ម្ដាយ បែកឈាមហូរខ្ចាយសព្វកាយា ។
កំពុងតែវាយយាយ-តាស្រែក សូរសព្ទសម្រែកស្រែកច្បាស់ថា

កូនអើយ ! ចូរវៀរចៀសគ្នា　　កុំនៅនេះណាប្រុសសម្លាញ់ ។
ពោរពាយប្រហារឪពុក-ម្ដាយ　　កូនៈចៀសឲ្យឆ្ងាយកុំគិតអញ
ម៉ែ.ឪស្លាប់ចុះប្រុសសម្លាញ់　　ព្រោះអញចាស់ហើយប្រុសស្នេហា ។
ម៉ែ-ឪស្រែកហើយស្រែកប្រាប់ទៀត　　កូនពាលពោលមៀតពាយទៀតណា
ទាល់តែមាតាទាំងបិតា　　ដល់នូវមរណាទាំងពីនាក់ (១) ។
យល់ថាស្លាប់បាត់សូន្យសញ្ញី　　កូនពាលត្រិះយកញកទ្រាក់
មាតាបិតាទាំងពីរនាក់　　ទម្លាក់មកដីដូចឆ្កែឆា ។
ហើយវិលត្រឡប់ទៅគ្រឹះស្ថាន　　បីបមថ្នមប្រាណស្និទ្ធស្នេហា
រួមរ័ក្សស្មោះស្ម័គ្រស្មើជីវា　　នឹងស្រីមួយស្បាកាឡ្យកណ្ណី ។
លុះស្លាប់បាត់បង់ស្ងាត់បាត់ទៅ　　ចាប់កំណើតនៅឋានអវិចី
យមបាលកាប់កាត់ផ្ដាច់សិរសី　　ពោះក្នុងអវិចីឆេះកាយា ។
ឆេះក្នុងនរកអស់១កប្ប　　ទើបចាប់កំណើតជាមនុស្ស
ត្រូវចោរគោរសាច់ផ្ដាច់ជីវ　　កាប់កាត់សិរសា ៥០០ ជាតិ ។

បទព្រហ្មគីតិ

ទោសពាយឪពុក.ម្ដាយ　　ខ្ញុំដោះស្រាយមិនឲ្យឃ្លាត
ពីព្រះពុទ្ធវាទ　　ដែលមាននៅក្នុង ម.អ (២) ។

---

១- ក្នុងគម្ពីរមង្គលត្ថទីបនីថា គ្រាន់តែវាយបន្តិចបន្តួច ក៏កើតចិត្តអាណិតឪពុកម្ដាយ នាំយកទៅផ្ទះ ហើយចិញ្ចឹមរក្សាមិនឲ្យហ្មង ។

២- មង្គលត្ថទីបនី អដ្ឋកថា ។

បងជាបទព្រហ្មគីត  រឿងអតីតពិតជាល្អ
ចាប់ចួនផ្ទួនបន្ត  បណ្ដាក់ល្អគ្រប់វគ្គឃ្លា ។
កន្លងកាលពីអតីត  មានរឿងពិតចែងពណ៌នា
ពីជនទ្រុស្តមាត  ស្ថិតនៅក្រុងពារាណសី ។
ឈ្មោះមិត្តវិន្ទុកៈ  ខ្ញៅអប្បលក្ខណ៍អន្យត្រីយ
ជាកូនមហាសេដ្ឋី  ខ្ញុំប្រុសស្រីគាល់និត្យនៅ ។
សេដ្ឋីជាបិតា  ធ្វើកិរិយាចែកស្ថានទៅ
មិត្តវិន្ទុកៈនៅ  តែពីរនាក់និងមាតា ។
ថ្ងៃ ១ ដេកព្រួយចិត្ត  សញ្ជឹងគិតក្នុងចិន្តា
ចង់ចេញជួញប្រែ-ផ្កា  តាមគេគ្រាទៅទីឆ្ងាយ ។
គិតហើយដើរចូលទៅ  កាន់លំនៅរបស់ម្ដាយ
ប្រាប់ថា « ខ្ញុំទៅឆ្ងាយ  ធ្វើជំនួញតាមសំពៅ » ។
មាតាសែនស្រណោះ  កូនកម្លោះចាកចេញទៅ
តាមផ្លូវសមុទ្រជ្រៅ  ខ្លាចក្រែងមានភយន្តរាយ ។
ក៏ល្បងលោមបុត្រា  អង្វរថា កូនមាសម្ដាយ
ចូរកូនកុំទៅឆ្ងាយ  អាណិតម្ដាយណាប្រុសណា ! ។
ទុកម្ដាយនៅម្នាក់ឯង  វែងចាំចែងក្នុងទុក
កុំទៅណាប្រុសណា  អាណិតម្ដាយកាន់តែចាស់ ។

សមុទ្រគួរឲ្យខ្លាច មានសត្វកាចច្រើនដេរដាស
ក្រពើធ្លាមច្រើនណាស់ ក្នុងសមុទ្រណាប្រុសម្ដាយ ។
ចូរកូនប្រុសកុំទៅ តាមសំពៅខ្លាចអន្តរាយ
មាសប្រាក់ពេជ្រទាំងឡាយ ក្នុងផ្ទះយើងមានច្រើនក្រៃ » ។
លួងលោមអង្វរហើយ មិនកន្តើយចូលចាប់ដៃ
ឱបរឹតស្និទ្ធស្នេហ៍ក្រៃ កូនប្រុសមួយព្រួយដ៏ក ។
ឯមិត្តវិទុក: ទៅអប្យលក្ខណ៍ទ្រុស្តមាតា
ស្ទុះចេញពីហត្ថា នៃមាតាហើយក្រញី ។
រាយវែធទាត់យាក់តប់ ដួលសន្លប់បាត់ស្មារតី
កូនពាលអន្យត្តរិយ លោតរំលងខ្នងទៀតណា ។
រត់លឿនឆ្ពោះត្រង់ទៅ ជិះសំពៅកាត់ផលសា
ត្រូវក្តោងលឿនណាស់ណា ដល់កណ្តាលមហាសាគរ ។
សំពៅកៀងនឹងថ្កល់ បលាបលខ្យល់កែវ
ភិតភ័យក្អកបញ្ជរ ផ្អើលឈូឆរទាំងប្រុសស្រី ។
នាំគ្នាពិភាក្សា ក្នុងកេត្រាប្តូរសំដី
ថា « មានកាឡកណ្ណី ពាលអប្រិយនៅជាមួយ » ។
ក៏ធ្វើស្លាកឲ្យចាប់ តាមលំដាប់ដោះទុក្ខព្រួយ
មានស្លាកគាក្រក់មួយ ដើម្បីជួយនូវមរណៈ ។

ស្វាកដែលអាក្រក់នោះ　បានទៅឈ្មោះវិទូក:
ជាមនុស្សពាលអប្បលក្ខណ៍　អស់ការ:តាំង ៣ ដង ។
អ្នកជិះផុតទុក្ខព្រួយ　ធ្វើក្បូនមួយឲ្យជិះឆ្លង
ទៅត្រើយមិនឲ្យហួង　តាមបំណងប៉ងប្រាថ្នា ។
ខ្យល់ព្យុះបោកបក់ផាត់　ក្បូនរសាត់កាត់ជលសា
ដល់កោះមួយឈ្មោះថា　ឧទកនរកធំ ។
វិមិត្តវិទូក:　ឃើញប្រប័ក្សហាក់សង្គម
ឬមហានគរធំ　រាជធានីទីសប្បាយ ។
ក៏ឡើងដើរចូលទៅ　ទីលំនៅសត្វតាំងឡាយ
កំពុងក្តៅក្រហាយ　ទុក្ខវេតកាយឥតឈប់ឈរ ។
បំណងចងកាយា　ឃើញច្បាស់ថាគ្រឿងលំអ
បិតញ្ចៀនកងខ្សែក　ភ្ញីចិញ្ចៀនល្អអន័គ្ឃ ។
កងចក្រជាប់លើក្បាល　ខ្ទិលខ្ទាល់ឈាមសស្រាក់
ជាមកុដវេតន:　ភ្ញីចិញ្ចៀនរំលេចចរ ។
បានឃើញដូច្នោះហើយ　មិនកន្តើយពោលអង្វរ
« ម្នាលអ្នករូបបវរ　កាយស្រស់ល្អគ្រប់លក្ខណ: ។
ខ្ញុំខំប្រឹងស្វះស្វែង　យូរអង្វែងហើយណាអ្នក
ដើម្បីរកវេតន:　កែវកងពាក់កដើងដៃ ។

សូមលោកប្រោសមេត្តា ដល់ខ្ញុំណា៎ ណា៎ម្ចាស់ថ្លៃ
សូមពាក់បានមួយថ្ងៃ ខ្ញុំមកុដពេជ្រនឹងសង្វារ ,, ៗ
រីសត្វនរកនោះ ឮដូច្នោះយល់អស់គាថា
« មិនមែនអលង្ការ កងសង្វារខេណាមិត្ត ៗ
គឺច្បាស់ជាចំណង យមបាលចងរួបរួតរឹត
នឹងកង់ចក្រណាមិត្រ ខួងក្បាលខ្ញុំឈឺពេកក្រៃ ,, ៗ
មិត្តវិន្ទុកៈថា ,, មិត្តស្នេហាកុំសង្ស័យ
មាស-ពេជ្ររលេចក្រៃ ផ្កាយពន្លឺភ្លឺចិញ្ចែង ៗ
ខ្ញុំឃើញប្រាកដណាស់ នឹងក្អែកច្បាស់យ៉ាងជាក់ស្តែង
អ្នកកុំករគ្នាឯង ខ្ញុំសូមតែងខ្លួនបានម្តង ,, ៗ
នរកទុក្ខឥតស្រាក ដោះកង់ចក្រនឹងចំណង
ចំណងស្ទុះទៅចង រួតរឹតមិត្តវិន្ទុកៈ ៗ
កង់ចក្រធ្លាក់លើក្បាល ខ្លួនវិលខ្វាល់ឈាមស្រោក
ទុក្ខធំធ្ងន់អនេក្យ ឈាមស្រោកតាមកាយា ៗ
មិត្តវិន្ទុកៈខ្លៅ សោយសោកសៅក្តៅខ្លោចផ្សា
ទោសវាយតប់មាតា រងទុក្ខាអចិន្ត្រៃយ៍ ៗ

## បទពាក្យ ៧

ខ្ញុំសូមវែកញែកឲ្យជាក់ច្បាស់ ជនល្មើសមុខក្រាស់កាចចង្រៃ

អតីតនិទានបានកែថ្លៃ ស្ដាព្រៃទិនមនុស្សអន្យត្ថិយ ៗ
កាលពីអតីតព្រឹទ្ធព្រេងទាយ នៅភូមិជិតជាយដែនកាសី
មានព្រានម្រិគម្នាក់ពាលអប្រិយ រកស៊ីបរបាញ់អចិន្ត្រៃយ៍ ៗ
យកសាច់លក់ដូរប្ដូរយកប្រាក់ សំលៀកបំពាក់ស៊ីវិឡៃ
ស្រូវខ្សាយដំណើរព្រានកែខែ ដូររាល់ ៗ ថ្ងៃមិនដែលខាន ៗ
បានប្រាក់ស៊ីចាយសប្បាយចិត្ត ជាមួយវរមិត្រកែវកល្យាណ
ប្រពន្ធល្អថ្លៃកប់ខ្សែកប្រាណ សម្ពស្សកល្យាណស្រស់ប្រិមប្រិយ ៗ
ថ្ងៃ ១ ព្រានព្រួយចិត្តអស្ចារ្យ ដោយអស់អាហារនំចំណី
កំលាករិយាសាច់សត្វ ចូលអរញ្ញតែម្នាក់ឯង ៗ
ខំប្រឹងរុករើមើលរកសត្វ ក្នុងព្រៃស្ងួនស្ងាត់បាត់ស្ងូរសែង
ដើរឆ្ងាយ ៗ ទៅដាច់សន្ទែង ហួសពីកន្លែងដែលធ្លាប់បាញ់ ៗ
ដល់ពេលព្រលប់យប់ស្ងួនឈឹងព្រានព្រៃខំប្រឹងដោយចិត្តក្នាញ់
ឡើងលើដើមឈើចាំប្រុងបាញ់ ក្នក់ក្នាញ់ក្នុងចិត្តឥតឧបមា ៗ
វាយោបក់ផាត់រសាត់មក ព្រានព្រៃនឹកក្នកព្រឺកាយា
នឹកដល់សម្ពស្សស្រស់ស្នេហា ស្រែកច្រៀងសកវាទំតែម្នាក់ឯង ៗ

មើលហ្ន៎ ! ព្រះចន្ទកាន់តែភ្លឺ
ផ្សព្វផ្សាយពន្លឺ ភ្លឺចិញ្ចែង
ខ្ញុំនឹកស្រណោះទីកន្លែង
ដែលធ្លាប់ប្រឡែងលេងនឹងស្រី ៗ

សង្សារឃ្លាតឆ្ងាយ ពីកាយពៅ
ធ្លាប់នៃបទឹត្យនៅ កល់កត្រី
ស្តាយអើយសែនស្តាយ កាយសង្ខី
ធ្លាប់ថ្នាក់ថ្នមបី ស្រីបវរ ៗ

លុះព្រឹកព្រាងស្វាងព្រះសុរិយា រះច្បាស់កាលណាព្រានគ្រេកអរ
ស្ពាយបាយទៅតាកបាកចេញចរ ដៃកាន់ធ្នូសរបរបាញ់សត្វ ៗ
ចំដើរបើរកុកក្តុលក្តៅ ក្នុងចិត្តម្ហួម៉ៅក្តៅពេកក្តាត់
ស្វះស្វែងបរបាញ់ក្នុងព្រៃស្ងាត់ គ្មានបានជួបសត្វអ្វីមួយសោះ ៗ
ក្អែកគន់រំពៃលៃពិនិត្យ ពីជិតទៅឆ្ងាយគ្មានបន្ទោះ
គុម្ពោតតូចធំសព្វកៀនកោះ គ្មានសល់បន្ទោះសោះឡើយណា ៗ
កំពុងតែប្រុង ៗ ប្រយ័ត្ន សម្ទឹងរកសត្វក្នុងព្រឹក្សា
ស្រាប់តែពេបពះប្រទះខ្លា មួយធំណាស់ណាក្បាលធីធើ ៗ
ព្រានភិតភ័យណាស់ស្រែកយំអ៊ោង ប្រឹងស្ទុះលោតតោងឡើងដើមឈើ
ពេលនោះស្វាសនៅពីលើ ទាញឡើងដើមឈើធ្វើព្រងើយ ៗ
ខ្លាឃើញស្វាសចាប់ទាញដៃ ព្រានពាលបង្រៃឡើងផុតហើយ
ក្រេវក្រោធពិរោធពុំមានស្បើយ ពោលថា ស្វាអើយ ! អឺបងស្វា ៗ
ខ្ញុំទំប្រឹងដេញតាមព្រានព្រៃ បង់ធីថ្ងៃមក្រែកឥតឧបមា
ចូរបងទម្លាក់ព្រានមកណា បងកុំរក្សាព្រានកម្លៅ ៗ

បងអើយខ្ញុំប្រាប់បងជាមុន    បងកុំធ្វើគុណមនុស្សក្បាលខ្មៅ
បងព្រានចុះមកខ្ញុំសុំទៅ    ទុកនាំហ្វូងសៅក្តៅក្រហាយ » ។
រីឯស្តេចស្វាចិត្តស្មោះសរ    ជាសត្វមានធម៌ប្រចាំកាយ
មេត្តាករុណាស្វាតែងផ្សាយ    ដល់សត្វទាំងឡាយមិនរើសមុខ ។
ស្វាសុខទូលនូវភារៈ    ដោយចិត្តស្មោះស្ម័គ្រពេញបន្ទុក
ហ៊ានចេញការពារពាំងមុខ    ការពេញបន្ទុកដោយប្រាជ្ញា ។
ក្រោកឈរធ្វើយតបយ៉ាងអង់អាច    មិនតក់ស្លុតខ្លាចអំណាចខ្លាច
«បងអើយ! ព្រានព្រៃភ័យអាត្មា    រត់មកប្រាថ្នាការជីវិត ។
ខ្ញុំសែនអាណិតឥតប្រៀបបាន    មិនអាចរុញច្រានបានទេមិត្ត
ចុះមនុស្សក្បាលខ្មៅខ្មៅទុច្ចរិត    ព្រេងព្រឹទ្ធសំដែងចែងយ៉ាងណា ?។
ខ្លាធំក្រេកអរមុខរីករាយ    នាំរឿងព្រេងនាយនិយាយថា
បងអើយចាំស្តាប់ស័ព្ទកថា ៖

## រឿងមនុស្ស-ពស់-ខ្លាធ្លាក់រណ្តៅ

កាលពីអតីតព្រឹទ្ធព្រេងនាយ    មានរឿងនិយាយមនុស្សក្បាលខ្មៅ
រងទុក្ខក្ខលក្កុកសោយសោកសៅ    នៅក្នុងរណ្តៅក្តៅខ្លាចផ្សា
ជាមួយសត្វខ្លានិងសត្វពស់    ស្ទើរស្លាប់ស្ទើររស់ព្រោះអាត្មា
អត់បាយអត់ទឹកមួយសប្តាហ៍    ស្គាំងស្គមកាយាស្វិតក្រៃ ។
កាលនោះមានព្រាហ្មណ៍សប្បុរស    មុខរីករាយស្រស់ញញឹមប្រែ

រកស៊ីកាប់អុសកល់ ៗ ថ្ងៃ  លក់យកកំរៃជូនមាតា ។
មានកាលថ្ងៃ១ព្រាហ្មណ៍ត្រូវការ  ចេញចាកពីផ្ទះចូលព្រឹក្សា
ក៏ជួបសត្វពស់មនុស្សនឹងខ្លា  កំពុងសោកាក្នុងរណ្តៅ ។
ព្រាហ្មណ៍ឃើញដូច្នោះអាណិតក្រៃ  ស្ទុះញាប់ជើងដៃទៅរកផ្តៅ
កាប់ជាសន្ធែកទម្លាក់ទៅ  ចុះក្នុងរណ្តៅដោយស្មោះសរ ។
ខ្លាពស់ឃើញច្បាស់លែងយំស្រែក  លោតតោងសន្ធែកសែនត្រេកអរ
ព្រាហ្មណ៍យោងឡើងផុតរួចពីមរណ  ខ្លាពស់ត្រេកអរជំរាបថា ។
«លោកម្ចាស់មានគុណធ្ងន់សែនធ្ងន់  ធ្ងន់ក្រៃលើសលន់ឥតឧបមា
ខ្លួនខ្ញុំជាសត្វពស់នឹងខ្លា  មានតែហត្ថាលើកប្រណម្យ ។
ប្រសិនបើលោកមានធុរៈ  ដល់នូវមរណៈគ្រោះថ្នាក់ធំ
សូមលោករឭកនឹកដល់ខ្ញុំ  ហ៊ានធានាសុំប្តូរជីវិត ។
តែលោកកុំយកមនុស្សក្បាលខ្មៅ  ចេញពីរណ្តៅជ្រៅងងឹត
ព្រោះមនុស្សក្បាលខ្មៅខ្លៅទ្រុស្តមិត្រ  ឲ្យទោសទុក្ខពិតជាមិនខាន» ។
ប្រាប់ហើយខ្លាពស់ក្រាបលាព្រាហ្មណ៍  ចេញចាកទៅតាមផ្លោះទីឋាន
ជួបជុំក្រុមញាតិមិត្រសន្តាន  បានសុខក្សេមក្សាន្តគ្រប់ទិវា ។
ឯព្រាហ្មណ៍កម្សោះមិនផ្តេសផ្តាស  អាណិតព្រានណាស់ជាតិដូចគ្នា
កំពុងតែរងទុក្ខវេទនា  ទ្រុឌទ្រោមគ្រាំគ្រាក្នុងរណ្តៅ ។
ព្រាហ្មណ៍មិនជឿពាក្យខ្លានឹងពស់  ចំស្រង់បានរស់មនុស្សក្បាលខ្មៅ

រួបពីមរណៈនៃរណ្តៅ    មនុស្សពាលក្បាលខ្មៅនិយាយថា ៗ
«ខ្ញុំបាចអរគុណនឹងលោកម្ចាស់    គុណលោកធ្ងន់ណាស់ឥតឧបមា
គ្មានអ្វីសងគុណលោកឡើយណា    មានតែហត្ថាថ្វាយបង្គំ ៗ
ខ្ញុំជាជាងមាសយ៉ាងចំណាន    មានគេហដ្ឋាននៅក្រុងធំ (១)
លោកមានការអ្វីទៅរកខ្ញុំ    ឯទីក្រុងធំខ្ញុំជូនបាន ៗ
ហើយមនុស្សក្បាលខ្មៅខ្លៅពាលា    លុតក្រាបវន្ទាបន្ទន់ប្រាណ
លាព្រាហ្មណ៍ចេញទៅគេហដ្ឋាន    បានសុខក្សេមក្សាន្តរាល់រាត្រី ៗ

---

១– រាជធានីពារាណសី ។

(នៅមានត)

ប្រមឹកស្រុក    ស្រវឹងដោយនារី
វក់ការបរបាញ់    លេងល្បែងភ្នាល់
រៀបជាន់ទ្រព្យសម្បត្តិ    រាំចាអាក្រក់
ចណ្ហកម្មដ៏អាក្រក់    ទាំងអស់នេះជា
សេចក្តីអន្តរាយនៃមនុស្ស ។

ហិតោបទេស

# វិធុរជាតក (ត)

បពិត្រអើយ ព្រះបាទពិរុណនាគរាជនោះមិញ យល់នាងខ្វល់សំបាផង់ដូច្នោះហើយ មហាក្សត្រមានព្រះរាជហឫទ័យនោះជាទុក្ខអផ្សុកមហិមាក្រៃពេក មហាក្សត្រាធិរាជ មិនអាចដើម្បីនឹងទប់ទល់ដំកលអាត្មានោះបានឡើយ ស្តេចក៏លីលា ចូលទៅគន់ក្នុងល្វែងមានសិរីសួស្តីនៃព្រះអង្គឯងហើយ ស្តេចទ្រង់ព្រះចិន្តាពិចារណា ក្នុងព្រះរាជហឫទ័យនៃព្រះអង្គឯងថា ឲនាងវិមលាទេវី នាងអើយ ប្រាថ្នាម្តេចចង់ធីថ្លើមទៅពិធូរអ្នកប្រាជ្ញ កុំថាដល់ថ្លើមឡើយ សូម្បីតែតួទៅពិធូរអ្នកប្រាជ្ញនោះ ម្តេចកម្រនឹងបានយល់ហ: ឥតអ្នកឯណា ១ ក៏នឹងមានឫទ្ធិអានុភាព មានអំណាច អាចទៅនាំទៅពិធូរអ្នកប្រាជ្ញនោះមកអំពីអំឡុងសកលជម្ពូទ្វីបនោះ មកដល់ពិភពលោកនេះបានឡើយ ក៏នឹងយកថ្លើមទៅអ្នកប្រាជ្ញនោះ ឲ្យនាងស៊ីដោយចំណង់នាងហោង ។ ព្រះបាទពិរុណនាគរាជថា ឲអញអើយ មានទុក្ខក្នុងខ្ទងធ្ងន់ពន់ប្រមាណអ្វី មាលព្រាយអេះ ស្តេចទ្រង់ព្រះចិន្តា ពិចារណានូវប្រការអម្បាលនោះហើយ ស្តេចគន់សុបសៅស្រងើនៅហោង ។ អថ ខីតា ឥរន្ធតី ណាម ណាកកញ្ញា សញ្ញ. លង្ការបដីមណ្ឌិតា មហាច្ឆេជ សិរីវិលាសេជ ។ បពិត្រអើយ ព្ធកាលនោះ ព្រះបាទពិរុណនាគរាជទឹងនាងវិមលាទេវី មានព្រះរាជបុត្រ ១ ព្រះអង្គទ្រង់មានព្រះនាមឈ្មោះនាង ឥរន្ធតី(១) ដ៏ជាកូនស្រីក្រមុំមាន

---

១ – ក្នុងគម្ពីរសាស្ត្រាស្លឹករឹត គេនិយមហៅឈ្មោះនាងនាគកញ្ញាថា "អារិនទតី" ។

នវលក្ខណ៍ឧត្តមសមនូវរូបនោះល្អ កម្រនឹងមាននៅពិភពនាគនេះ ឥរន្ទតី នាងប្រដាប់សម្រាប់អង្គនាងជាដើម គឺស្នាប់ព្រះជង្គង់ អង្គព្រះហូរក្ខ នូវមកុដ ភាពម អន្ទាម ព្រះស្បូវង់កង់ចិញ្ចៀនស្រេចហើយ ទើបនាង ទ្រង់ព្រះពស្ត្រ ព្រះសុក៏គដ៏មានពណ៌រស្មីនោះល្អប្រពៃ ស្រេចហើយនៃ ទើបនាងលីលា ទៅគាល់សម្តេច ព្រះវរបិតាធិរាជ ដល់ហើយ នាង ថ្វាយបង្គំប្រណម្យសម្តេច ព្រះវរបិតាធិរាជ ហើយនាងបំគហាន១ ដ៏សម គួរទីឯកាត្តាហើយ ទើបនាងរមិលមើលទៅយល់សម្តេចព្រះវរបិតាធិរាជពុំ សុខសប្បាយដូច្នោះហើយទើបនាងទូលដណ្តឹងទៅ ស្ទូត្រជាបទគាថាដូច្នេះ

កិន្នុ តាត តុវំ បជ្ឈាយសិ បទុម ហត្ថគតំវ តេ មុខំ កិន្នុ ទុម្មនរូបោ សិ ។ បពិត្រសម្តេចព្រះវរបិតាធិរាជ អម្ចាស់វិសេសអើយ ហេតុអ្វីព្រះគុណសុបសៅស្រពោនដ៏មានព្រះភក្ត្រនោះក្រហមទុំ ហាក់ដូច ឱនស្រក់ឈាមចេញ បីដូចអ្នកយកផ្កាឈូកមកញីញ៉ីពួជកណ្តាល ព្រះ ភក្ត្រដាក់លើបាតដៃ អ្នកនោះចេញទៅកណ្តាលថ្ងៃ សឹងជិតស្វិតជ្រីវ ស្រពោន នោះមានប្រការម្តេចម៉េញ ព្រះភក្ត្រព្រះអង្គនោះ ស្វិតជ្រីវ ដូច្នោះហ្ន៎ បពិត្រព្រះវរបិតាអម្ចាស់វិសេសខ្ញុំអើយ ព្រះអង្គមានព្រះ រាជហឫទ័យ ជាទុក្ខអផ្សុក ដ្បិតអីក្រែងមានសត្រូវមកក្នុងព្រះនគរឬម្តេច កាលនោះព្រះពិរុណនាគរាជ ស្តាប់ពាក្យនាងឥរន្ទតី ស្រដីដូច្នោះហើយ មានព្រះបន្ទូលទៅនឹងនាងឥរន្ទតីថា ហៃកូនស្រីសំឡាញ់អាពុកអើយ

វីអាពុកជាទុក្ខទាំងអម្បាលនេះ មិនប៉ុន្តែសេចក្តីអ្វី បីក្រែ ទឹងនាងវិមលា
ទេវី ដ៏ជាម្តាយនៃនាងឡើយ ឯម្តាយនាងប្រាថ្នាចង់តែស៊ីថ្លើមចៅពិ-
ធូរអ្នកប្រាជ្ញ ហៃឥរន្ទតីកូនស្រីសំឡាញ់អាពុកអើយ វីនាងវិមលាទេវី
ថាបើពុំបានស៊ីថ្លើម ចៅពិធូរអ្នកប្រាជ្ញនោះឡើយ នាងនឹងក្ស័យ
ជីវិតប្រាកដហោង ហៃនាងឥរន្ទតី នាងអើយ កុំថាតែថ្លើមឡើយ សូម្បី
តែតួចៅពិធូរអ្នកប្រាជ្ញនោះ យល់ថា កម្រក្រែទឹងបាន ឱនាងឥរន្ទតី
អើយ អាពុកគិតទៅហើយ អាសូរនាងណាស់ហ្ន៎ះ ឥតអ្នកឯណា ១
មានរិទ្ធិអានុភាព មានអំណាចអាចទៅនាំមកឲ្យបានឡើយ ហៃឥរន្ទតី
កូនស្រីសំឡាញ់អើយ មិនគួរគេប្រស្រដីទឹងនាងឡើយ ថាបើនាងចង់
ឲ្យម្តាយនាងមានជីវិតរស់នៅ ចូរនាងទៅស្វែងរកអ្នកប្រាជ្ញណា មាន
ឫទ្ធីអានុភាព មានអំណាចច្រើន អាចទៅនាំចៅពិធូរអ្នកប្រាជ្ញមកឲ្យដោយ
ចំណង់ម្តាយនៃនាងបាន ហើយចូរនាងទៅជាភរិយាអ្នកនោះហោង ។
តេន វុត្តំ ។ បិតុ ច សា សុត្វាន វាក្យំ រត្តិ និក្ខម្ម
អវសរ្សុតិ ចរិ ។ នាងឥរន្ទតី ស្តាប់ព្រះបន្ទូលព្រះវរបិតាធិរាជហើយ នាង
ថ្វាយបង្គំប្រណម្យទូលថា បពិត្រព្រះសម្មតិទេព មហារាជអើយ ថា
បើដូច្នោះហើយ កុំឲ្យព្រះអង្គព្រួយ ព្រះរាជហឫទ័យឡើយ ទុកដារ
ខ្ញុំឯង នឹងទៅរកថ្លើមចៅពិធូរអ្នកប្រាជ្ញនោះមកឲ្យ ដោយចំណង់ព្រះ
រាជហឫទ័យនៃសម្តេចព្រះវរមាតាខ្ញុំហោង ។ ម្ល៉ោះហើយនាងឥរន្ទតី

នាងលោមសម្តេចព្រះវរបិតាធិកដហើយ នាងថ្វាយបង្គំប្រណម្យលា សម្តេចព្រះវរបិតាធិកដទៅលោមនាងវិមលាទេវី ដ៏ជាសម្តេចព្រះវរមាតា ហើយនាងលីហោទៅកាន់ល្វែងមានសិរីសួស្តី យកសំពត់ដក់គាំ មានរស្មីនោះក្រហមប្រាលទ្វាលល្អ នាងទ្រង់ ហើយនាងយកស្បៃប្រពៃ មកពាក់លើព្រះអង្គ ហើយនាងលីលាកែក្រាយដជាយទំលាយទឹកមហាសមុទ្រប្រាកដឡើងអំពីពិកពនាគនាយ នាងលីលាដោយផ្លូវមហាស-មុទ្រប្រាកដទៀបព្រៃ ប្រទេស ខេត្ត ខែម ព្រះហេមពាន្ត ស្ថានស្អាតជាប្រទេសវិសេស ប្រសើរ ហើយនាងទៅកាន់ភ្នំមួយឈ្មោះកា-ឡាគិរីអញ្ចនបពិតប្រាកដ មានកំពស់ ៦០ យោជន៍ពិត មានទំហំនោះពេញ គាន់ខ្ពន់ខ្ពប់ សីងល្អបរិសុទ្ធ បពិត្រអើយ វីនាងឥវទ្ធិតី នាងទៅបេះផ្កាឈើមកក្រងជាកម្រងមាលាផ្កាក្រ ហើយនាងទៅប្រាយកាយលើកំពូលភ្នំកាឡាគិរីអញ្ចនបពិតប្រាកដ ដូចកម្រងមណីរត្ន គិតដ៏ពិចិត្រប្រពៃហើយនៃ ទើបនាងឥវទ្ធិតីឈរលើកម្រងផ្កា ហើយនាងកំច្រៀងមានសូរសំឡេងនោះផ្អែមល្ហែមពីរោះសោះសា ស្រែកសូត្រជាបទព្រះគាថា ។ កោ គន្ធព្វេ រក្ខសេ ឆាកេ កោ គឹ បុរិសេ កោ ច មានុសេ បណ្ឌិតេ សព្វកាមទទេ ទីឃរត្តំ កត្តាមេ ភវិស្សតិ ទុនាគ យក្ខ គន្ធព្វ អសុរគត បុរសឯណាហើយ ថាបើអ្នកនោះមានបារមី រិទ្ធិអានុភាព មានអំណាចអាចទៅនាំថ្ងៃមទៅពិធូរអ្នក

ប្រាជ្ញនោះមកឲ្យដោយចំណង់ ម្តាយខ្ញុំ ខ្ញុំនឹងទៅជាភរិយានៃអ្នកនោះហោង នាខ្ញុំទៅជាភរិយានៃអ្នកនោះ មិនប៉ុន្តែថ្ងៃមួយថ្ងៃពីរឡើយ ទីឃរត្តំអស់កាលដ៏លង់ទៅហោង បពិត្រអើយ កាលនាងឥរន្ទតីទៅច្រៀងរាំលើភ្នំកាឡាគិរីអញ្ជនបពិតនោះ មិនបាត់ស្ងាត់ ប៉ុន្តែនាងឯងទេឡើយ ៗ តស្មិំខណេ វេស្សវណោមហារាជស្ស ភាគិនេយ្យោ បុណ្ណោ កោណាម ៗ

ខ្សែទី ២

បពិត្រអើយ កាលនោះ មានយក្សសេនា១ ជាក្មួយព្រះបាទវេស្សវណ កុវេរ មហារាជ រីយក្សសេនានោះឈ្មោះ បុណ្ណកយក្ស មានសេះសិន្ធព១ ឈ្មោះ មនោម័យ ដ៏មានប្រវែងខ្លួនប្រមាណបានបីគាវុត្តប្រាកដក្រៃពេក បុណ្ណកយក្ស ឲ្យចងគ្រឿងប្រដាប់សម្រាប់ មនោ-ម័យជាដើម គឺស្នាប់ទ្រាប់កណ្តាល បុស្ស រនាំង ខណ្ឌជីបសរសៃសូត្រវិសមកែមកញ្ចក់ ក្អក់ក្បៀល្ងើ សឹងល្អប្រពៃស្រេចហើយនៃ បុណ្ណកយក្ស ស្ទុះផែនប្រួចប្រួចឡើងលើខ្នងមនោម័យ ដៃកាន់រំពាត់ពាត់ទៀនថា ហឹះៗ ក្សណនោះ មនោម័យ ស្ទុះហិចហោះអណ្តែតត្រសែតទៅនាកណ្តាលអាកាស បុណ្ណកយក្សបរសេះទៀបហៀបទឹងដល់ភ្នំអញ្ជនបពិត ព្រួសព្រួត្រសេះទៀនថាកឹកៗ បុណ្ណកយក្សស្រែកថា បាយ៉ាបជ័យបានលាភប្រាកដក្នុងថ្ងៃនេះឯងមិនទេឡើយ ម៉្លោះហើយក៏បរសេះ ហោះរៀងៗ ទៀប ហៀបទឹងដល់កំពូលភ្នំនោះក្បែរ ព្រួសព្រួនាងច្រៀងនោះតែងៗ ម្នាក់ឯងនោះដ៏

មានសំឡេងនោះស្រទន់ ជាផ្អែមល្ហែមពិរោះដូច្នោះហើយ បុណ្ណកយក្ខ មិនអាចដើម្បីនឹងទប់ទល់ ដំកល់អាត្មាភាពនោះបានឡើយ ហេតុតែបុណ្ណកយក្ខនឹងបាននាងឥរន្ទតី ជាភរិយាអំពីកាលជាតិមុនមិញ បុណ្ណ-កយក្ខ កាលបើបានឮពាក្យនាងឥរន្ទតី ដង្ហោយស្រែកច្រៀងលើកំពូលភ្នំនោះដូច្នោះហើយ បុណ្ណកយក្ខ ព្រឺព្រួច ក្រលួចអស់អង្គស្រយ៉ង់ហឫទ័យ មិនអាចដើម្បីនឹងបរសេះមនោម័យឲ្យវៀររួស បង្ហួសទៅនោះបានឡើយ ទើបបុណ្ណកយក្ខញាក់ក ទ្រាក់សេះមនោម័យឋរបង្វិលវិលមកកាន់នាងឥរន្ទតី បុណ្ណកយក្ខស្រដីទៅកាន់នាងឥរន្ទតីថា ភទ្ទេ ម្នាលនាងអើយ នាងកុំច្រៀងពេកឡើយ កុំច្រៀងពេកខ្លាច ពស្មកក ហៃនាងប្អូនស្រីសំឡាញ់បងអើយ នាងអើយកុំនាងបារម្ភឡើយ ណានាបងឯង នឹងទៅស្វែងរកថ្លើមចៅពិធូរអ្នកប្រាជ្ញនាំមកឲ្យដោយចំណង់ នៃចិត្តម្តាយនាងហោង បុណ្ណកយក្ខ មិនស្រដីទៅឡើយលោមនាងឥរន្ទតី សូត្រជាបទព្រះគាថា៖ អស្សាស ហោស្សាមិតេ បតី ថាម្នាលនាងមានវង់ភក្ត្រល្អ ឥតដំណេះគេះដៀល ភ្នែកនៃអ្នកដង់តាំងឡាយឡើយ ចូរនាងមានដង្ហើមចេញចូលឲ្យធូរស្រណុកសុខសប្បាយ ណានាបងឯង នឹងជាស្វាមីនៃនាងឯងហោង ហើយបងនឹងទៅនាំថ្លើមចៅពិធូរអ្នកប្រាជ្ញ មកឲ្យដោយចំណង់ចិត្តម្តាយនាងហោង បុណ្ណកយក្ខស្រដីនូវប្រការអម្បាលនោះហើយ គិតក្នុងចិត្តថា អញនឹង

ចាប់នាងនេះបញ្ជិះលើសេះបរនាំទៅ ដោយនូវគ្រាកាលឆាប់ហោង បុណ្ណកយក្ខគិតអំពាលនោះហើយ ចុះអំពីលើខ្នងសេះមនោម័យប្រពៃ ស្អាតសីហនាទ គគាតដើរចូលទៅ ចាប់ដៃនៃនាងឥរន្ធតី ទើបនាងឥរន្ធតីយល់ បុណ្ណកយក្ខទឹងចាប់ដៃនាងដូច្នោះ នាងផាត់ខ្លួនចេញ នាងស្រដីថា ហៃហៅមាណពអើយ រីអញនេះមិនជាស្រី សើរើរើររាយ ស្រើបស្រាលសរសេទ់សាធារណមកប្រៀងលេង ដោយនូវចិត្តសប្បាយ ពយមាយគាស្រវកាសពីកិច្ចការម្តាយឪពុកឲ្យបានតែសុខក្នុងព្រៃនេះឡើយ ហៅអើយ រីអញនេះជាព្រះរាជបុត្រនៃមហាក្សត្រាធិរាជមួយព្រះអង្គទ្រង់នាម ហៅព្រះបាទពិរុណនាគរាជ សោយរាជ្យសម្បត្តិស្ថិតនៅឯពិភពនាគនាយ រីឯព្រះវរមាតាអញ ទ្រង់ព្រះនាមហៅនាងវិមលាទេវី ដ៏ជាព្រះអគ្គមហេសី ធំនៃព្រះមហាក្សត្រាធិរាជនោះឯង ថា ហៃហៅមាណពកំឡោះអើយ ចាប៉ើហៅចង់ប្រាថ្នាអញជាភរិយានៃហៅ មកយើងនាំគ្នាទៅកាន់ព្រះអង្គទាំងពីរឯនាយ ចាប៉ើព្រះអង្គទាំងពីរសព្វព្រះរាជហឫទ័យហើយ ព្រះអង្គប្រដាប់ប្រដាការអាពាហ៍ពិពាហ៍ជាឧត្តមផ្សំអញនឹងហៅជាប្តីប្រពន្ធនឹងគ្នា ។ ក្សណៈនោះបុណ្ណកយក្ខស្តាប់ពាក្យនាងឥរន្ធតី ស្រដីដូច្នោះហើយ ក៏មានចិត្តនោះត្រេកអរស្មោះសរ ទឹងនាងឥរន្ធតីពេកហោង ម្លោះហើយបុណ្ណកយក្ខលើកនាងឥរន្ធតី បញ្ជិះលើខ្នងសេះមនោម័យ បរបំផាយទំលាយទឹកនព្វមហាសមុទ្រប្រាកដ

ជ្រែកចុះទៅកាន់ពិភពនាគនាយ កាលបើបានដល់ហើយ នាងឥរន្ទតីនោះចុះទៅអំពីលើខ្នងសេះមនោម័យមួយអន្លើប្រពៃស្អាត  សីហនាទគគាត ចូលទៅកាន់ស្ថានលំនៅនៃនាងឯង  រីបុណ្ណកយក្ខនោះសោតចងសេះមនោម័យមួយអន្លើហើយ  បុណ្ណកយក្ខឡើងទៅកាន់ព្រះបាទវរុណនាគរាជស្រេចថ្វាយបង្គំប្រណម្យទូលសូត្រជាបទព្រះគាថា ញាតាវរ  វរោ សុណោហិ មេ ញាតកញ្ញិរំ ៗ បពិត្រព្រះអង្គដ៏ជាធំឧត្តមប្រសើរអើយ សូមទានព្រះអង្គទទួលយកមាសប្រាក់កែវកង  ពៃទូរ្យរតន៍  ខ្ញុំប្រុសស្រី ដំរីសេះរទេះគោក្របីជាទ្រព្យខាន់ស្លា  សូមទានព្រះអង្គទ្រង់មេត្តាជាក្រយាសំពះនៃខ្ញុំហោង  បពិត្រព្រះអង្គអើយ  ខ្ញុំមិនប្រាថ្នារបស់អ្វីមួយដទៃបីក្រៃ  ទឹងនាងឥរន្ទតី  ខ្ញុំសូមនាងជាភរិយានៃខ្ញុំ  សូមទានព្រះអង្គផ្សំខ្ញុំនឹងនាងជាប្ដីប្រពន្ធផងគ្នាហោង ៗ បពិត្រអើយ  កាលនោះព្រះបាទវរុណនាគរាជស្ដាប់ពាក្យបុណ្ណកយក្ខ  ស្រដីដូច្នោះហើយ  មានព្រះបន្ទូលទៅកាន់បុណ្ណកយក្ខថា  ហៃពៅមាណពអើយ  ថាបើពៅចង់បាននាងឥរន្ទតីកូនស្រីនៃអញហើយ  ចូរពៅចាំអញទៅគិតនឹងនាងវិមលាទេវីជាម្ដាយនៃនាងឥរន្ទតី  បើគេចូលចិត្តមិញ  ក៏បាន  លើកបើគេពុំចូលចិត្តឡើយនោះពៅខាន  ពុំបានឡើយ  ហៃមាណពពៅអើយ  រីច្បាប់មេបាចាស់ទុំលោករមែងតែងដាក់ទុកកូនពៅឲ្យមានប្ដីមានផ្ទះសំបែង  តែងគិតគស់មេបាប្រៀនលាន កល្យាណមិត្រសំឡាញ់ផងថា  បើពុំបានគិតឡើយ នៅ

ផងគ្នាទៅ លុះគជាមិនល្អ លុះគបើគេតជាជំលោះ ប្រកែកដណ្ដើមអំពីសន្ដានញាតិផៅទៃ ។ ហើយកទឹងកើតជាបន្ទោស ចុះចយឯក្រោយវិញហោង ព្រះបាទពរុណនាគរាជបន្ទូលនឹងបុណ្ណកយក្ខម្ល៉េះហើយ ស្ដេចលីលាចូលទៅក្នុងព្រះរាជមន្ទីរ ស្ដេចគង់វាងនាងវិមលាទេវី ថាហៃនាងវិមលាទេវី ប្អូនស្រីសំឡាញ់បងអើយ ឥឡូវនេះ មានមាណព ១ មកអំពីឯណា ក៏មិនដឹងឡើយ មកសូមនាងឥរន្ទតីកូនស្រីសំឡាញ់យើង ឥឡូវនេះ តើនាងនឹងគិតម្ដេចទៅ ស្ដេចថាបើដោយចិត្តអញហើយ អញនឹងបង្ហើរនាងឥរន្ទតី កូនស្រីសំឡាញ់យើងឲ្យទៅទៅមាណពនោះឯង រីឯចិត្តនាង តើនាងនឹងឲ្យគេឬទេនាង បើនាងឲ្យក៏នាងឲ្យ បើនាងមិនឲ្យក៏នាងថាមកឲ្យដឹង នាងវិមលាទេវីស្ដាប់ហើយ ក្រាបថ្វាយបង្គំប្រណម្យទូលថា បពិត្រព្រះសម្មតិទេពមហារាជអើយ កុំថាតែទៅមាណពនោះ យកទ្រព្យទាំងអម្បាលនោះមកឲ្យ ហើយសូមនាងឥរន្ទតី គឺកូនសំឡាញ់ខ្ញុំនឹងយកជាប្រពន្ធ សូម្បីទៅមាណពនោះយកមាសប្រាក់កែវកងសព្វពិព័ធរតនមកដាក់ដារពេញទាំងពិភពនាគនេះក្ដី ក៏នឹងមិនឲ្យនាងឥរន្ទតី កូនស្រីសំឡាញ់ខ្ញុំជាប្រពន្ធឡើយ បពិត្រព្រះសម្មតិទេពមហារាជអើយ ថាបើមាណពនោះមានឫទ្ធិអានុភាពទៅនាំថ្មើមទៅពិជូរអ្នកប្រាជ្ញមកដោយនូវធម៌ ដល់ពិភពនាគនោះ ក៏ខ្ញុំនឹងឲ្យឥរន្ទតីទៅជាប្រពន្ធទៅមាណពនោះហោង ខ្ញុំមិនប្រាថ្នាទ្រព្យរបស់

អ្វីដទៃបៃក្រែនឹងថ្លើមចៅពិធូរអ្នកប្រាជ្ញឡើយ ខ្ញុំយកតែថ្លើមចៅពិធូរជាខាន់ស្លាក្រយាសំពះខ្ញុំហោង ព្រះបាទពិរុណនាគរាជស្ដាប់ហើយស្ដេចលីលាចេញទៅអំពីព្រះរាជមន្ទីរហើយ មានព្រះបន្ទូលទៅនឹងបុណ្ណកយក្ខថាហៃចៅមាណពអើយ ឥឡូវនេះ នាងវិមលាទេវីស្រដីថា កុំចាំទៅយកទ្រព្យតាំងអម្បាលនោះមកឲ្យឡើយ ពោះបើយកមាសប្រាក់រតនាមកចាក់ដាក់ឲ្យពេញតាំងពិភពនាគនេះក្ដី ក៏នាងមិនឲ្យនាងឥរន្ទតីកូនស្រីសំឡាញ់នាងជាប្រពន្ធទៅឡើយ ថាបើទៅមានឫទ្ធីអានុភាពអាចទៅនាំថ្លើមចៅពិធូរអ្នកប្រាជ្ញមកដោយនូវធម៌ បានដល់ពិភពនាគនេះហើយ នាងនឹងឲ្យកូនស្រីសំឡាញ់នាងទៅហោង បុណ្ណកយក្ខស្ដាប់ហើយទះដៃផាំងកាំងក្រពាត្លើយថា អៃយ៉ាំអញគិតស្មានជាទ្រព្យរបស់អ្វី ៗ នោះយល់ជាគម្របន្តិចហ៎ះ ថាបើប្រាថ្នាថ្លើមចៅពិធូរអ្នកប្រាជ្ញនោះរាងាយហ៎ះឯងអេះ កុំថាចៅពិធូរអ្នកប្រាជ្ញតែមួយតែពីរឡើយ ពោះបើចៅពិធូរអ្នកប្រាជ្ញនោះជារយជាពាន់ ជាម៉ឺន ជាសែនក្ដី ក៏ខ្ញុំនឹងទៅចាប់ចៅពិធូរអ្នកប្រាជ្ញនោះយកមកថ្វាយព្រះអង្គឥឡូវនេះឯង បពិត្រមហារាជអើយ រចៅពិធូរអ្នកប្រាជ្ញនោះ តើគាត់តូចឬធំ សឬខ្មៅ ធាត់ឬស្គម គាត់ទាបឬខ្ពស់ សក់គាត់តើវែងឬខ្លី សំដីគាត់នោះរឹងឬទន់ ក៏ខ្ញុំនឹងទៅសួររកក្រែងអ្នកស្រុកនោះគេប្រាប់ខ្ញុំមិនជាក់ ជាចៅពិធូរអ្នកប្រាជ្ញនោះឡើយ ៗ ហើយខ្ញុំទៅចាប់ឯអ្នកខ្មៅថាជាអ្នកប្រាជ្ញ ល្គកខ្ញុំអាចនាំមកថ្វាយព្រះអង្គ

ហើយ ព្រះអង្គទ្រង់មានព្រះបន្ទូលថា ឱចៅមាណពអើយ នេះមិនគឺ ចៅពិគូរអ្នកប្រាជ្ញទេឡើយ ប្រសិនបើដូច្នោះវិញហើយ វាអសារឥតការ ហោង នាងឥន្ទូតីអសារមិនបានជាភរិយាខ្ញុំឡើយ ដូច្នោះហើយ សូម សម្តេចមហាពជ្រប្រាប់ខ្ញុំឲ្យបានជាក់ច្បាស់ប្រាកដហោង ៗ

(នៅមានត)

## កំឡាំងសាមគ្គី (កាព្យពាក្យ ៤)

ការរួបរួមគ្នា កើតជាកម្លាំង កំឡាំងនោះខ្លាំង មាំមួនមហិមា គ្មានជនណាអាច ប្រមាថគត់ យាយីពាធា បានដូចបំណង ។ បើនៅតែឯង គ្មានជនណាផង រួមជាមិត្រត្រង់ សត្រូវមើលងាយ សះសៃសូត្រមួយ ខ្យល់បក់ផាត់ផាយ ផាត់ធ្លាក់ទៅឆ្ងាយ ហេតុគ្មានពំនឹង ។ គ្មានញាតិពំនាក់ ពឹងពាក់ពុំរឹង ពុំបានរឹងប៉ឹង ដាច់ឆាប់ពេកក្រៃ សរសៃសូត្រច្រើន ក្រវេនពួតដៃ ពួតព័ទ្ធវេញផ្នែ កាខ្សែជាខ្សែ ។ ពួរតូចពួរធំ ជាក់មាំពូកែ ឥតមានប្រែប្រួល បែរបែកទៅផ្លាស ស្វិតក្រៃលែងស្វិត ជាប់មិនវិនាស យកទៅប្រើប្រាស ដូចក្តីប្រាថ្នា ។ មិនងាយដាច់ដោច របោចទៅណា ចងអ្វីនានា ជាប់ពេកខ្លាំង ទោះសត្វដំរី ធំក្រៃចម្បង រើពុំរួចផង ហេតុវេញច្រើនថ្នុង ។ នេះប្រៀបដូចចិត្ត វេញស្និទ្ធជិតស្អុង ពីដើមដល់ចុង ស្មោះស្ម័គ្រពេកពន់ ប្រសើរល្អណាស់ ទោះកិច្ចស្រាលធ្ងន់ និងអាចរែកពន់ ទៅបានសព្វឋាន ។ ទោះខ្លាំងសត្រូវ ចង់ចូលរុករាន រុកចូលទន្ទ្រាន ពុំបានដូចប៉ង កំឡាំងសាមគ្គី ខ្លាំងក្រៃកន្លង ខ្លាំងលើសអ្វីផង ដែលហៅថាខ្លាំង ។ ផលនៃសាមគ្គី អាចឲ្យតតាំង តយុទ្ធប្រឆាំង ឈ្នះសត្រូវបាន ហើយនាំបានសុខ ផុតទុក្ខរំពាន រុងរឿងក្សេមក្សាន្ត ទៅអនាគត ។ ចូរក្មេងទាំងឡាយ រក្សាឲ្យគត់ ទុកឲ្យម៉ត់ចត់ នូវធម៌សាមគ្គី ធម៌នោះប្រពៃ ថ្លាថ្លៃពេញទី គ្មានអ្វីជាទី នៅនាលោកិយ ។

ផេង-ជ្រីវ

**ផ្នែកអក្សរសាស្ត្រ**

អក្សរសាស្ត្រខ្មែរ ខ្មែរត្រូវថែថ្នម
ឲ្យបានខ្ជាប់ខ្ជួន គង់វង្សគង់មត់
ព្រោះអក្សរជាតិ គោលជាតិប្រាកដ
អក្សររលត់ ជាតិក៏រលាយ

ប. ៣.

# ចម្បាំងក្នុងលោក

(វិចារណកថា)

រៀបរៀងដោយ ប៊ូ-ឆរិន្ទ
សង្កាត់លេខ៥ ក្រុងភ្នំពេញ

ខ្ញុំបានអានអត្ថបទមួយរបស់លោក ហ៊ែល-សុំផា ប្រធាននៃសមាគមអ្នកនិពន្ធខ្មែរ ។ អត្ថបទនោះស្ដីអំពីចរិយាសាស្ត្រ តទល់នឹងវិទ្យាសាស្ត្រដែលផ្សាយក្នុងទស្សនាវដ្ដីអ្នកនិពន្ធខ្មែរ ឆ្នាំទី ១ លេខ ២ ទំព័រ ៣៦ . . . ខ្ញុំមានចិត្តចាប់អារម្មណ៍នឹងអត្ថបទរបស់លោកនេះ យ៉ាងខ្លាំង ហើយខ្ញុំមានយោបល់ស្របតាមលោកដែរ ដោយហេតុខ្ញុំធ្លាប់បានពិចារណាកររកហេតុផលក្នុងបញ្ហាចម្បាំងនេះមកពីមុន ៗ ខ្លះដែរ ។ ខ្ញុំអត់ទ្រាំពុំបាន ទើបខ្ញុំសរសេរអំពីយោបល់ខ្លះរបស់ខ្ញុំចំពោះបញ្ហាថា:

«បើវិទ្យាសាស្ត្រ មិនមែនជាបុព្វហេតុនៃចម្បាំងទេ តើមានធម្មជាតិ

អ្វីផ្សេងទៀត ជាបុព្វហេតុនៃចម្បាំងទៅវិញ?

មុននឹងដោះស្រាយប្រស្នាខាងដើមនេះឲ្យបានងាយយល់នោះ ខ្ញុំសូមធ្វើអត្ថាធិប្បាយបញ្ជាក់អំពី

## ធម្មជាតិចម្បាំង

ក) ដោយឧទាហរណ៍យ៉ាងខ្លី – មនុស្សទាំងពួងសឹងធ្លាប់បានដឹងឮឬបានឃើញច្បាស់ទាំងភ្នែកខ្លួនហើយនូវចម្បាំងក្នុងប្រទេសឬនៅក្រៅប្រទេសសព្វថ្ងៃនេះ ។

ដូចជាកាលខ្លួនខ្ញុំនៅពីក្មេងតូចធ្លាប់បានមើលល្ខោនបាសាក់ ខ្ញុំខ្លាចស្ញប់ស្ញែងត្រង់ឆាកចម្បាំងរវាងមនុស្សនឹងយក្ស ដោយឃើញមុខយក្សនោះកាចក្រក់ណាស់ នាំឲ្យខ្ញុំខ្លាចជាខ្លាំង ថែមទាំងឮសម្លេងយក្សរ៉ៃស្រែកឡូឡាទៀត ខ្ញុំរិតតែតក់ស្លុតចង់រត់ចេញពីរោងល្ខោន ប៉ុន្តែ ម៉ែគាត់ចាប់ដៃខ្ញុំជាប់ ។ តមកក្រោយទៀត ខ្ញុំកាន់តែធំខ្លួនដឹងក្តីគ្រាន់បើហើយ ខ្ញុំឮចាស់ទុំនិយាយគ្នាពីបារាំងច្បាំងនឹងសៀម ពីជប៉ុនច្បាំងនឹងអាមេរិក ។ គង់ទ័ពទាំងសងខាង មានស្លាប់បាត់បង់ជីវិតអស់ជាច្រើន ព្រាត់ប្រាស់ម៉ែឪប្រពន្ធកូន ។ ខ្ញុំឮដូច្នេះរិតតែភិតភ័យជាងមើលល្ខោនទៀត ព្រោះល្ខោននោះច្បាំងគ្នាគ្មានស្លាប់ទេ គ្រាន់តែគេធ្វើត្រាប់ចម្បាំងប៉ុណ្ណោះ ។

ឧទាហរណ៍សង្ខេបប៉ុណ្ណោះ ល្មមឲ្យអស់លោកជ្រាបច្បាស់ហើយ

អំពីចម្បាំង ខ្ញុំមិនបរិយាយឲ្យពិស្ដារទៅទៀតទេ ព្រោះយើងអាចយល់បានដោយងាយថា ចម្បាំងគឺជាការប្រើកម្លាំងមនុស្ស ដើម្បីដណ្ដើមយកជ័យជំនះគ្នាទៅវិញទៅមក ដោយប្រើយុទ្ធោបករណ៍ ឬប្រើយុទ្ធោបាយផ្សេង ៗ ពីគ្នា ។ បើទុកជាគេប្រើដុំថ្ម-ធ្នូ ឬប្រើកាំភ្លើង គ្រាប់បែកបរមាណូជាដើម ក៏រួមហៅថា ចម្បាំងដែរ ។

១) ដោយឧទាហរណ៍ដ៏ពិស្ដារ – បើយើងគ្រាន់តែយល់អំពីចម្បាំងហើយនៅស្ងៀមឈឺងត្រឹមហ្នឹងទៅ នោះយើងមិនអាចនឹងបានដឹងនូវបុព្វហេតុនៃចម្បាំងទេ ។ ដូច្នេះ តពីនេះទៅ យើងត្រូវប្រើវិចារណញ្ញាណស្រាវជ្រាវពិររកនូវវត្ថុដែលជាបុព្វហេតុរបស់ចម្បាំង ឲ្យឃើញច្បាស់លាស់ ។

## បុព្វហេតុនៃចម្បាំង

តាមទ្រឹស្ដីរបស់បណ្ឌិតពួកខ្លះ យល់ឃើញថា «ចម្បាំងកើតមានឡើងនោះ មកតែពីការខ្វះខាតគ្រឿងឧបភោគសម្ភារៈ ពីដណ្ដើមកស្កុតារ ពីការបែងចែកលាភសក្ការៈមិនស្មើភាគគ្នា ទើបបានជាមានអស្មិមានៈប្រកាន់វណ្ណៈ ប្រកាន់បក្សពួករវាងគ្នាឯង ក្នុងប្រទេសជាមួយគ្នាក៏មាន រវាងអន្តរជាតិ នៅប្រទេសនានាក៏មាន ។ «ទ្រឹស្ដីបែបនេះហៅថា «សេដ្ឋបច្ច័យនិយម» ( Séterminisme économique ) ។

តាមការសង្កេតរបស់ខ្ញុំដ៏ទន់ខ្សោយ ខ្ញុំយល់ឃើញថា : ចម្បាំង

មាន ២ បែប គឺចម្បាំងធំ ១ បែប ចម្បាំងតូច ១ បែប ។ ចម្បាំងធំសំដៅយកការប្រហារគ្នាដោយគ្រឿងសស្ត្រាវុធយុទ្ធភ័ណ្ឌ ទោះជាចម្បាំងនឹងជាតិគ្នាឯងក្នុងប្រទេសជាមួយគ្នាក្តី ទោះចម្បាំងនឹងជាតិដទៃ ប្រទេសដទៃក្តី ។ ចម្បាំងធំនេះ មិនមែនកើតមានឡើងឯង ៗ តែម្តងទេ គឺតែងកើតមានឡើងពីចម្បាំងតូចជាមុន ។ ចម្បាំងតូចសំដៅយកការប្រើពាក្យសំដីឬក៏ការផ្សាយតាមសារពត៌មាន ដូចកាសែត ខិតប័ណ្ណជាដើម ។ ប៉ុន្តែគេយើងរាល់គ្នាភ្លេចខ្លួន មិនបានជាចាប់ភ្លឹកនឹកនាដល់ចម្បាំងតូចនេះផងសោះ បែរតែនាំគ្នាបើកភ្នែកធំ ៗ សម្លឹងមើលទៅដល់ចម្បាំងធំតែម្តង ហើយព្រឺខ្លួនក្រញែងស្លាលាន់មាត់ថា „អែយ៉ា ! បរមាណូ ! ” តាមពិត យើងមិនគួរបំភ្លេចចម្បាំងតូចចោលទេ បើបំភ្លេចចោលហើយមុខជាកើតចម្បាំងធំមិនខាន សឹងមានសុភាសិតបុរាណខ្មែរថា « អាតូចបង្ខូចអាធំ ភ្លើងឆេះពីសម្រាម » ។

រឿងចម្បាំងតូចនេះ ក្លាយដូចប្រទេសកម្ពុជាយើង តាំងពីបានឯករាជ្យបរិបូណ៌មក ធ្វើជាប្រទេសអព្យាក្រឹតមកជាង ១០ ឆ្នាំហើយ បែរតែមានចម្បាំងតូចលេចចេញមកពីមហាប្រទេសខ្លះរាល់ថ្ងៃ ។ ចំពោះមកលើប្រទេសយើង ទាល់តែអស់លោកមេទ័ពខេមរកូមិន្ទយើងក្តៅក្រហាយជាខ្លាំង ក្រាបទូលអង្វរសុំព្រះបរមានុញ្ញាតពីសម្តេចព្រះប្រមុខរដ្ឋចេញធ្វើចម្បាំងធំ ប៉ុន្តែ អង្គសម្តេចឪយើង ទ្រង់ជាអគ្គមគ្គុទ្ទេសដ៏ឆ្នើម

ប្រកបដោយគតិបណ្ឌិត ទ្រង់ឈ្វេងយល់ផលអាក្រក់ដែលកើតមានពីចម្បាំងធំនោះ បើទុកជាយើងច្បាំងឈ្នះគេ ក៏គង់តែស្លាប់កូនចៅព្រះអង្គដែរ ហេតុនេះ ទ្រង់ចេះតែខំរកមធ្យោបាយដោះស្រាយដោយសន្តិវិធី ដើម្បីនឹងរំលត់ចម្បាំងតូចឲ្យអស់ទៅ ៗ តទៅមុខ ប្រសិនបើចម្បាំងតូចមិនរលត់ទេ នៅតែរាលដាលដល់ទៅកើតចម្បាំងធំទៀតនោះ មិនមែនធ្លាក់កំហុសលើសម្តេចឪយើងទេ មុខជាធ្លាក់កំហុសទៅលើមហាប្រទេសណាដែលមិនព្រមឈប់ធ្វើចម្បាំងតូច មកលើប្រទេសខ្មែរនោះតាំងស្រុង រឿងចម្បាំងតូចនេះ អ្នកសង្កេតការអន្តរជាតិបានយល់ច្បាស់ណាស់មកហើយ ៗ

គួរឲ្យយើងឆ្ងល់ដែរថា តើចម្បាំងតូចនោះ គឺជាអ្វី? យើងត្រូវឆ្លើយថា ចម្បាំងតូចនោះ គឺជាសង្ឃ័ដ (ការប៉ះទង្គិចគ្នា ឬការប្រឆាំងគ្នា) ៗ ឧទាហរណ៍ដូចជាការចោទប្រកាន់គ្នាដោយពាក្យសំដី ឬដោយលាយលក្ខអក្សរ ៗល។ សង្ឃ័ដនេះមិនទាន់ដល់ថ្នាក់វាយប្រហារគ្នាដោយគ្រឿងសស្ត្រាវុធទេ គឺគេគ្រាន់តែចាក់ដោតតិះដៀលគ្នាដោយសំដីឬដោយតួអក្ខរប៉ុណ្ណោះ ដែលយើងធ្លាប់និយាយគ្នាមកហើយថា « សង្គ្រាមប៉ាកកា » ៗ

ប៉ុន្តែ មានមនុស្សភាគច្រើនសន្និដ្ឋានថា សង្ឃ័ដនេះពុំមែនជាចម្បាំងទេ ព្រោះគេឥតសម្លាប់អ្នកណាសោះ គេគ្រាន់តែធ្វើឲ្យមានការ

ទន្ទិចដោយពាក្យសំដីប៉ុណ្ណោះ ៗ ការធ្វើនេះមិនមែនជាបុព្វហេតុបណ្ដាលឲ្យក្ស័យជីវិតមនុស្សទេ ៗ សេចក្ដីសន្និដ្ឋានបែបនេះ ឃ្លាតឆ្ងាយណាស់ ពាត់ថាមិនយល់បច្ច័យនៃចម្បាំងតូចនោះឡើយ ៗ

តាមការណ៍ពិត ការប្រឆាំងគ្នាដោយពាក្យសំដីនោះឯងហើយជាមូលហេតុនៃចម្បាំងធំ ៗ បើចម្បាំងតូចកើតមានកាន់តែច្រើន ៗ ឡើងហើយ អាចបណ្ដាលឲ្យផ្ទុះទៅជាចម្បាំងធំបាន ៗ ចម្បាំងធំត្រូវប្រើយុទ្ធោបករណ៍ សង្គ្រាមក្នុងផែនការសម្ភារៈ (Conlit dans le plan matériel )

ក្នុងប្រយោគដែលគេធ្លាប់និយាយគ្នាថា «យើងត្រូវតែតស៊ូ ដើម្បីធ្វើឲ្យកើតមានសន្តិភាព» ប្រយោគមួយទៀតថា «យើងត្រូវតែធ្វើវិទ្ធង្សនាប្រឆាំងនិងពួកយុទ្ធិកៈអ្នកបង្កបង្កើតសង្គ្រាមឲ្យបរាជ័យទៅ ដើម្បីឲ្យសន្តិភាពបានឈ្នះអសន្តិភាពក្នុងសកលលោកជាស្ថាពរ» ៗ ប្រយោគទាំង ២ ឃ្លានេះ ឥតបានន័យថាជាអ្វីសោះ បានន័យប្រហែលគ្នានឹងថា សម្លាប់ដើម្បីឲ្យរស់ ៗ សង្គ្រាមនៅតែមានដដែល ៗ សន្តិភាពបានតែមួយខណៈប៉ុណ្ណោះ ក៏រលាយបាត់ទៅវិញ ៗ

បើដូច្នេះ តើយើងត្រូវធ្វើដូចម្ដេច ទើបអាចនឹង

## បំបាត់ចម្បាំងឲ្យអស់រលីងពីសកលលោកបាន ?

ប្រស្នានេះ បើតាមយោបល់ដ៏ស្ដួចស្ដើងរបស់ខ្ញុំ ៗ ជឿទុកជាមុនថា ការធ្វើចម្បាំងដោយប្រើយុទ្ធោបករណ៍នោះ ពុំមែនជាការបំបាត់

ចម្បាំងឲ្យអស់រលីងពីសកលលោកទៅទេ ។ បើយើងចង់ឲ្យអស់ចម្បាំងនោះ លុះតែយើងលះបង់ចោលនូវគំនិតជាកលោបាយ ដែលប្រឆាំងនឹងគំនិតរបស់ពួកយុទ្ធកៈអ្នកបង្កសង្គ្រាម គឺថា យើងត្រូវរកមធ្យោបាយធ្វើឲ្យមនុស្សទាំងអស់ ក្នុងសកលលោកមានមនោគតិសុចរិតស្លូតត្រង់ទៅវិញទៅមករកគ្នា ។ បើនិយាយតាមព្រះពុទ្ធោវាទថា ចម្បាំងកើតពីមនុស្សម្នាក់ ៗ រួបរួមគ្នាទៅជាយោធាជាកងទ័ព បើមនុស្សម្នាក់បំបាត់កាមតណ្ហាឲ្យអស់ពីចិត្តខ្លួនចេញ ទើបបានផុតរលត់ចម្បាំងក្នុងលោក ទោះចម្បាំងត្រជាក់ក្តី ក្តៅក្តី ។

---

ព្រះរាជាអង្គណា មានពេទ្យរាជគ្រូ នឹង
មន្ត្រី សុទ្ធតែជាអ្នកបញ្ចោរ ព្រះរាជា
អង្គនោះ នឹងស្គមព្រះសរីរៈថយគុណ
ធម៌ នឹងអន្តរាយឃ្លាំងដោយឆាប់រហ័ស

ហិតោបទេស

# វចនានុក្រមសំស្ក្រឹត-ខ្មែរ

ព្រះមហា ចាំង-ខាត់ រៀបរៀង

(តមក)

---

**អធ្វន៑** បុំ. អធ្វា ផ្លូវ ដំណើរ ចំងាយ ដំណើរនឹងពេលដំណើរ ។ អធ្វគ ដែលទៅតាមផ្លូវ ដែលទៅនឹងផ្លូវ បុំ. អ្នកដើរកំសាន្ត អ្នកដំណើរ ។ អធ្វគវើ គុ. ដែលកាន់យកទៅជាអ្នកព្រោះឧបស្គ ដែលជាប៉ូងនិយោស ។ អធ្វទគិន បុំ. អ្នកបង្ហាញផ្លូវ អ្នកនាំផ្លូវ មគ្គុទ្ទេសក៍ ។

**អធ្វន្យ** បុំ. អ្នកដំណើរ ។

**អធ្វរ** បុំ. ទេវាល័យ យញ្ញពិធី ។ – គ គុ. ដែលតាំងទៅដើម្បីយញ្ញពិធី ។

**អធ្វរ្យុ** បុំ. ព្រាហ្មណ៍អ្នកធ្វើយញ្ញពិធី ។

**អធ្វស្ត** គុ. ដែលមិនអន្តរាយ (ដែលមានអន្តរាយមិនមាន) ។

**អធ្វាន** បុំ. អធ្វា ផ្លូវ ។

**អធ្វាន** បុំ. អធ្វាន កិរិយាមិនមានសូរ លទ្ធិមូគៈ ។

**អន៑** មើល អ ២ ។

**អន៑** ធាតុ. អនីតិ អានយតិ – ដកដង្ហើម ។

**អន** សព្វនាម មើល ឥទម៑ ។

**អន** បុំ. ខ្យល់ដកដង្ហើម ។

អនំឝ គុ. ដែលមានចំណែកមិនមាន (មតិក) ។

អនក្ដិ មើល អក្ខិ ។

អនក្សជិ ដែលបេះបាស្កាមិនមាន ដែលមិនបេះបាស្កា ។

អនក្សត្រគណ គុ. ដែលមានពួកនក្សត្រមិនមាន ។

អនក្សរ គុះ ដែលចេញសំឡេងមិនមាន ដែលគថ្លង់ ។ ក្សរមិ អនក្រ. វិ. ដោយឥតមាត់ក ។

អនក្សិគត គុ. ដែលមានបត្តាក្នុងភ្នែកមិនមាន ។

អនគ្ន គុ. ដែលមានអាក្រាតមិនមាន ដែលមិនរនល ។

អនគ្និ គុ. ដែលមានភ្លើងមិនមាន ដែលមិនរក្សាភ្លើង ។ – ក គុ. ដែលមានភ្លើងមិនមាន ។ - ទត្ន បុំ. ពហុ. ឈ្មោះព្រាហ្មណ៍ ។

អនឃ គុ. ដែលមានប្រលាក់មិនមាន ដែលឥតទោស ដែលមិនអន្តរាយ ដែលឥតព្រួយ ។ អនឃា ស្រី. ឈ្មោះទន្លេ ។

អនង្កុរិត គុ. (ពុកមាត់) ដែលមិនដុះ ។

អនង្កុឝ គុ. ដែលមានកង្វេមិនមាន ដែលមិនព្រមស្ដាប់កង្វេ (ដែលមិនព្រមទៅតាមហ្វា ដែលប្រើកង្វេ បង្គាប់) ។

# រឿងអាប៊ូលហ្វ៉ាអ៊ីរីស៍

(ក)

---

លោក ក៏យ-ល្អុត តំណាងរាស្ត្រ

ប្រែរៀបរៀង

អន់ចិត្តខ្លាំងនឹងសេចក្ដីព្រហើន នៃបុគ្គលចំឡែកនេះ ទាសាម្នាក់អត់ទ្រាំពុំបាន ស្ទុះទៅវាយដាល់ តែវាសំឡឹងមកទាសានោះធ្វើសញ្ញាដោយញាក់មុខប្រាប់ រួចឈានដៃមកក្របួចស្មា ចាក់នឹងក្រចកវាទាសានោះស្លាប់ភ្លាមទៅ ។ ឃើញដូច្នោះ កម្មករសំពៅទាំងអស់ ខ្លះកាន់ដាវ ខ្លះកាន់លំពែង ឈ្លួសព្រួតគ្នាទៅវាយកាប់ចាក់មនុស្សកំណាចតែសាច់វារឹងដូចពេជ្រឥតរលាត់អ្វីបន្តិចសោះ ។ ដាវលំពែងខ្លះបាក់ ខ្លះរមួលមូរមុខ ៗ វាសងសឹកមកវិញ លោតសំដៅទៅទាសាម្នាក់ ដែលននះនរនោចជាងគេ ចាប់បានក្រញាំហែកហួរខ្ទិចខ្ទីស្លាប់ភ្លាម ចំពោះមុខយើងតែម្ដង ដូច្នេះយើងទាំងអស់គ្នាមិចក្នុកលោតព្រមគ្នា ទៅតាមពេមបម្រុងនឹងប្រានវាទម្លាក់ទឹក តែវាឈរនឹងថ្កល់ ឥតកម្រើកបន្តិចបន្តួចសោះវាមានជើងដៃសរសៃរឹងអស្ចារ្យផង ក្រចកខុប ៗ របស់វាមុតដូចដែកគោលបោះទៅនឹងក្ដារសំពៅរឹងម៉ឹងដូចស្នឹងផង ម្ល៉ោះហើយវាញញឹម ៗញាក់ចិញ្ចើមដាក់យើងវិញ ដោយពេបជ្រាយ ហើយមានវាចាថា ៖

តាមត្រង់ទៅចុះ ! សំឡាញ់ទាំងឡាយអើយ ! អ្នកឯងចង់មកតស៊ូ

នឹងខ្ញុំនោះ មានផ្លូវតែមួយប៉ុណ្ណោះឯង គឺចាញ់ខ្ញុំ ! អ្នកត្រូវតែគោរពស្តាប់បង្គាប់ខ្ញុំទៅវិញល្អជាង ! ខ្ញុំឈ្នះមនុស្សរើងរូសទាំងឡាយជាងអ្នកឯងអស់ទៅហើយ ! បើអ្នកនៅតែតទល់នឹងខ្ញុំ ខ្ញុំនឹងសម្លាប់អ្នកឯងទាំងអស់ ដូចអាពីរនាក់នុះ ! ៗ

សំដីនេះ នាំឲ្យយើងទាំងអស់គ្នាខ្លាចវាត្រជាក់ដៃត្រជាក់ជើងដាក់ដាវដាក់ដំបង ក៏នាំគ្នាស៊ើបទៅរៀបចំគុអាហារទំ ៗ ឲ្យដនកំណាចនោះទៀត ក្នុងសេចក្ដីរៀបរយ ៗ ទៀតហើយ ! វាតមញយ ១ វាត់អស់មួយគុនេះក្លាយទៅទៀត... ឆ្អែតហើយទើបមានចិត្តទោរទន់មេត្តាករុណាហើយឲ្យពរសព្វសាធុការដល់យើងទាំងអស់គ្នា រួចវាបួងសួងសូមឲ្យជួបប្រទះនឹងសំពៅមួយទៀតសម្បូណ៌ដោយស្បៀងអាហារ នឹងអាលវាលោតចូលសំពៅនោះតទៅ... លុះតែដល់ពេលនោះ ទើបយើងទំនេរទៅកើត ៗ ក្នុងពេលនេះយើងមិនទាន់រួចខ្លួនទេ ៗ វាបរិភោគគុជាគម្រប់បួនម្តងនេះ ឃើញថាឆ្អែតឆ្អន់មែនទែន ដោយយើងឃើញពោះវាប៉ោងប្រអឹងប្រអាង ៗ យើងខ្សឹបខ្សៀវគ្នា មានសេចក្ដីសង្ឃឹមថា បន្តិចទៀតប្រហែលវាដេកលក់ ហើយយើងនឹងឆ្លៀតឱកាសនោះច្រានវាទម្លាក់សមុទ្រ ឲ្យវាស្លាប់តែម្តងទៅ ៗ នោះយើងមានស្បៀងអាហារគោតទ្រព្យច្រើនទាំងម្ទេះក៏ដោយ វានេះជាយក្ខ មិនប៉ុន្មានថ្ងៃទេ ! មុខតែវាស៊ីអស់ហើយ ស៊ីទាំងក្បាលយើងទាំងអស់គ្នាផងក៏មិនដឹង ! ៗ យើងគិតគ្នាប៉ុណ្ណោះ

ដូចជាកទ្រង់ញាណដឹងតែម្តង ! សត្វកំណាចនេះស្រាប់តែប្រាប់យើងថា ៖ ខ្ញុំមិនបេះដេកសោះឡើយ . . . . អាហារដែលចូលទៅក្នុងខ្លួនខ្ញុំទាំងប៉ុន្មាន អំបាញ់មិញ គឺជាស្រេចស្រាប់សម្រាប់ឲ្យខ្ញុំឆ្អែតទាំងចិត្ត ឆ្អែតទាំងសេចក្តីស្រេកឃ្លានរបស់រូបកាយខ្ញុំ ។

វាហៅយើងម្នាក់ម្តង ៗ ទៅសួរ អំពីស្រុកទេសទំនៀមទម្លាប់ដំណើរផ្សងព្រេងរបស់យើង ។ យើងបានឆ្លើយរៀបរាប់តាមដំណើរ ថ្វីបើយើងមានសេចក្តីបង្អៀតបង្អល់ចិត្ត ។ វាមិនដេកពាល់តែសោះ ។ យើងទាំងអស់គ្នាកើតទុក្ខយ៉ាងខ្លាំង ចុះវាសនាអ្វីក៏អាក្រក់ម្ល៉េះ ? រីឯចៅកែសំពៅ លោកមុខស្រងូតអស់សង្ឃឹមជឿជាក់ថា ត្រូវវិនាសបាត់បង់ជីវិតខានទៅដល់កោះកូលកុត ។

កំពុងតែនាំគ្នាកើតទុក្ខជាទម្ងន់ដូច្នេះ ស្រាប់តែមេឃងងឹត យើងស្មានថា ប្រហែលមានព្យុះសង្ឃរាមកដល់ ។ សូវឲ្យមានព្យុះសង្ឃរាដូច្នេះទៅវិញល្អជាង ព្រោះយក្សនេះដល់វាស៊ីស្បៀងអាហារយើងអស់កាលណា មុខតែយើងទាំងអស់គ្នាទៅជាចំណីវាទៀតជាប្រាកដពុំលែងឡើយ ។ សេចក្តីស្មានរបស់យើងនេះខុសស្រឡះ ៖ ពពកមួយដុំធំ និងចំហាយទឹកបែកផ្សែង ដែលយើងឃើញនោះ គឺជាសត្វឥន្ទ្រីមហៃសូរ្យមួយ មានមាឌធំសំបើម សត្វធំដល់ម្ល៉េះ យើងមិនដែលជួបប្រទះឃើញសោះ ។ មហាបក្សានេះ វាបោះពួយលឿនដូចព្រួញ មកចំសំពៅ

យើងហក់ចុះមកតាមឆក់ យកអាយក្ខកំណាចនោះទៅដោយស្រួល ព្រោះយក្ខនោះឥតដឹងខ្លួន ពុំឃើញមានប្រយុទ្ធតស៊ូអ្វីសោះនឹងសត្វនោះ ៗ ថ្វីបើដូច្នោះ ស្រាប់តែដល់ទៅលើមេឃ យក្ខនោះវាចុចក្រចកវាចូលទៅក្នុងសាច់សត្វឥន្ទ្រីរួចវាខ្វះយកសាច់ទាំងដុំៗមកស៊ី ស៊ីទាំងស្លាបសត្វបក្សីនោះផងទៀត ៗ សត្វឥន្ទ្រីឈឺណាស់ ស្រែកព្រកក្រើកមហាសាគរ ទាំងយកក្រចកវាខ្វះក្អែកយក្ខខ្លាក់ទាំងពីរ ទាំងក្អែកខ្លាក់យក្ខនៅតែខំខ្វះយកបេះដូងឥន្ទ្រីមកបរិភោគ ៗ ឯសត្វឥន្ទ្រីដឹងដូច្នោះ វាក៏ប្រមូលកម្លាំងក្នុងខ្លួនវាទាំងប៉ុន្មានទំប្រឹងគ្រវែងមួយចំពុះ ចុះលលាដ៍ក្បាលយក្ខ សត្វបក្សីនិងយក្ខ ក៏ធ្លាក់គ្រាំទាំងពីរ នៅក្បែរយើង លិចស្លាប់ក្នុងសមុទ្រអស់ទៅ ៗ

X

X X

យើងទាំងអស់គ្នាវាយកញ្ចាក់លោតកញ្ចែងក្នុងសំពៅ សប្បាយរីករាយណាស់ ៗ តែយើងមានសេចក្ដីស្ដាយថា មិនគួរឡើយនឹងសត្វឥន្ទ្រីស្លាប់ សត្វនេះមានគុណនឹងយើង ៗ ម្យ៉ាងទៀតយើងចេះតែឆ្ងល់គិតមិនយល់ថា ចុះមានពូជមនុស្សអ្វីក៏ចម្លែកអស្ចារ្យម្ល៉េះ ? នៅក្នុងពិភពលោកយើង ៗ

ដល់យើងបានរួចពីយក្ខអសុរយ៉ង់ឃ្នងហើយ យើងបន្តដំណើរទៅទៀត ៗ សំណាងល្អ ខ្យល់រំភើយៗល្មម សំពៅអណ្ដែតបានលឿន

ជាច្រើនថ្ងៃតមក យើងឃើញទីដីគោកលិមៗ ។ កម្មករនាវាខាងជើងក្ដោង បានឲ្យយោបល់ថា បើយើងបិតនៅខាងសមុទ្ទខ្ពស់ដូច្នេះ ទីដីស្រួចនុះត្រូវជាចុងកោះជ្វាបែកខាងលិច មានកោះស៊ុម៉ាត្រានៅខាងកើត ចន្លោះនោះ ជាច្រកសមុទ្ទឈ្មោះ ឡាសុន្ដ ជិតទីក្រុងបាន់តាំ ។

យើងទាំងអស់គ្នារីករាយសប្បាយណាស់ ដោយបានឃើញដូច្នេះ នាំគ្នាទំជួយបំប៉ោងក្ដោង ទទួលពេលនោះខ្យល់បញ្ចូនល្អ ត្រូវទិសផង មិនយូរប៉ុន្មាន យើងក៏បានសំចតវិញ នៅកំពង់នៃក្រុងបានតាំនេះ ។ យើងនាំគ្នាទិញស្បៀងអាហារជាថ្មី ស្រេចហើយ យើងបន្ដដំណើរហូតដល់កោះដ៏ល្បីល្បាញមួយឈ្មោះបាតាវី ។ នៅទីនេះចៅកែយើង លោកមានកិច្ចការត្រូវបំពេញផងដែរ ។ ទីនេះឆ្ងាយពីក្រុងបានតាំ ប្រហែល ១៥ ឬ ២០ លៀ (៦០ ឬ ៨០ គីឡូម៉ែត្រ) ស្រេចហើយយើងត្រូវធ្វើដំណើរតាមផ្លូវកាត់ ប្រហែលមួយខែ ទើបដល់ព្រះរាជអាណាចក្រនាមគូលកុណ្ឌ ។

នាកាលយើងដល់កំពង់នៃរាជធានីក្ខាម មានជនានុជនកុះករឈូឆរមកទទួលយើងដោយឧបអរសាទរ ព្រោះចៅកែយើង លោកជាមនុស្សមួយ មានគេស្រឡាញ់រាប់អានច្រើន ។ ចំណែកខាងគ្រួសារលោកនោះ ឃើញថាមានសេចក្ដីរីករាយសប្បាយជាពន់ពេកណាស់ ។ ប្រពន្ធនិងកូនស្រីរបស់លោក នាំគ្នាទាំងម្ដាយទាំងកូន មកឱបលោកមិនលេះ

អស់មិនបេះហើយ ទឹកមុខទន់ភ្លន់គោរព ឯលោកក៏ឃើញសប្បាយរីករាយណាស់ ចិត្តប្រកបដោយមុទិតាធម៌ ទៅកាន់ប្រពន្ធកូនដល់ទឹកភ្នែករលេងរលោង...ៗ លោកថៅកែបាននាំខ្លួនខ្ញុំ (ក) ទៅបង្ហាញអស់លោកស្រីទាំងនេះ ដោយមានប្រសាសន៍ថា ឈ្មោះកាប៊ូលហ្វ៉ាអ៊ួរ៉ស់នេះជាពាសា ដែលលោកកប់គាន់ជាពិសេស ហើយប្រគល់ជូនតាមតែលោកស្រីប្រើប្រាស់តាមត្រូវការតទៅ ៗ

X X

X

លុះចំណេរកាលតមកមិនយូរប៉ុន្មាន លោកស្រីទាំងអស់នោះ មានសេចក្ដីអាណិតកប់គាន់ខ្ញុំជាខ្លាំង នរណាធ្វើអ្វីក៏មិនប្រសើរល្អដែរ បានតែរូបខ្ញុំមួយនេះធ្វើ ទើបពេញចិត្តលោក ៗ ពាសា ពាសី ទាំងឡាយឥតមានសេចក្ដីច្រណែនអ្វីទេ នាំគ្នាកាន់តែសប្បាយចិត្តខ្លាំងទៅទៀត ដោយឃើញខ្ញុំបានគាប់ដូច្នេះ ៗ ជាការណ៍ពិត ចំណែកខាងខ្ញុំ ៗ ក៏ខំលួងលោមអ្នកទាំងនោះ ឲ្យធូរឲ្យស្រួលហើយជារឿយ ៗ ខ្ញុំចែកចាយទ្រព្យនិងរង្វាន់ខាន់ទៅឲ្យអ្នកដែលមិនគួរទាំងបានផងនោះដែរ ៗ ដូច្នេះលោកឪហាអូស្ស មានសេចក្ដីអនុគ្រោះ ដល់ខ្ញុំកាន់តែធំឡើង ៗ ទើបមានថ្ងៃមួយលោកមានប្រសាសន៍និងខ្ញុំថា ៖

កាប៊ូលហ្វ៉ាអ៊ួរ៉ស់! អ្នកប្រហែលជាបានសង្កេតឃើញថា ខ្ញុំទុកដាក់អ្នក ខុសពីពាសាទាំងឡាយឯទៀត ៗ ៗ ខ្ញុំនិយាយឲ្យច្បាស់ទៅចុះថា

ខ្ញុំនឹងមានសេចក្ដីអាណិតអាសូរដល់អ្នក លើសពីនេះទៅទៀត ៗ អ្នកបានឃើញនាង ហ៊្រក្រិនិសាកូនរបស់ខ្ញុំហើយ តាមខ្ញុំស្មានគឺនៅទីកោះគូលគុនិនេះ គ្មានកញ្ញាណាស្អាតល្អជាងទេ ខ្ញុំបានស្ងាបស្ទង់ចិត្តកូនខ្ញុំហើយ មើលទៅរូបអាប៊ូលហ៊្រអ៊ូរីស៊ែងឯង ពុំមែនជាទីស្អប់ខ្ពើមរបស់វាទេ ៗ

ឮដូច្នេះខ្ញុំ (អា) ក៏តាំងស្មារតី បេញស្ដីមិនរួច ៗ លោកខេហាអូស្ស ឃើញមុខខ្ញុំស្ទើរតែឥតញញឹមសោះ ទើបលោកថែមសេចក្ដីថា៖ ចុះម្ដេចទៅវិញ! សេចក្ដីដែលខ្ញុំស្នើអំពាញម៉ិញ មិនគាប់ចិត្តអ្នកទេឬអ្វី? នាងហ៊្រក្រិនិសាកូនខ្ញុំទៅធ្វើជាប្រពន្ធរបស់អ្នក រួចអ្នកត្រូវទទួលសម្បត្តិទ្រព្យខ្ញុំជាមរតក... (ល) អត្ថប្រយោជន៍ប៉ុណ្ណេះមិនសមល្មម នឹងចិត្តតាសាម្នាក់ដូចអ្នកឯងឬអ្វី ?

(អា)– មហាសេដ្ឋី ដ៏ជាទីគោរពខ្ញុំអើយ! ខុនខ្ញុំប្រហែលបានធ្វើជាកូនប្រសាលោក កិត្តិយសនេះ ខ្ញុំចង់បានជាទីបំផុត បើលោកចូលសាសន៍ម៉ាហូម៉ិតដូចខ្ញុំទៅក៏... តែលោកល្អនឹងខ្ញុំណាស់...

(ខ)– ទេ! បើមានឧបសគ្គតែមួយនេះទេ ជាគ្រឿងរាំងរកអ្នកនោះមិនយូរប៉ុន្មានទេ បន្តិចទៀតយើងស្រុះស្រួលគ្នាបានហើយ ព្រោះខ្ញុំនឹងសម្រេចចិត្តថា ខ្ញុំចូលសាសនាម៉ាហូម៉ិត ឯកូនស្រីខ្ញុំក៏ដូច្នោះដែរ ៗ អ្នកបួសលោកបានដាក់ច្បាប់តាំងឡាយបង្អិលខួរក្បាលខ្ញុំ ថ្វីបើខ្ញុំនឿយណាយអស់កម្លាំងកាយ-ចិត្ត ទៅថ្វាយបន្ទំធ្វើពលិកម្មបូជា ស្ងូត្រធម៌គោរពឈ្មោះ

គោញីតាំងនោះហើយក៏ដោយ ! ខ្ញុំជាមនុស្សដឹងខុសត្រូវជាពន់ពេក មិនសមឡើយខ្ញុំទៅទទួលតាំងនឹងគេធ្វើក ៗ គ្នា តាមជំនឿអមង្គល ខ្ញុំដឹងពិតជា ត្រូវមានអ្វីប្រសើរខ្ពស់លើសលើព្រះអាទិទេពម្ចាស់សួគ៌តាំងនោះទៅទៀត ? ៗ ដូច្នេះ កូនអើយ ! ត្រូវកូនទទួលយល់ព្រមគោរពតាមសេចក្ដីស្នើរបស់ឪពុកចុះ កុំញញើតញញើមអ្វីឲ្យសោះ ឪពុកសុំឲ្យកូនទទួលភ្លាមទៅ !

(ក)–ទោះបើខ្ញុំខំប្រុងស្មារតីយ៉ាងណាក៏ដោយ - មើលទៅប្រហែលជាដោយហេតុ ខ្ញុំឃើញនាងកនហ្វាឌុក៏ពុំដឹង !– ការពាហពិពាហ៍ដែលគេផ្គួផ្គងកូនគ្រានេះ នាំឲ្យខ្ញុំមានសេចក្ដីខ្ពើមរអើមជាដរាប ៗ កង់ពេលនោះ ខ្ញុំឥតមានបញ្ចេញអាការអ្វីឡើយ ទៅកាន់ចៅហ្វាយខ្ញុំ ៗ ដោយស្មានថា ខ្ញុំយល់ព្រមហើយ ព្រោះពុំឮប្រកែកអ្វីសោះ លោកក៏អញ្ជើញទៅភយកប់រឿងនេះ ជាដំណឹងដល់ប្រពន្ធនឹងកូនស្រីរបស់លោក ៗ បន្ទាប់ភ្លាមតមក ខ្លួនខ្ញុំមានសេរីភាពនិយាយជាមួយនឹងនាងហ្វ៉ាក្រិន្ទិសា ចង់ញញឹមញញែមញញាក់ញញោច ដើមក្អែកកន្ទុយក្អែកជាក់គ្នាយ៉ាងណា បានតាមចិត្ត ៗ នាងមានសេចក្ដីរីករាយស្រស់បំព្រង ខ្ញុំនឹកថាប្រហែលជានាងស្រឡាញ់ខ្ញុំខ្លាំងដោយសុទ្ធចិត្ត ... តែបន្តិចមក ខ្ញុំបានដឹងថា សេចក្ដីដែលខ្ញុំស្មាននេះ គឺខុសស្រឡះ !

(នៅមានត)

# ល្បើកឡាហ្វុងតែន

ប្រែពីភាសាបារាំងដោយលោក ដេង-ជ្រីវ

(៣)

## ៩៤)- សំឡាញ់ពីរនាក់

មានមិត្រពីរនាក់អាស្រ័យនៅ «ម៉ូណូម៉ូតាប៉ា» (១): មិត្រទាំងពីរនេះមានទ្រព្យសម្បត្តិ ប្រហាក់ប្រហែលគ្នា ។ មិត្រភក្តិក្នុងប្រទេសទាំងនោះ ក៏មានតម្លៃ ដូចមិត្រភក្តិ ក្នុងប្រទេសយើងដែរ ។

មានយប់មួយ នៅពេលដែលមិត្រទាំងពីររូប កំពុងទទួលទានដំណេក ស្រាប់តែមិត្រម្នាក់ស្ទុះក្រោកដូចមានអាសន្នលោតចុះពីគ្រែ រត់ទៅឯផ្ទះមិត្រជាទីស្នេហា ហើយដាស់បាវបំរើទាំងឡាយភ្ញាក់គ្មានសល់ ។

មិត្រដែលកំពុងដេក ក៏ស្ទុះក្រោកឡើងទាំងធ្ងល់ ឆក់ទៅយកប្រាក់ យកអាវុធ រត់មកជួបនឹងមិត្រហើយសួរថា៖ ខ្ញុំមិនដែលធ្លាប់ឃើញសំឡាញ់ស្ទុះស្ទាក្នុងពេលដែលគេកំពុងដេកយ៉ាងនេះ តាមដែលខ្ញុំធ្លាប់ដឹង សំឡាញ់ជាមនុស្សចេះសំចៃពេលគ្រាន់បើ សំពប់ការទទួលទានដំណេក តើសម្លាញ់ មានបើខាតបង់ប្រាក់កាស ដោយល្បែងភ្នាល់ឬ? ប្រាក់ឯណេះ! ហ៎យកទៅ ឬសម្លាញ់មានបើកើតជម្លោះអ្វី ខ្ញុំមានដាវ យើងទៅជាមួយគ្នា ; ឬសម្លាញ់អផ្សុកខ្លាំងពេក ព្រោះដេកតែ

(១)- ម៉ូណូម៉ូតាប៉ា ជាប្រទេសមួយនៅអាហ្វ្រិកខាងត្បូង ។

ម្នាក់ឯងជានិច្ចនោះ ? ខ្ញុំមានបាវស្រីម្នាក់រូបល្អគួរសម សម្លាញ់ត្រូវការឬ ខ្ញុំឲ្យគេហៅមក ?

មិត្រនោះឆ្លើយថា ៖ ទេ អ្វីក៏មានទាំងអស់ ខ្ញុំសូមអរគុណខឹងសម្លាញ់ហើយ ។ កំពុងដេក ខ្ញុំយល់សប្តិឃើញសម្លាញ់ឯងដូចមានសេចក្តីព្រួយបន្តិច ដោយខ្ញុំខ្លាចក្រែងរដូចជាក្នុងយល់សប្តិ ទើបខ្ញុំរត់មកសួរយាំងរហ័សនេះ ។ ដំណើរដែលខ្ញុំមកនេះ មានយល់សប្តិបច្រែជាហេតុ ។

បណ្តាមិត្រទាំងពីរ តើមិត្រណាដែលមានចិត្តស្នេហាជាងគេ? ចំពោះរឿងនេះ សូមអ្នកអានវិនិច្ឆ័យផងចុះ ។

មិត្រពិតប្រាកដ ទុកជាវត្ថុមួយដ៏ផ្អែមល្ហែម ! មិត្រនោះរមែងតែងស្វែងរកនូវសេចក្តីត្រូវការរបស់អ្នក រហូតដល់ក្នុងបេះដូងអ្នក គេមានអធ្យាស្រ័យ ចំពោះការខ្វះខាតរបស់អ្នក គឺថាមិនបណ្តោយឲ្យអ្នកស្វែងរកសេចក្តីត្រូវការដោយខ្លួនអ្នកឡើយ ។ ទោះជាយល់សប្តិក្តី ទោះជាអ្វីដទៃក្តី ទាំងនេះតែងធ្វើឲ្យមិត្រព្រួយបារម្ភជានិច្ច កាលបើរឿងនេះមានការទាក់ទងដល់មិត្ររបស់គេ ។

## ៩៥)– អ្នកទទួលបញ្ញើមិនស្មោះត្រង់

ដោយសារតែទេពស្តារតី ខ្ញុំបានយកសត្វទាំងឡាយមកថ្លែងពណ៌នា ។ ប្រហែលជាតួដទៃទីងផ្តល់នូវជោគជ័យស្តួចស្តើងដល់ខ្ញុំ ។ ក្នុង

អត្ថបទទាំងឡាយរបស់ខ្ញុំ ៗ ឲ្យចចក និយាយនិងគ្នា សត្វទាំងឡាយល្មមគួរសម ត្រូវធ្វើជាតួផ្សេងៗ ខ្លះជាមនុស្សឆ្កួត ខ្លះជាបណ្ឌិត ប៉ុន្តែឃើញថា តួជាមនុស្សឆ្កួត មានចំនួនច្រើនបរិបូណ៌ជាង ។ មិនតែប៉ុណ្ណោះ ខ្ញុំយកអ្នកបោកបញ្ឆោត យកចោរ អ្នកលោភលាក្រក់ អ្នកអកតញ្ញូ អ្នកប្រមាទ លលាតែ អ្នកល្ងីល្ងើ និងបញ្ញោរ មកដាក់ផងដែររួចខ្ញុំបញ្ចូលក្រុមអ្នកកុហកថែមមកទៀត ព្រោះបណ្ឌិតតែងពោលថា ៖ មនុស្សនិយមកុហកជាប្រមាណ ៗ ប្រសិនបើមានតែក្រុមមនុស្ស ស្រទាប់ថោកទាប គេនឹងមិនអាចដឹងនូវកំហុសនៃមនុស្សទាំងឡាយបានឃើញទាំងអស់គ្នាសុទ្ធសឹងនិយាយកុហកទាំងធំទាំងតូច តែបើអ្នកណាហើយនិយាយពាក្យកុហក ខ្ញុំនឹងប្រឆាំងជាដាច់ខាត ។ ហើយទោះបីមានអ្នកណាមួយ នឹងត្រូវការកុហក ក៏អ្នកកុហកដ៏ពិតប្រាកដ នឹងមិនមានសភាពដូចជាលោក « អេសុប » (Esope) (១) និងលោក (ហោមែរ៍) (២) (Homère) ឡើយ គឺជាសម្ផស្សដ៏ត្រជាក់ផ្អែម នៃចិត្តគតិជាច្រើន ដែលកើតមានឡើង ដោយសិល្បៈដ៏ឧត្តមរបស់លោក ក្រោមសំពត់គឺការកុហក រមែងផ្តល់ផលយើងនូវការណ៍ពិត ៗ លោកទាំងពីររួបធ្វើសៀវភៅមួយ ដែលខ្ញុំទទួលទុក ថាគួរគប្បីឲ្យមានជីវិតតទៅរកទីបំផុតគ្មាន ។ អ្នកណាដែលប្រាថ្នាអ្វី កុំកុហកដូចលោកខាងលើ ៗ ហើយកុហកដូចជា

---

១- កវីជាតិក្រេក ២– អ្នកនិពន្ធជាតិក្រេកដ៏ល្បីល្បាញ ។

អ្នកទទួលបញ្ញើម្នាក់បានធ្វើ រួចត្រូវទទួលទោសព្រោះតែសំដីនៃអាត្មាត្រូវចាត់ទុកជាអ្នកកំណាច និងជាអ្នកល្ងីល្ងើ ៗ រឿងនេះមានដូចតទៅ ៖

មានពាណិជម្នាក់នៃប្រទេស «ពែរ្ស» (Perse) កាលដែលនៅជំនួញ បានយកដែកប្រហែល ១០០ គីឡូ ទៅផ្ញើទុកនឹងអ្នកផ្ទះជិតខាង ៗ លុះត្រឡប់មកវិញ ពាណិជនោះទៅសុំយកដែកមកវិញ ៗ

អ្នកទទួលបញ្ញើប្រាប់ថា: ដែករបស់អ្នក ? ខ្ញុំស្តាយណាស់ ព្រោះមានកណ្តុរមួយ ស៊ីអស់រលីង ៗ ចំពោះរឿងនេះ ខ្ញុំបានស្តីបន្ទោសយ៉ាងខ្លាំង ដល់មនុស្សទាំងឡាយក្នុងផ្ទះដែរ តែធ្វើដូចម្តេច ? ព្រោះក្រន់ស្រូវរមែងមានរន្ធជានិច្ច ៗ

ពាណិជនោះក៏កោតរឿងប្លែកដ៏អស្ចារ្យនេះពេក ហើយធ្វើជារឿងនោះទុកជាការណ៍ពិត ៗ កន្លងពីនោះមកមិនបានប៉ុន្មានថ្ងៃ ពាណិជបានគិតដោយសម្ងាត់ ឲ្យគេលបលួចចាប់កូនអ្នកជិតខាងយកទៅលាក់ទុក រួចទៅអញ្ជើញឪពុកកូននោះមកពិសាលៀង គាត់នេះសុំទោសទាំងទឹកភ្នែកថាមិនបានទៅទេ ព្រោះសេចក្តីសប្បាយរីករាយតែបាត់អស់ហើយ ៗ ពោលថា ៖ ខ្ញុំស្រឡាញ់កូនស្មើជីវិត ខ្ញុំមានតែវាមួយហ្នឹង ឥឡូវអ្នកណាលួចចាប់យកទៅបាត់ហើយ តាមតែអ្នកអភ័យទោសដល់ខ្ញុំផងចុះ ខ្ញុំព្រួយពេកណាស់ ៗ

ពាណិជឆ្លើយថា៖ ពីម្សិលមិញ ពេលល្ងាចជិតយប់ ខ្ញុំឃើញ

សត្វគូកហើរមកឆាបឆក់កូនអ្នកទៅ សំដៅគេហស្ថានកញ្ញាស់មួយ ។

ឪពុកឆ្លើយថា៖ អ្នកឯងនិយាយយ៉ាងនេះ ខ្ញុំរកជឿមិនកើត មិនដែលឮសត្វណា អាចឆាបឆក់យកទៅបាននូវរំពាបែបនេះ ? តើគួរជឿបានឬទេ សត្វគូកអាចឆាបឆក់កូនខ្ញុំយកទៅបាន ? ពាណិជឆ្លើយថា៖ ចំពោះរឿងហ្នឹង ខ្ញុំមិនឆ្លើយជំទាស់ទឹងអ្នកទេ ព្រោះខ្ញុំឃើញថាច្បាស់នឹងភ្នែករបស់ខ្ញុំ គឺឃើញវាឆាបយកកូនអ្នកទៅមែន ហើយខ្ញុំមិនឃើញមានអ្វី ដែលបង្ខំឲ្យអ្នកសង្ស័យបន្តិចបន្តួចសោះ នៅពេលខាងក្រោយដែលខ្ញុំនិយាយរឿងនេះ ។ តើអ្នកឃើញជាការប្លែកអស្ចារ្យឬទេ ដែលកណ្ដុរតែមួយ អាចស៊ីអស់ដែក ១០០ គីឡូបាន ហើយសត្វគូកមិនអាចឆាបយកបាននូវកូនក្មេងទម្ងន់តែ ៤០ គីឡូ ?

ឪពុកកូនក្មេងទាល់ប្រាជ្ញ ក៏ប្រគល់ដែកមកឲ្យពាណិជ ។ ក៏ត្រឡប់ប្រគល់កូនទៅឲ្យវិញ ។

(នៅមានត)

ព្រះពជាអង្គណា មានសេចក្ដីកែកាយទឹង
សេចក្ដីក្រោធស្មើគ្នា មានសេចក្ដីត្រេក
អរក្នុងសាស្ត្រទឹងអាថ៌ មានការទំនុក
បំរុង អាមាត្យអស់កាលជានិច្ច ផែនដី
គប្បីចំរើននូវទ្រព្យចំពោះព្រះពជាអង្គនោះ

ហិតោបទេស

# រឿងសាមកុក

ឧកញ៉ាវិបុលរាជសេនា នូ-កាន ប្រែរៀបរៀង

(តមក)

> រឿងសាមកុកទុកជាយុទ្ធសាស្ត្រ
> អ្នកវាងវៃឆ្លាសបើបានអាន
> នឹងបេះឧបាយកលចំណាន
> ទាំងមានសន្ដានស្នេហាជាតិ ។
>
> យូរ-អ៊ុន

ឯចូឆូនោះ លុះដល់ពេលយប់ស្ងាត់ ក៏ចាត់ប្រើទៀវខាប់ នឹងហៃហ៊ឺអៀនលើកទាហានទៅពួនបង្កប់នៅលើកំពូលភ្នំទាំងសងខាង ហើយឲ្យទាហានឡើងទៅជីករណ្ដៅមួយជ្រៅ ហើយយកដីគ្របពីលើមាត់រណ្ដៅលុញឲ្យស្អាតមិនឲ្យក្រឡេកយល់ លុះដល់ពេលទៀបភ្លឺស្រាងក៏ចាត់ទាហានឲ្យលើកទៅចំណាយកំពែងស្រុក ឯខ្លួនចូឆូនឹងទាហានប្រមាណ ១៤-១៥ នាក់ក៏ឡើងនៅលើកំពូលភ្នំដែលជីករណ្ដៅទុកនោះ ។

លុះព្រឹកឡើង ប៉ាំងតេកលើកទាហានបើកទ្វារស្រុកចេញទៅតាំងតែពោមពាយចំណាយកងទ័ពចូឆូ ខៅធូឃើញដូច្នោះក៏បរសេះចូលច្បាំងនឹងប៉ាំងតេកជាប់ដៃគ្នាទៅវិញទៅមក ហើយធ្វើជាថយរត់ទៅក្រោយ ប៉ាំងតេកឃើញបានចំណាប់ ក៏ប្រញាប់បរសេះដេញតាមទៅដល់កំពូលភ្នំ ។

ចូឆូនៅលើកំពូលភ្នំខ្ពស់ត្រដែត ឃើញប៉ាំងតេកដេញខៅធូឡើងមកក៏

ស្រែកស្ដីទៅប៉ាំងតេកថា ស្រុកហាន់តុងប៉ីដូចជានៅក្នុងកណ្ដាប់ដៃយើង អស់ហើយ ហើយទៀវឡេនោះប៉ីដូចកូនមាន់ យើងនឹងចូលកាប់ ចំណាយឲ្យបានឥឡូវនេះ បើស្រុកហាន់តុងបានយើងហើយ ខ្លួនអ្នកឯងក៏ គង់នឹងស្លាប់អសារឥតការ ហេតុនេះ អ្នកគួរតែមានប្រាជ្ញាចូលមកលន់ តួចំណុះយើងដោយស្រួលបួលទៅចុះ ទើបនឹងរួចពីសេចក្ដីស្លាប់ ៗ

ប៉ាំងតេកបានឮដូច្នោះក៏គិតថា បើប្រសិនជាយើងនឹងចាប់ទាហាន បានដល់រយនាក់នាំទៅឲ្យទៀវឡេ ក៏មិនស្មើនឹងចាប់បានខ្លួនចូឆូតែមួយ នោះឡើយ គិតហើយក៏ញាក់សេះឡើងទៅលើកំពូលភ្នំដោយមិនដឹង កលឧបាយ ទទួលព្រួសូរជាវ សេះនោះក៏ស្ទុះទៅចំមាត់រណ្ដៅ ប៉ាំងតេកក៏ ធ្លាក់ពីលើសេះចុះទៅក្នុងរណ្ដៅ ៗ ពួកទាហានចូឆូក៏ស្ទុះស្រូបចូលទៅព័ទ្ធ ចាប់ខ្លួនប៉ាំងតេក ចងបានហើយនាំទៅឲ្យចូឆូ ៗ

ចូឆូឃើញដូច្នោះ ក៏ក្រោកធ្វើជាឃាត់ហាមទាហានទាំងអស់នោះកុំ ឲ្យវ៉ៃឡើយ ចូឆូចុះទៅពីលើសេះ ស្រាយចំណងប៉ាំងតេកចេញអស់ ហើយសួរថា ខ្លួនអ្នកនឹងព្រមនៅធ្វើការជាមួយនឹងយើងតទៅឬ ? យើងនឹងទុកអាយុជីវិត ប៉ាំងតេកក៏នឹកគិតតែក្នុងចិត្តថា ចិត្តចូឆូនេះមិន មានអាឃាតព្យាបាទនឹងយើងសោះ ឯទៀវឡេនោះជាមនុស្សចិត្តស្រាល ត្រចៀកស្រាល គ្មានពិគ្រោះពិចារណាឲ្យដឹងការច្បាស់ប្រាកដរកឲ្យ ឃើញខុសនិងត្រូវសោះ គិតហើយក៏ឆ្លើយថា ខ្លួនខ្ញុំបាទជាសត្រូវខ្មាំង

នឹងលោក ៗ ចាប់ខ្លួនបានមិនសម្លាប់នោះ ព្រះគុណជាទម្ងន់មិនមានទីបំផុត ខ្ញុំសូមផ្ញើអាយុជីវិតនឹងលោក សូមចូលធ្វើជាការតបស្នងព្រះតេជព្រះគុណ ត្រាតែអស់ជីវិត ៗ

ចូច្ចបានស្ដាប់ហើយក៏មានអំណរណាស់ ទើបឲ្យរកសេះ ១ មកឲ្យប៉ាំងតេកជិះ ហើយក៏នាំចូលទៅក្នុងបន្ទាយ រួចឲ្យរៀបតុលៀងអាហារ ហើយឲ្យបំណាច់ប្រាក់មាសដល់ប៉ាំងតេកជាច្រើន លុះវេលាព្រឹកឡើង ចូច្ចក៏ប្រើទាហានឲ្យយកជើងជណ្ដើរនឹងចង្កៀង ទៅដាក់ភ្ជាប់នឹងកំផែងស្រុក ឯទាហានដែលនៅលើសេនបន្ទាយក៏បាញ់ធ្នូរុះចូលមក ហើយបោលទម្លាក់ដុំថ្មមកត្រូវទាហានចូច្ចរបួសពិការស្លាប់ជាច្រើន ពួកទាហានចូច្ចក៏យកស្ពាន់ធម៌នឹងរំសេវមកលាយគ្នាដាក់ជាឈ្នួនក្នុងដុំដី ហើយបោលចូលទៅលើដំបូលផ្ទះ ឈ្នួននោះក៏ឆេះរាលដាលគ្រប់ដំបូលផ្ទះរបស់អ្នកស្រុកពេញពាសឡើង ពួកអ្នកស្រុកទាំងអស់គ្នាក៏នាំគ្នាលត់បាន ៗ

ទៀវឡូដឹងថា ប៉ាំងតេកប្រែចិត្តក្បត់ចូលទៅខាងចូច្ចហើយ ក៏ប្រឹក្សានឹងទាហានទាំងពួងថា វេលានេះ ប៉ាំងតេកចេញជាក្បត់នឹងយើងទៅនៅខាងចូច្ចហើយ ចូច្ចក៏លើកកងទ័ពមកដល់ជើងកំផែងទៀត តើអ្នករាល់គ្នានឹងជួយគិតប្រការម្ដេច ? ៗ ទៀវអ៊ូយឆ្លើយថា ការដែលនឹងការពារស្រុកទុកឲ្យបាននោះមុខជាមិនកើតទេ គួរតែដុតបំផ្លាញភូមិស្រុកទាំងនេះឲ្យវិនាសអស់ចេញ កុំឲ្យចូច្ចបានរបស់ទ្រព្យអ្វីឡើយ ហើយខ្លួនលោក

ក៏ត្រូវនាំគ្រប់គ្រួ នឹងពលទាហានរត់ចេញទៅនៅស្រុកប៉ាគុនវិញ ៗ អៀវស៊ុនឆ្លើយថា ដែលនឹងឆ្លើយថា ដែលនឹងធ្វើតាមពាក្យទៀវអ៊ូយនោះ មិនគួរទេ បើប្រសិនជារត់ចេញទៅនៅស្រុកប៉ាគុន ក៏គង់មិនរួចពីដៃចូចូ សុំឲ្យលោកចេញទៅលន់តួ សុំចំណុះចុះចូលដោយល្អទៅវិញស្រួលជាង ៗ

ទៀវឡូ បានស្តាប់ទៀវអ៊ូយ នឹងអៀវស៊ុនថាខុសដំណើរសេចក្តីគ្នា ដូច្នោះ ក៏មិនអស់សង្ស័យ មិនដឹងនឹងយកសំដីវាងណា ហើយថា កាលពីដើម យើងគិតនឹងតាំងខ្លួននោះ ប្រាថ្នានឹងជួយទំនុកបំរុងអាណាប្រជានុកស្រ្តឲ្យបានសេចក្តីសុខ ឥឡូវនេះ មានកម្មជាហេតុឲ្យទុក្ខមកបណ្តាលឲ្យពាល់ខ្លួនដល់ទីនៅហើយ បើនឹងដុតបំផ្លាញទ្រព្យរបស់នឹងស្បៀងអាហារសម្រាប់ស្រុកចេញមិនគួរ ៗ តែនាំគ្នារត់ចេញទៅឲ្យផុតអំពីភ័យអន្តរាយចុះ លុះដល់ពេលយាម ២ ប្តាយ ទៀវឡូក៏នាំគ្រប់គ្រួនឹងស្ម័គ្របក្សពួករត់ចេញតាមផ្លូវទ្វារទិសខាងត្បូង ដម្រង់ទៅស្រុកប៉ាគុន ៗ ចូចូដឹងដូច្នោះ ក៏មិនបានឲ្យទាហានដេញតាមទៀវឡូនោះទេ លុះព្រឹកឡើង ចូចូក៏នាំទាហានទាំងពួងចូលទៅក្នុងស្រុកហាន់តុង ចូចូឃើញឃ្លាំងនឹងចង្រុកចាក់សោរជាប់ ក៏បង្គាប់ទាហានឲ្យពុះទំលាយទ្វារចូលទៅឃើញរបស់ទ្រព្យនៅច្រើនណាស់ ចូចូក៏បង្កើតចិត្តសង្វេកអាណិតគិតថា ទៀវឡូនោះជាមនុស្សទៀងត្រង់ មិនបានធ្វើអន្តរាយរបស់ទ្រព្យក្នុងស្រុកឲ្យវិនាសរត់យកតែខ្លួនទៅពួនក្នុងទីដទៃ សមដូចពាក្យបុរាណ

ពោលទុក បួចក៏តែងជាសំបុត្រមានទំនុកទំនៀមតាមធម៌ល្អ បញ្ចុះបញ្ចូលចិត្តទៀវឡ្យឲ្យវិលមកចំណុះចុះចូលតាមស្រួលទៅចុះ បួចថា មិនបានប្រកាន់ទោសពៃរ៍អ្វីទេ បំរើក៏កាន់សំបុត្រនោះទៅឲ្យទៀវឡ្យ ឯស្រុកប៉ាតុង ។

ទៀវឡ្យបានយល់សេចក្ដីក្នុងសំបុត្រដូច្នោះ ក៏ចេះតែគិតខ្លាចក្រែងបួចនឹងធ្វើកលឧបាយបញ្ឆោត ទើបប្រឹក្សានឹងទៀវអ៊ុយជាប្អូន តាមសេចក្ដីសំបុត្របួចនោះ ។ ទៀវអ៊ុយថា ឯចិត្តបួចនោះប្រកបដោយកលឧបាយបញ្ឆោតច្រើនប្រការណាស់ ដែលនឹងចូលទៅលន់តួនោះ ខ្ញុំបាទមិនយល់ផងទេ សុំឲ្យគិតតែរក្សាស្រុកប៉ាតុងទុកឲ្យគង់នៅចុះ បើបួចលើកទ័ពតាមមកនឹងបានតទល់ច្បាំងគ្នាជាមាំមួន ទៀវឡ្យក៏ទទួលស្ដាប់ពាក្យទៀវអ៊ុយជាប្អូន គៀវស៊ុងក៏លបធ្វើសំបុត្រស្ងាត់ ប្រើបំរើឲ្យនាំទៅឲ្យបួចឯស្រុកឃានតុង ។

បួចទទួលសំបុត្រនោះទៅមើល ឃើញសេចក្ដីថា ខ្ញុំបាទគៀវស៊ុងសូមគំនាប់មកដល់ហ៊ុយក៊ុងបានជ្រាប ដែលទៀវឡ្យរឹងទទឹង មិនព្រមចូលមកលន់តួលោកនោះ ព្រោះទៀវអ៊ុយជាប្អូននាំរឹងទទឹង សូមឲ្យលោកលើកទ័ពទៅវាយស្រុកប៉ាតុងចុះ ខ្ញុំបាទនឹងទទួលជាកលសឹកខាងក្នុង , បួចឃើញសេចក្ដីដូច្នោះក៏មានអំណរណាស់ ទើបចាត់ចែងកងទ័ពលើកទៅតាំងនៅជិតស្រុកប៉ាតុង ។

ឯទៀវឡុះដឹងថា ចូឆូលើកទ័ពទៅដល់កំប្រឹក្សានឹងទាហានទាំងពួនថា ឥឡូវចូឆូលើកទ័ពមកយើងនឹងគិតការពារប្រការម្តេច ទៀវអ៊ួយថា ខ្ញុំបាទនឹងសុំអាសាលើកទ័ពចេញទៅច្បាំងនឹងចូឆូ ហើយទៀវអ៊ួយក៏ចាត់ចែងទាហានលើកចេញទៅ ។

ចូឆូឃើញដូច្នោះ ក៏ប្រើខាវធូចេញទៅតនឹងទៀវអ៊ួយបាន ៤ ក្បួន ខាវធូក៏យកលំពែងចាក់ត្រូវទៀវអ៊ួយធ្លាក់ពីលើសេះស្លាប់ ទាហានទាំងពួនក៏បែករត់ចូលទៅប្រាប់ទៀវឡូ ៗ ដឹងដូច្នោះ ក៏ភ័យស្លុតស្មារតី ទើបកេណ្ឌទាហានឡើងរក្សាសើនបន្ទាយជាមាំមួន អៀវស៊ុនឃើញដូច្នោះ ទើបក្លែងកេទនិយាយនឹងទៀវឡូថា ដែលនឹងស្ងៀម នៅដូច្នេះមិនស្រួលទេ ព្រោះសត្រូវមកតាំងនៅព័ទ្ធជុំវិញស្រុកហើយ ខ្ញុំបាទនឹងសុំរក្សាស្រុកទុក ឯខ្លួនលោកត្រូវចេញទៅធ្វើសង្គ្រាមតនឹងចូឆូទើបសមគួរជាជាតិទាហាន ទាំងឈ្មោះសម្តេងលោក ក៏នឹងល្បីតទៅមុខវែងឆ្ងាយ ។

ទៀវឡូមិនដឹងកលឧបាយ ក៏រៀបទាហានលើកចេញ ឯទាហានដែលចេញទៅជាមួយនឹងទៀវឡូនោះ ក៏ត្រឡប់វិលទៅនៅរក្សាគ្រប់គ្រួក្នុងស្រុកវិញទាំងអស់ ទៀវឡូឃើញដូច្នោះក៏រឹតតែភ័យណាស់ ទើបញាក់សេះបែរត្រឡប់រត់ទៅដល់ជើងកំផែងស្រុក ចូឆូឃើញដូច្នោះ ក៏លើកទាហានដេញតាមទៅ ។

អៀវស៊ុននៅលើសើនបន្ទាយ ឃើញទៀវឡូរត់ត្រឡប់មកក៏ឲ្យ

ទាហានបិទទ្វារស្រុកជិតនឹងចូលពុំបាន ចូឆូឃើញក៏ស្រែកទៅទៀវឡូថា ខ្លួនអ្នកឯងនឹងដល់សេចក្តីស្លាប់ហើយគ្រានេះ បើប្រសិនជាចូលមកលន់តួ ចុះចូលយើងតាមសុភាព យើងក៏ទុកជីវិតឲ្យរស់នៅតទៅ ៗ ទៀវឡូឮ ដូច្នោះ ក៏លោតចុះពីលើសេះបោះអាវុធចេញពីដៃ ហើយដើរចូលទៅ គំនាប់ចូឆូ ៗ ក៏មានចិត្តអាណិតអាសូរណាស់ ទើបនាំទៀវឡូចូលទៅក្នុង ស្រុកប៉ាគុង ហើយតាំងទៀវឡូឲ្យធ្វើជាចៅហ្វាយស្រុកប៉ាគុង បណ្តាទាហានរបស់ទៀវឡូនោះ ចូឆូក៏តាំងឲ្យធ្វើការតាមធំ-តូច តាមគុណបំណាច់ ៗ

ចូឆូប្រាបប្រាមអាណាខេត្ត ដែលឡើងស្តាប់បង្គាប់ស្រុកហាន់តុងនោះរាបទាបទាំងអស់ហើយ ក៏ចែកបំណាច់រង្វាន់ពលទាហានតាមសមគួរ ហើយឲ្យគេហៅខ្លួនអៀវស៊ុងចូលទៅប្រាប់ថា ខ្លួនអ្នកឯងជាមនុស្សលោភលាភសក្ការៈអកតញ្ញូនិរគុណគេពេកណាស់ ឃើញតែត្រឹមរបស់ទ្រព្យជាមុខ គួរប្តូមកប្រែចិត្តក្បត់ទៀវឡូដែលមានគុណលើខ្លួន បើយើងនឹងចិញ្ចឹមរក្សាខ្លួនជាពួកផងតទៅមុខទៀត ខ្លួនក៏គង់នឹងប្រែចិត្តគិតប្រទូស-រាយដល់យើង ទៅចូលខាងសត្រូវដូចជាគ្រាឥឡូវនេះដែរ ថាហើយក៏ប្រើទាហានចាប់យកខ្លួនអៀវស៊ុងទៅចងក្នាងកាត់ក្បាលសម្លាប់បង់ ហើយយកក្បាលដោតផ្ចាលមិនឲ្យអ្នកទាំងពួងយកតម្រាប់តាម កាលចូឆូប្រាប់ប្រាមស្រុកហាន់តុងនឹងអាណាខេត្តដែលឡើងទាំងប៉ុន្មាននោះ មនុស្ស

ទាំងពួងក៏សន្មតហៅទីដែននោះថា តាំងឈ្នួន គឺជាផ្លូវដាច់ស្រយាលខាងទិសបូព៌ ។

## សាមកុកខ្សែ ៥៦

តាំងពីសុម៉ាអ៊ីពន្យល់ឲ្យចូចូលើកទ័ពទៅវាយយកស្រុកសែឈ្នួន ចូចូមិនព្រម រហូតដល់ចូចូឲ្យសម្លាប់ពួកនាម៉ឺនក្នុងស្រុកហ៊ូតោ ដែលផ្សាយលត់ភ្លើងពួកក្បត់ ៣០ នាក់ ។

ខណៈនោះ សុម៉ាអ៊ីបានចូលទៅនៅនឹងចូចូតាំងពីនៅស្រុកហ៊ូតោ ចូចូឲ្យសុម៉ាអ៊ីជាសមុហបញ្ជីគូនទាហាន ។ សុម៉ាអ៊ីចូលទៅគំនាប់ចូចូ ហើយថា គ្រានេះ វ៉ុយកុងលើកទ័ពមកវាយបានស្រុកហាន់តុងហើយ ខ្ញុំបាទឮកិត្តិសព្ទថា ឡេវពីបានស្រុកសែឈ្នួនហើយ បណ្ដេញឡេវជៀងចេញពីស្រុកទៅ អាណាប្រជានុរាស្ត្រទាំងពួងដែលនៅក្នុងស្រុកសែឈ្នួននោះនៅមិនទាន់ជាប្រក្រតីនឹងឡេវពីទេ ដែលលោកលើកទ័ពមកដល់ទីនេះហើយ ក៏ជាផ្លូវដាច់ស្រយាលឆ្ងាយណាស់ បើនឹងលើកទ័ពត្រឡប់ទៅវិញក៏មិនគួរសោះ កាលណាឡើយនឹងបានលើកមកទៀត សូមឲ្យលោកលើកទៅវាយយកស្រុកសែឈ្នួនឲ្យបានក្នុងគ្រានេះតែម្តងទៅ រួចសឹមលើកត្រឡប់ទៅវិញ ។

ចូចូឮដូច្នោះ ក៏ធ្វើជាដកដង្ហើមធំហើយក្លែងថា ធម្មតាកើតមកជាមនុស្សនេះ កាលដើមនឹងគិតថារកតែមួយ លុះបានរួចហើយក៏គិត

កំរើបនឹងរកឲ្យបាន ២ តឡើងទៅ ព្រោះសេចក្ដីលោភ ដូចជាបានស្រុកហាន់តុងហើយថែមតាំងចង់បានស្រុកសៃឈួនទៀត ស្រុកទាំងនេះសុទ្ធតែផ្លូវដាច់ស្រយាលឆ្ងាយណាស់ ។

ឡៅហួថា ដែលសុម៉ាអ៊ីនិយាយនោះ គួរប្រពៃណាស់ បើលោកនឹងបង្អង់ទុកឲ្យយូរទៅ ខុងបេងគង់នឹងមានសតិបញ្ញារិះគិតបញ្ចុះបញ្ចូលបណ្ដារាស្ត្រក្នុងស្រុកសៃឈួនឲ្យមានចិត្តប្រក្រតីស្រួលទៅ ទាំងគួនអ៊ូទៀតហើយ ដូខ្យុង សឹងតែជាតាហានឯកនឹងតាហានក្រៅពីនេះក៏មានច្រើនអនេកណាស់ បើលោកនឹងលើកទៅវាយយកជាក្រោយក៏ដោយសេចក្ដីលំបាកៗ បួនគុបថា យើងលើកមកគ្រានេះ ផ្លូវក៏ដាច់ស្រយាលឆ្ងាយណាស់ ប្រការមួយទៀត បានស្រុកហាន់តុងហើយ តាហានក៏កំពុងហត់នឿយ ដែលនឹងលើកទៅវាយស្រុកសៃឈួនទៀតនោះ យើងមិនទាន់ឃើញផងទេ ហើយក៏តាំងបម្រុងសេនាតាហាននៅក្នុងស្រុកប៉ាតុង ។

ឯអស់អាណាប្រជារាស្ត្រក្នុងស្រុកសៃឈួន នឹងបណ្ដាអាណាខែត្រដែលឡើងតាំងប៉ុន្មាន លុះបានដឹងកិត្តិសព្ទថា បួនលើកកងទ័ពមកវាយយកស្រុកហាន់តុងបានដូច្នោះ ទាំងអស់គ្នានោះក៏នាំគ្នាតក់ភិតភ័យខ្លាចបួនពន់ប្រមាណ ក្រែងបួននឹងរុករានខុនស្រានលើកទ័ពទៅវាយយកស្រុកសៃឈួនទៀត ។ ឡៅពីដឹងថាបណ្ដារាស្ត្រទាំងពួងតក់ស្លុតភិត

ភ័យខ្លាចដូច្នោះ ក៏ពិគ្រោះសួរខុងបេងថា បណ្តាស្រុកក្នុងស្រុកយើង ខ្លាចបច្ចុទឹងលើកទ័ពមកធ្វើអន្តរាយ ដូច្នេះលោកទឹងត្រិះរិះគិតប្រការម្តេច?

ខុងបេងថា នេះលោកកុំព្រួយចិត្តឡើយ ខ្ញុំទឹងគិតកលឧបាយមិនឲ្យបច្ចុលើកទ័ពមកធ្វើអន្តរាយដល់ស្រុកយើង ទឹងឲ្យលើកទ័ពត្រឡប់ទៅវិញ ។ ទៀតពីសួរថា លោកទឹងគិតប្រការម្តេច? ខុងបេងថា ឯបច្ចុនោះ រមែងខ្លាចញញើតស៊ុនកួនជាដរាប បានជាឲ្យហៃហ្វិនទឹងទៀវលៀវទៅឈរស្រុកហាប់ប៉ា កាលបច្ចុលើកកងទ័ពមកវាយយកស្រុកហាន់តុងនេះ ក៏យកហៃហ្វិនមកផង ១ នេះសូមឲ្យលោកចាត់ប្រើរណា ដែលមានគម្រោះប្រាជ្ញាឲ្យទៅនិយាយទឹងស៊ុនគួនថា ទៀតពីទឹងឲ្យស្រុកកាំងហែ ស្រុកទៀវសា ស្រុកហ៊ុយអៀងមកជូនលោកហើយញុះញង់ឲ្យស៊ុនគួនលើកទ័ពទៅវាយយកស្រុកហាប់ប៉ា បើបច្ចុដឹងវេលាណា ក៏ទឹងកន្លល់វល់ចិត្តគិតលើកទ័ពទៅជួយគ្នាជាប្រាកដ ។

(នៅមានត)

# ព្រះរាជនិពន្ធរាមកេរ្តិ៍

## អារម្ភកថា

ស្រាវជ្រាវដោយ លោក ឌុ-គាម (ត)

---

នឹងសំដែងរឿងអសុរព្រហ្មនៅក្នុងក្រពឿ ក្នុងចិត្តប្រាថ្នាចង់បានខ្លាំងពូកែឲ្យលើសជាងទេវបុត្រទេវតា ព្រះឥន្ទព្រះព្រហ្មយមយក្សទាំងពួង ហើយក៏ខំស្វាហាប់ឡើងទៅគាល់បំរើព្រះឥសូរញយ ៗ ជាយូរឆ្នាំអង្វែង លុះមានសម័យថ្ងៃមួយ អសុរក៏គិតក្នុងចិន្តាថា អញនឹងទៅគាល់ព្រះឥសូរជាម្ចាស់សូមពរឫទ្ធិ អំពីព្រះអង្គឲ្យបានដូចសេចក្ដីប្រាថ្នាហោង ៗ អសុរគិតហើយ ក៏តែងគ្រឿងប្រដាប់ស្រេចហើយ ក៏ហោះឡើងទៅដល់ភ្នំកៃលាស ចូលទៅគាល់ព្រះឥសូរជាកំពូលភ្នំត្រ័យ ហើយអសុរ ក៏ក្រាបថ្វាយបង្គំទូលថា ខ្ញុំព្រះករុណានេះខំស្វាហាប់គាល់ហៅបំរើព្រះបាទជានិរន្តរ៍ ទ្រង់ព្រះករុណាក៏មិនដែលប្រទានរបស់អ្វីឲ្យទានទោះក៏គ្មាន ឥឡូវនេះទូលព្រះបង្គំជាខ្ញុំសុំព្រះកជទានដំបងពេជ្រមួយ ហើយនិងពរកុំឲ្យអ្នកណាតឫទ្ធិបានឡើយ តាមតែទ្រង់ព្រះមេត្តាប្រោស ៗ កាលនោះ អង្គព្រះសយម្ភូញាណបានស្ដាប់វាចាអសុរ សូមដូច្នោះហើយ ក៏មានព្រះកាយនោះអាសូរករុណាណាស់ ទើបប្រទានដំបងពេជ្រ ១ ហើយទ្រង់ប្រសិទ្ធិពរឲ្យអសុរ ចូរអ្នកខ្លាំងពូកែដូចសេចក្ដីប្រាថ្នា ឲ្យឈ្នះអស់បច្ចាមិត្រទាំង ១០ ទិស កុំឲ្យមកតតឫទ្ធិអានុភាពនិងអ្នកបានឡើយ ៗ អសុរព្រហ្មក៏ក្រាប

ថ្វាយបង្គំទទួលយកដំបងពេជ្រទិងពារស្រេចហើយ កំមានចិត្តនោះត្រេកអរណាស់ ក៏ថ្វាយបង្គំលាហោះតាកស្ពានកៃលាស ហើយក៏ទ្រង់សំដែងឫទ្ធិអានុភាពវិលមុកស្ពានពិមានអាត្មាវិញហោង ៗ ឈប់ស្ងេះ ៗ នឹងសំដែងពីព្រះបាទ មាលីវត្តព្រហ្ម លុះឃើញព្រះឥសូរជាម្ចាស់ទ្រង់ប្រទានដំបងពេជ្រទិងពារឲ្យអាសុរព្រហ្មដូច្នោះហើយ ក៏មានចិត្តនោះភ័យបារម្ភណាស់ ត្បិតចិត្តអសុរនេះ វាកាចឃោរឃៅអប្រិយណាស់ វានឹងធ្វើបាបអស់ទេវលោកគ្រប់ស្ថាន ទ្រង់គិតដូច្នោះហើយ ក៏ក្រាបទូលព្រះឥសូរថាដែលព្រះអង្គទ្រង់ប្រទានដំបងពេជ្រទិងពារទៅអសុរនោះ ខ្ញុំពាជាអ្នកចិត្តបាបឫស្យាម៉ិច្ឆាទិដ្ឋិ ឃើញជាវានិងបៀតបៀនត្រៃលោក នឹងបានសេចក្តីក្តៅក្រហាយ ពុំនោះទឹងដល់ទៅព្រះបាទអដ្ឋបាលដែលគ្រងរាជ្យនៅនគរស្រីអយុធ្យាជាកវតីនឹងតដៃនិងវាពុំបាន ដូច្នេះសូមទ្រង់ព្រះករុណាប្រទានទេពអាវុធបាន១ គ្រាន់នឹងបានបង្ក្រាបអសុរព្រហ្មតទៅ ត្រៃលោកនឹងបានជាទីពឹងព្រះបារមីផង ៗ កាលនោះព្រះឥសូរបានស្តាប់មាលីវត្តព្រហ្មទូលដូច្នោះហើយ ក៏មានព្រះទ័យនោះគិតដល់ព្រះបាទអនោមាទត្តជាអនិច្ចាអើយ រីឯព្រះនារាយណ៍នេះអញក៏ភ្លេចសោះ កាលដើមឡើយអញបានឲ្យអនោមាទត្តសោយរាជ្យនៅជម្ពូទ្វីប ឥឡូវនេះក៏សុគតទៅនៅតែព្រះរាជបុត្រឲ្យសោយរាជ្យស្នងគ្រប់គ្រងនគរតទៅ អញភ្លេចសោះមា-លីវត្តព្រហ្ម កុំតែឯងថាទើបនឹកឃើញ ត្រាស់ហើយទើបឲ្យព្រះខ័នមួយ

ហើយប្រសិទ្ធីពរឲ្យឈ្នះលើដំបងពេជ្រអសុរព្រហ្ម ហើយក៏ឲ្យទៅមាលីវគ្គព្រហ្មយកទៅឲ្យព្រះបាទអជ្ជបាលហោង ។ ព្រះបាទមាលីវគ្គព្រហ្មក៏ទទួលយកព្រះខ័នទៅថ្វាយព្រះបាទអជ្ជបាល លុះហោះទៅដល់នគរព្រះបាទអជ្ជបាល នៅកណ្ដាលអាកាស បំពោះត្រង់បង្អួចទ្វារប្រាសាទ ហើយក៏ស្រែកប្រាប់ទៅថា ណែព្រះបាទអជ្ជបាលអើយ ឥឡូវនេះព្រះឥសូរជាម្ចាស់ត្រាស់ប្រើយើងមក យកព្រះខ័នពេជ្រមួយមកឲ្យអ្នកហោងៗ ព្រះបាទអជ្ជបាលស្ដេចទៅគង់នៅលើប្រាសាទអង្គុយលើបល្ល័ង្កពេជ្រកែវ បានឮវាចាបញ្ចេញឈ្មោះព្រះឥសូរចមកពីកៃលាសដូច្នោះហើយ ក៏អើតមើលទៅតាមបង្អួចទៅឃើញមាលីវគ្គព្រហ្មហើយ ក៏មានព្រះឱង្ការសួរទៅថាព្រះចមលោកនាថកៃលាសត្រាស់ថាដូចម្ដេច សូមអញ្ជើញអ្នកចុះមក មាលីវគ្គព្រហ្មបានស្ដាប់ហើយ ក៏ហោះចុះមករួចគង់អាសនៈជាមួយនិងគ្នាហើយក៏ធ្វើគារវៈនិងគ្នាស្រេចដោយស្មោះសរគ្រេកអរ ៗ ព្រះបាទអជ្ជបាលក៏មានវាចាសួរទៅថាព្រះឥសូរជាម្ចាស់ត្រាស់ប្រើអ្នកមកនោះមានធុរៈការដូចម្ដេចខ្លះ ហើយអ្នកនាមាឈ្មោះអី ៗ កាលនោះព្រះបាទមាលីវគ្គព្រហ្មបានស្ដាប់ហើយ ក៏តបវាចា ខ្ញុំនេះឈ្មោះមាលីវគ្គព្រហ្មខ្ញុំបានឡើងទៅគាល់ព្រះឥសូរ ហើយមានអសុរព្រហ្មមួយវាទៅសូមដំបងពេជ្រពីព្រះអង្គ ១ ក៏ឲ្យទៅវា បានជាខ្ញុំនេះមានសេចក្ដីភ័យពីព្រះអង្គមានសេចក្ដីភ័យខ្នក់បារម្ភណាស់ ខ្ញុំក៏ក្រាបទូលព្រះឥសូរជាទ្រង់ព្រះករុណា

ប្រទានដំបងពេជ្រនិងពរឲ្យវាំ រីអសុរព្រហ្មនេះឃើញថាវាំទឹងបៀត បៀនត្រ័យលោកទាំង ៣ មិនតែម្ទោះឡើយ វាំនីងមកបំផ្លាញដល់អ្នកទៀត ទើបខ្ញុំក្រាបបង្គំទូលសុំព្រះច័នពេជ្រឲ្យឈ្នះលើដំបងពេជ្រអសុរព្រហ្ម ព្រះអគ្គីក៏ទ្រង់ប្រទានឲ្យខ្ញុំយកមកជូនអ្នក ។ ព្រះបាទអជ្ជបាលបានស្តាប់សព្វគ្រប់ហើយ ក៏មានព្រះទ័យនោះត្រេកអរណាស់និងព្រះគុណអ្នកជាទីបំផុត ហើយព្រះអគ្គីបែរព្រះកក្រ្ត ត្រង់ទៅស្ថានកៃលាសហើយក៏លើកដៃថ្វាយបង្គំទទួលយកព្រះច័នពេជ្រ ហើយមានពាក្យនិយាយនិងព្រះបាទមាលីវត្តព្រហ្មថា យើងទាំងពីរនាក់នេះសូមមេត្រីជាមិត្តនិងគ្នាដល់យាវជីវិតទៅហោង ។ កាលនោះ ព្រះបាទមាលីវត្តព្រហ្មទទួលសច្ចាប្រណិធាននិងគ្នា ហើយក៏លាវិលទៅស្ថានអាត្មាវិញហោង ។

នឹងនិយាយពីអសុរព្រហ្មនោះ តាំងតែពីបានដំបងពេជ្រថ្ងៃណាហើយ ក៏មានចិត្តនោះមិច្ឆាទិដ្ឋិលោកលន់ពន់ប្រមាណ គិតចង់ទៅបង្ក្រាបឲ្យរាបដោយអំណាចប្ញទ្ធិអានុភាពទាំង ១០ ទិស គិតដូច្នោះហើយអសុរ-ព្រហ្ម ក៏សំដែងប្ញទ្ធិហោះទៅកណ្តាលអាកាស ហើយស្រែកប្រកាសថាខ្លួនអញឈ្មោះអសុរព្រហ្ម មានប្ញទ្ធិអានុភាពគ្មានអ្នកណាស្មើបាន ឥឡូវនេះអញនឹងបំផ្លាញត្រ័យលោកទាំង ៣ ឲ្យវិនាសដោយប្ញទ្ធិអញហោង ។ ស្រែកហើយក៏សំដែងប្ញទ្ធិដេញវាយអស់ទេវលោកគ្រប់ស្ថាន ទាំងគន្ធនសុបណ្ណគ្រុឌមហាឥសីជាកោលាហល ។ រីអស់ទេវលោកគ្រប់ស្ថាននូវពិ-

ទ្យាធរកិន្នរនាគគន្ធព្វ គន្ធធ័ សុបណ្ណគ្រុឌមហាឥសីទាំងអស់នោះ ក៏ភ័យតក់ស្លុតរន្ធត់រត់ពោលស្ថានសីមាគាត់ទីទៃ ៗ ហើយមកប្រជុំគ្នា ហោះទៅឯនគរព្រះបាទអដ្ឋបាល ទូលថាអសុរព្រហ្មកំណាចវាឡើង ទៅធ្វើបាបយើងកល់គ្នា ឥឡូវនេះវានៅ ៗ ដើនក្តៅកៃណាស សូមព្រះអង្គអញ្ជើញទៅបង្ក្រាបប្រាប់អសុរ ជួយទម្លាប់ឲ្យត្រ័យលោកបានសេចក្តីសុខសប្បាយដោយបុណ្យបារមីព្រះអង្គហោង ៗ ព្រះបាទអដ្ឋបាលបានស្តាប់អ្នកទាំងអស់ទូលដូច្នោះហើយ ក៏ខឹងក្រោធនិងអសុរព្រហ្មណាស់ ព្រះអង្គក៏ស្តេចយាងទៅហោង លុះមកដល់ហើយ អសុរព្រហ្មក៏ក្រឡេកឃើញព្រះអង្គហើយ ក៏ស្ទុះទៅឈរទាំងពាំងពីមុខរាជរថ ហើយក៏ស្រែកថា អ្នកណាក៏អាចហ៊ានមកតវ៉ានិងអញ មិនខ្លាចស្លាប់ទេ ឬ ថាហើយ អសុរព្រហ្មក៏ក្រេវក្រោធណាស់ ក៏ស្ទុះហោះទៅថា ឯងនេះនាមករឈ្មោះអ្វី ជាតិឯងជាមនុស្សក៏មានចិត្តអហំការមកតបេស្តា ត្រៃលោកទាំង ៣ ក៏បាក់បបខ្ទបខ្លាចអំណាចបារមីឫទ្ធិអញទាំងអស់ហោង ខ្លួនឯងនេះជាមនុស្សតូចណាស់ ប្រៀបដូចអំពិលអំពែក ក៏ហ៊ានមកផ្តាញ់ពន្លឺព្រះអាទិត្យ ជីវិតឯងឃើញជាក្ស័យនឹងដៃអញពុំលែងឡើយ ៗ រីឯព្រះបាទអដ្ឋបាលបានស្តាប់ពាក្យអាសុរហើយក៏ទ្រង់ក្រោធ ទើបស្តេចមានព្រះបន្ទូលតបទៅថា ឯងឬឈ្មោះអសុរព្រហ្ម ឯងកុំអាលអួតឫទ្ធិឡើយ ឯងនេះប្រៀបដូចជាសត្វអម្រឹគា កាលណាឡើយក៏មកអួតចន់ប្រឡងឫទ្ធិនឹងស្តេចរាជ

សម័ហ៍ដូចម្ដេចបាន ខ្ញុំអញនេះឈ្មោះព្រះបាទអជ្ជបាលធិបតីគ្រង៍បូរីស្រី អាយុធ្យាធាកវតី មហាឥសីទេវលោកគ្រប់ស្ថានបានអញ្ជើញអញមក ប្រហារជីវិតអាឯង៍កុង៍គ្រានេះៗ អសុរព្រហ្ម បានស្ដាប់ហើយក៏ក្រេវក្រោធ ណាស់ ទាំមាត់សង្កៀតធ្មេញហើយក៏ស្ទុះឡើង៍ទៅលើរាជរថព្រះអង្គប្រាំង៍ គ្នា លុះតតាំង៍គ្នាបន្តិចទៅ ព្រះបាទអជ្ជបាល ក៏ចាប់សម្លាប់អសុរព្រហ្ម ស្លាប់ទៅដោយបុទ្ធបារមីព្រះអង្គហោង៍ ៗ កុង៍គ្រានោះ អស់ពួកទេវ លោកគ្រប់ស្ថាន បានឃើញវង្សព្រះនាកយណ៍សម្លាប់អសុរព្រហ្មស្លាប់ ដូចសេចក្ដីប្រាថ្នាហើយ ក៏មានសេចក្ដីនោះត្រេកអរសាទរពេកក្រៃទះដៃ ស្រែកឲ្យស័ព្ទសាធុការឲ្យជ័យហើយ ក៏បាចសាចផ្កាចុះមកពេញពាស ទាំង៍ព្រះធរណីហោង៍ ៗ រីព្រះបាទអជ្ជបាលនោះលុះសម្លាប់អសុរស្រេច ហើយ ព្រះអង្គក៏កាត់ក្បាលអសុរព្រហ្មយកមកដាក់នឹង៍កន្ទ្រៃរាជរថ ហើយ ក៏ស្ដេចបររាជរថហោះមកនគរវិញ ដល់ហើយក៏ស្ដេចយកក្បាលអសុរ ព្រហ្មនោះមកដោតទុកនឹង៍សួនឧទ្យាន ហើយទ្រង៍ដាក់បណ្ដាសាឲ្យចាំ សួនឧទ្យាន ដូចព្រះឱស្ឋព្រះអង្គថា ខ្មោចអសុរក៏នៅចាំរក្សាសួន ព្រះអង្គហោង៍ ៗ

និយាយពីព្រះបាទមាលីវត្តព្រហ្មរាមពង្សវង្សា និង៍ព្រះបាទចតុរក្ត្រ ដែលសោយរាជ្យនគរក្រុង៍លង្កាទ្វីប តាំង៍តែព្រះអង្គបានមិត្តរួមជីវិតនិង៍ ព្រះបាទអជ្ជបាលដែលគ្រប់គ្រង៍នគរស្រីអយុធ្យា តាំង៍ចិត្តសុចរិតនិង៍

គ្នា ទើបស្តេចឡើងទៅគាល់ព្រះឥសូរឯស្ថានកៃលាសបព៌ត ។ លុះមកដល់ហើយ ព្រមទាំងហ្វូងទេពទេវនគន្ធព្វកិន្នរនាគ តាបសឥសីប្រជុំ ព្រមព្រះបាទមាលីវត្តព្រហ្ម ក៏ក្រាបថ្វាយបង្គំទូលទៅព្រះឥសូរថាទូលព្រះបង្គំជាខ្ញុំសុំឲ្យមានមាត់ទិព្វដូចសេចក្តីប្រាថ្នា ។ កាលនោះ ព្រះសយម្ភូវនាថបានស្តាប់ហើយព្រះអង្គទ្រង់រំពឹងដោយទិព្វញាណទៅទ្រង់ជ្រាបថា ព្រហ្មនេះមានសេចក្តីកាន់សត្យសុចរិតពិតត្រង់ គួរអញនឹងប្រសិទ្ធពរឲ្យ គិតហើយព្រះអង្គទ្រង់ប្រទានពរឲ្យសំរេចដូចសេចក្តីប្រាថ្នាអ្នកហោង ។ ហើយព្រះអង្គទ្រង់ឲ្យនាមឈ្មោះជាមាលីវករាជវិញហោង ហើយឲ្យធំលើអសុរគព គ្រប់ទាំងទេពទាំងអស់ហោង ព្រះបាទមាលីវករាជបានពរប្រសិទ្ធពីព្រះឥសូរហើយក៏ត្រេកអរ ក្រាបថ្វាយបង្គំលាវិលមកស្ថានអាត្មាវិញហោង ។

និងសំដែងពីព្រះបាទសហមាលីវនយក្សា ដែលត្រងក្រុងលង្កាមកពីមុននោះ កាលរត់ខ្លាចអំណាចចក្រពេជ្រព្រះនារាយណ៍នោះ ទៅនៅឯបាតាលព្រះអង្គជាពូជពង្សវង្សនឹងព្រហ្ម បានដឹងថាព្រះបាទសហម្បតិ-ព្រហ្មចុះមកសាងនគរលង្កាទ្វីបជាថ្មីទៀត ឲ្យធតាព្រហ្មសោយរាជសម្បត្តិ ដែលធតាព្រហ្មនោះត្រូវជាពូជពង្សវង្សានិងគ្នាទ្រង់នាមាថាព្រះបាទចតុរភក្ត្រ នោះសហមាលីវនមានសេចក្តីត្រេកអរណាស់ ត្បិតបានធតាព្រហ្មនេះប្រសើរណាស់ នឹងបានជាលក្ស្មណ៍ផែនដីតពង្សវង្សត្រកូល ដូច្នេះគួរអញនឹងឡើងទៅឯក្រុងលង្កាទ្វីប គិតហើយក៏បង្គាប់ប្រាប់ទៅសេនា

អាមាត្យឲ្យរៀបចំបុស្សបុករ័ត្នកែវ នឹងហៅពលសកលយោធាស្រេច ស្តេច
ចាប់ដំបងពេជ្រហើយហោះមកដល់ក្រុងលង្កាទ្វីប ព្រះបាទចតុរកក្រ្ត
ឃើញព្រះសាហាយមកដូច្នោះ ហើយក៏ទទួលតំនាប់គ្នា ហើយក៏ទាញដៃ
ឲ្យឡើងមកគង់បល្ល័ង្កជាមួយនឹងគ្នា រីសហមាលីវ័នក៏ទបព្រះបាទចតុរកក្រ្ត
ហើយក៏ស្រក់ទឹកភ្នែកព្រះនេត្រា ត្រាស់ថាខ្ញុំនេះបានសេចក្តីលំបាក
តោកយ៉ាកណាស់ ត្បិតអង្គព្រះនារាយណ៍លោកធ្វើបាបផ្ដន្ទាមិនឲ្យដំនា-
ទិស ខ្ញុំបានជាធំនៅក្នុងក្រុងលង្កាទ្វីប បានជាខ្ញុំនាំគ្នារត់ទៅនៅឯនគរ
ក្រុងបាតាលវិញ លុះខ្ញុំបានដឹងដំណឹងថា ព្រះបាទសហម្បតិមហាព្រហ្ម
លោកឲ្យចុះមកសាងជាទីលង្កាទ្វីប ឲ្យអ្នកមកគ្រងរាជសម្បត្តិជាថ្មីទៀត
នោះ ខ្ញុំមានសេចក្តីត្រេកអរសោមនស្សណាស់ទើបបានជាខ្ញុំឡើងមករក
សម្លាញ់ ដោយសារខ្ញុំពានទៅមករកគ្នាជាយូរអង្វែង ៗ កាលនោះ ព្រះ
បាទចតុរកក្រ្ត បានស្តាប់ព្រះបាទសហមាលីវ័ននិយាយប្រាប់ពីដើមរៀងមក
មិនអាចនឹងទប់ទល់ដំកល់អាត្មាភាពពុំបានក៏សោយសោកា រួចស្រេចក៏
មានពាចា អនិច្ចាអើយមិនគួរឲ្យដល់ម៉្លឹង ឯព្រះអង្គជាពង្សវង្សព្រហ្ម ក៏
ព្រះអង្គមានសេចក្តីព្រួយគ្រប់ទិវារាត្រី បានចុះមកកសាងក្រុងលង្កាទ្វីប
ទៀត ឲ្យខ្ញុំមកសោយរាជ្យតពូជពង្សវង្សក្នុងនគរក្រុងលង្កាទ្វីបទៅហោង
ចូរអ្នកអញ្ជើញមកនៅជាមួយនឹងខ្ញុំ នឹងបានបំរុងរក្សាអាណាចក្រជាសុខ
ក្សេមក្សាន្តក្នុងខែត្រខ័ណ្ឌពន្ធសេមាលង្កាទ្វីប ៗ ព្រះបាទសហមាលីវ័ន

បានស្តាប់ហើយក៏មានសេចក្តីត្រេកអរដូចបានទិព្វវិមកសេពសោយ  ក៏ទ្រង់ទូលព្រះបាទចតុរកក្រ្តជាសម្លាញ់ថា  ខ្ញុំអរគុណនិងអ្នកហើយ ឥឡូវនេះខ្ញុំគ្មានរបស់អ្វីជូនសម្លាញ់  មានតែបុស្បុកកែវមួយនេះមានឫទ្ធិវិសេសផ្សេងៗ ជូនសំឡាញ់ឯង ទុកជាកេរ្តិ៍ក្នុងព្រះនគរតរៀងទៅមុខទុកតាងជំនួសខ្លួនខ្ញុំ ឯបុស្បុកកែវនេះ បើតែសត្រូវមេម៉ាយនោះជិះហើយ មិនអណ្តែតលឿនទៅឡើយ តែក្រៅពីនោះតាមចិត្តប្រាថ្នា  ទីងបង់ទៅទីស្ថានណាក៏ដូចចិត្តប្រាថ្នាហោង ។ ព្រះបាទចតុរកក្រ្ត  មានព្រះទ័យនោះត្រេកអរក្រៃណាស់  ទទួលយកបុស្បុកកែវមណីហើយថាសម្លាញ់ឲ្យខ្ញុំ ។  អរខិងព្រះគុណអ្នកណាស់ ។  ស្រេចហើយសហមាលីវនកំលាត្រឡប់វិលមកកាន់នគរវិញហោង ។ ព្រះបាទចតុរកក្រ្តយក្សាសោយរាជសម្បត្តិបាន៦ម៉ឺនឆ្នាំក៏សុវណ្ណគតទៅ  ឡាក្សទៀនជាព្រះរាជបុត្របានគ្រងរាជ្យសោយសម្បត្តិជាធំក្នុងក្រុងលង្កាទ្វីប  មានមហេសី៤ អង្គសុទ្ធតែទ្រង់លក្ខណានាមនាងជាធំនោះនាងដារីសុមន្ទា  បន្ទាប់នោះឈ្មោះនាងចិត្តមាលី មួយមកទៀតឈ្មោះនាងសុវណ្ណម៉ាឡៃ  មួយមកទៀតឈ្មោះនាងប្រថៃស៊ីមួយឈ្មោះនាងរដ្ឋតាទេវី  គ្រប់តាំង៤ នាក់សុទ្ធតែមានរូបឆោមឆាយល្អល្អះដូចទេពកញ្ញាធិតាស្រីសួគ៌  ព្រះបាទឡាក្សទៀនសោយរាជ្យក្នុងក្រុងលង្កាទ្វីប ទ្រង់តេជានុភាពល្បីខ្ចរខ្ចាយសាយសព្វជាទី ព្រះអង្គគង់ជាសុខក្សេមក្សាន្តរៀងទៅហោង ។ កាលនោះ ព្រះបាទមាលីរាជដែល

ស្ថិតនៅកំពូលភ្នំយុគន្ធរ មានសេចក្ដីរលឹកនឹកដល់ព្រះបាទចតុរកេក្រជា វង្សព្រហ្ម គិតហើយព្រះអង្គក៏ហោះចុះមកកាន់នគរលង្កាទ្វីប ។

( សូមចាំអានភាគ ២ តទៅទៀត)

# ១៥–រឿងកូនអូដ្ឋ

Le Petit chamelon (Conte mongol)

លោក ពៃ-ប៊ុក ប្រែពីភាសាបារាំង

(ក)

មានសេដ្ឋីម្នាក់បានរៀបរាប់ហមង្គលការបុត្រខ្លួន នឹងបុត្រីនៃនាហ៊្មឺន ធំម្នាក់ ហើយបានប្រគល់ទ្រព្យចំណងដៃជាសត្វអូដ្ឋ ស ១០០ ក្បាល ។ បណ្ដាអូដ្ឋទាំងឡាយ មានកូនអូដ្ឋមួយដែលគេផ្ដាច់ដោះពីមេវា តាមទៅជាមួយផង ។

មេអូដ្ឋនឹកកូនខ្លួនដែលឃ្លាតចាកទៅទីឆ្ងាយ កូនអូដ្ឋក៏នឹកមាតាពន់ពេកណាស់ដែរ ! ។

ដល់កូនអូដ្ឋនោះដើរបានបន្តិច ក៏រត់ចេញពីហ្វូងអូដ្ឋទាំងឡាយមានខំណងតែមួយ : ចង់ជួបនឹងមេវា ។ កូនអូដ្ឋនោះក៏បោលយ៉ាងប្រញាប់ប្រញាល់ វេះគេចជ្រកនឹងដើមត្រែង ផ្សៀងត្រចៀកស្ដាប់ក្រែងគេមកតាម ។

កូនអូដ្ឋនឹកសប្បាយក្នុងចិត្តថា : «ជាការស្រួលពន់ពេកដោយបានដេកនៅលើខ្នងមាតា ក្រឡេកមើលក្ដួកមាតាក្ដីជួបព្រះអាទិត្យព្រះចន្ទ្រ ក្រេបផឹកទឹកដោះមាតាមានឧជារសជាយ៉ាងក្រៃលែង ...» ។

កំពុងតែគិតដូច្នេះ កូនអូដ្ឋនោះស្រាប់តែជួបប្រទះនឹងបឹងមួយធំ ដែលខ្លួនមិនអាចនឹងឆ្លងទៅត្រើយម្ខាងបាន ។

កូនអូដ្ឋឈរនៅត្រើង មិនដឹងជាទឹកគិតយ៉ាងណា ... ស្រាប់តែមានត្រីមួយធំផុះពីបឹងនោះមក ។

ត្រីធំនោះមានសមានចិត្តចំពោះកូនអូដ្ឋនោះ ក៏ឲ្យកូនអូដ្ឋជិះលើខ្នងខ្លួនឆ្លងបឹងនោះទៅត្រើយម្ខាង បានសុខក្សេមក្សាន្ត ... ។ តែការសុខនេះ កូនអូដ្ឋបានតែមួយភ្លែត ហើយត្រឡប់បានជួបប្រទះនឹងគ្រោះថ្នាក់មួយទៀតយ៉ាងធ្ងន់ គឺមានអ្នកឃ្វាលអូដ្ឋមួយចាប់យកទៅ ។ អ្នកឃ្វាលអូដ្ឋនោះ បានយកកូនអូដ្ឋទៅចងភ្ជាប់នឹងអូដ្ឋធំមួយ តែកូនអូដ្ឋនោះនឹកមេពន់ពេកក៏បេះតែស្រែកហៅ ។

អូដ្ឋធំនោះបានឮកូនអូដ្ឋពណ៌នា អំពីរឿងរ៉ាវខ្លួនសព្វគ្រប់ ក៏មានសមានចិត្តព្រមទាំងករុណាចំពោះកូនអូដ្ឋ ក៏ខាំខ្សែដែលចងកូនអូដ្ឋ ក៏បណ្ដោយឲ្យកូនអូដ្ឋរត់ទៅរកមេចុះ ។

កូនអូដ្ឋខំបោលរត់ចាកចេញពីទីនោះទៅដល់កន្លែងមេ ។

អូដ្ឋជាមេដោយនឹកកូនពន់ពេក ក៏ទៅផាឈើជិតស្លាប់ខ្លួន ។ ដេកនៅលើស្មៅមេអូដ្ឋមានទឹកភ្នែកហូរហៀរសស្រាកហើយពោលថា :

« ម្ដាយជិតស្លាប់ហើយកូន ! តែក្រោយដែលម្ដាយស្លាប់ទៅ បីយប់ទៀតមានតិណ្ណជាតិ បីដើមដុះលើក្បាលម្ដាយ ។ កូនឯងយកតិណ្ណជាតិនោះមួយដើមពុះជាបីចម្រៀក ហើយឯងបរិភោគទៅ ។ រួចកូនឯងដើរទៅទិសខាងជើង ដើម្បីនឹងទៅនៅជាមួយបងប្អូនឯង ។ ឯបងប្អូន

នោះតូចតែមានសក់កវែង ហើយក៏មានស្បែកពណ៌ស ដូចជាកូនឯងនឹងម្តាយដូច្នោះៗ ឯងរស់នៅជាមួយនឹងបងប្អូនឯង ហើយឯងនឹងបានសុខមួយជីវិត ។

"តែត្រូវឯងចាំបណ្តាំម្តាយកុំភ្លេច ! បើឯងទៅរកបងប្អូនឯង ឯងកុំត្រូវដេកនៅលើភ្នំតូចៗ ឬនៅទីកន្លែងដែលមនុស្សបោះដំរីសម្រាក ត្រូវតែកូនឯងដេកខាងត្បូងបង្កើនភ្នំតូចៗ នោះទើបសុខៗ ម្យ៉ាងវិញទៀតបើឯងបាននៅដល់បងប្អូនឯងហើយ ឯងត្រូវដើរចំកណ្តាលហ្វូងគេទៅទៀត" ។

ក្រោយដែលបានទូន្មានបុត្រដូច្នេះម្តាយកូនអូដ្ឋនោះ ក៏ទទួលមរណភាពទៅ ។

ម្តាយកូនអូដ្ឋស្លាប់បានបីថ្ងៃ មានតិណ្ណជាតិបីដើមដុះលើក្បាលនោះ កូនអូដ្ឋក៏ដកតិណ្ណជាតិទាំងបីដើមមកបរិភោគ ហើយធ្វើដំណើរទៅខាងជើង ដើម្បីនឹងស្វែងរកអូដ្ឋជាបងប្អូនរបស់ខ្លួន ។

តែកូនអូដ្ឋនេះមានបរិយាថ្លៃកបង់ពិសោធលមើលបណ្តាំម្តាយ ក៏គិតថា :

"អញចង់ដេកមួយយប់នៅលើកូនភ្នំនេះ តើវាយ៉ាងណាទៅ" ។

នៅលើកូនភ្នំនោះ មានការយោបក់បោកខ្លាំង ហើយមានអាកាសត្រជាក់រងាពន់ពេក ។

កូនអូដ្ឋនឹកដល់បណ្តាំម្តាយ "ព្រោះហេតុដូច្នេះ បានជាម្តាយអញលោកមិនឲ្យអញដេកលើកំពូលភ្នំតូចនេះ" ។

តែកូនអូដ្ឋនេះ នៅតែមានមនោមានះគិតថា : « អញចង់ដេកនៅជិតជំរំមនុស្សស្រម្រាក » ។ រួចកូនអូដ្ឋនោះក៏ធ្វើតាមដែលខ្លួនគិត ។

តែក្នុងពេលយប់នោះ មានសត្វតិរច្ឆានជាច្រើនមករកសំណល់អាហារ នាំឲ្យខ្លួនដេកមិនបាន ។

កូនអូដ្ឋនឹកដល់បណ្តាំម្តាយ ។

« ព្រោះហេតុដូច្នោះបានជាម្តាយអញបានផ្តាំអញថា កុំឲ្យដេកនៅជិតជំរំមនុស្ស » ។

យប់ទីពីរកូនអូដ្ឋ ទៅដេកលើជំហៀងភ្នំតូចខាងត្បូង ។ យប់នោះកូនអូដ្ឋដេកលក់ស្រួលគ្មានអ្វីជាឧបសគ្គសោះឡើយ ។

ថ្ងៃទីបួនកូនអូដ្ឋនោះ បានទៅដល់ហ្វូងអូដ្ឋ ដែលមានបងប្អូនខ្លួននៅក្នុងហ្វូងនោះ ។

តែកូនអូដ្ឋនៅគិតថា :

« ហេតុដូចម្តេច បានជាម្តាយបង្ខំអញឲ្យដើរតាមក្រោយបងប្អូនអញ ហើយត្រូវតែដើរចំកណ្តាលហ្វូងអូដ្ឋទាំងឡាយនោះជាការចាំបាច់ » ។

កូនអូដ្ឋនោះ ត្រេចទៅពីមុខហ្វូង ហើយត្រូវពួកអូដ្ឋជាមេហ្វូងខាំពីខាងក្រោយ ។

ក្រោយមកទៀត កូនអូដ្ឋនោះដើរពីក្រោយហ្វូងវិញ ហើយមានកូនអូដ្ឋញីមួយខាំពីក្រោយទៀត ។

លំដាប់តមក កូនអូដ្ឋនោះដើរទៅខាងចំហៀងហ្វូងនោះ ក៏ត្រូវប៉ះលើធូលីខ្សាច់ហុយចូលភ្នែកស្ទើរខ្វាក់ ។

កូនអូដ្ឋទើបដឹងខ្លួនជាក់ច្បាស់ ថា ឪពុកម្ដាយថាឲ្យអញដើរចំកណ្ដាលហ្វូងជាការមានសារៈសំខាន់ ហើយពីថ្ងៃនេះតទៅត្រូវតែអញដើរចំកណ្ដាលហ្វូងតរៀងទៅ ។ តាំងពីពេលនោះមកដំណើរការណ៍បានស្រួលសុខសប្បាយ គ្មានអ្វីជាឧបសគ្គមករាំងរាបានឡើយ ។ បងប្អូននៃកូនអូដ្ឋនោះក៏ថែទាំចំបាច់មានស្មៅបរិភោគដ៏បរិបូណ៌ ផឹកទឹកបានតាមបំណង ហើយថែមទាំងបានសវនាការរឿងរ៉ាវ ដែលអូដ្ឋជាបងប្អូនបាននិទានប្រាប់ ។ កូនអូដ្ឋរស់នៅជាមួយបងប្អូនជាសុខក្សេមក្សាន្តជានិរន្តរ៍តរៀងទៅ ។

កូនអូដ្ឋនឹកក្នុងចិត្តថា : « បិតាម្ដាយជាបិតាប្រកបដោយគតិបណ្ឌិត ខ្ញុំសូមសំដែងចំពោះមាតានូវកតញ្ញូតាធម៌យ៉ាងជ្រាលជ្រៅ » ។

រឿងនេះបានគតិដូចខាងក្រោម : « ឪពុកមាតា បណ្ឌិតលោកថា ប្រយោជន៍និរន្តរ៍ បានសុខសួស្ដី ផលល្អគ្រប់គ្រាន់ បិតាសោភ័ណ គួរកាន់ឲ្យខ្ជាប់ » ។

ចប់រឿងព្រេងទី ១៥ រឿងស្ដីពីកូនអូដ្ឋនៅមាន « រឿងទី ១៦ សេចក្ដីយុត្តិធម៌ នឹងប្រាក់ » តទៅទៀត ។

ទំនៀមទម្លាប់ នៃខេមរជាតិ
ខ្មែរគួរខ្មីឃ្មាត សិក្សាពេញទី ។
ព្រោះខេមរជាតិ ជាជាតិសោភី
ក្នុងទ្វីបអាស៊ី តាំងពីព្រេងនាយ ។

ប. ព.

# រឿងត្រពាំងបឹងតេ

(នៅខេត្តកំពង់ស្ពឺ)

*លោក លី-ធាមតេង*

*សមាជិកក្រុមជំនុំ ទំនៀមទម្លាប់ រៀបរៀង*

*នៅក្នុងឃុំសន្ទែសាខប ស្រុកថ្ពង ខេត្តកំពង់ស្ពឺ មានត្រពាំងមួយ អ្នកស្រុកហៅថាត្រពាំង "បឹងតេ" ។ ត្រពាំងនេះមានលក្ខណៈប្លែកដែលនាំឲ្យអ្នកស្រុកជិតខាង និងអ្នកដំណើរណាដែលបានទៅដល់ទីនោះ ចាប់អារម្មណ៍គ្រប់ ៗ គ្នា ។ ទំហំត្រពាំងមិនជាធំប៉ុន្មានទេ ប្រមាណជាមាត់ផ្ទៃ១០០ម៉ែត្រប៉ុណ្ណោះ ។ មាត់ត្រពាំងជុំវិញ មានភក់ជុះខ្លាំងខ្លាប់ពុំដែលសត្វធាតុណាមួយចូលទៅស៊ីរុកកនឡើយ ឯដីត្រង់ជុះភក់នោះមានសភាពទន់ជ្រាយល្មមដើរបាន ឥតផុងជើងទេ តែទៅដល់កណ្ដាលត្រពាំង បែរជាមានត្រើបមួយជុំជុះស្មៅខ្វះភក់ខ្វះ ហើយដីនោះជាភក់ល្បោកស្មោះ ។ បើគេចង់ធ្លងត្រើបនេះ ទាល់តែយកឈើវែង ១ ដាក់គង រួចដើរស្ទួតលើឈើនោះទើបបាន ។ មានអ្នកស្រុកនិយាយបន្ថែមទៀតថា កាលជំនាន់បាក់ងនៅជាអាណាព្យាបាលប្រទេសខ្មែរ*

កាលនោះ បារាំងទៅពិនិត្យមើលប្រុងនឹងធ្វើស្ពានថ្មង ហើយចុកសរសរស្ពានចំកណ្ដាលត្រពាំងនោះ ៗ ពេលនោះគេឃើញមានដូចជាផ្សែងចំហាយហុយ ៗ ចេញពីត្រឹបនេះមក ៗ លុះពិនិត្យសង្កេតក្នុងត្រឹបកណ្ដាលនេះទៅ ឃើញមានថ្មដុំមូល ៗ ជាច្រើនដុំ សំបកក្រៅក្រហម ៗ របៀបដូចជាថ្មបាយក្រៀម ឯសាច់ថ្មខាងក្នុងពណ៌សក្បុះ ហើយនៅចន្លោះៗនោះមានទឹកថ្លាហូរហែង ៗ ចេញពីរន្ធថ្មមកផង ៗ តំរោងការស្ថាបនាស្ពាន ពីជំនាន់នោះក៏ពុំបានសម្រេចឡើយ ៗ

ដោយឃើញមានលក្ខណៈប្លែក ៗ ហើយជាធម្មតា នៅស្រុកខ្មែរយើង តែមានទឹកខ្វង់ពីបូកណាប្លែក ៗ យ៉ាងនេះ ប្រាកដជាមានរឿងព្រេងនិទានប្រចាំទឹកខ្វង់នោះជាមិនខាន ហេតុនេះ ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ ដែលត្រូវការរកឯកសារដំកល់ទុក ក៏បានអំពាវនាវស៊ើបសួររករឿងព្រេងស្ដីពីត្រពាំងបឹងគេនេះឡើង ។ ជាភ័ព្វល្អ លោកជា-ញុញ ស្នងការប៉ូលីស លោកបានយកចិត្តទុកដាក់ការរករឿងនេះផង ព្រោះលោកធ្លាប់ទៅឃើញផ្ទាល់នឹងភ្នែក កាលដែលលោកទៅបំពេញមុខការនៅខេត្តកំពង់ស្ពឺ ៗ មិនយូរប៉ុន្មានលោកយកប្រដាប់ថតសំឡេងមួយមកចាក់ជូនក្រុមជំនុំស្ដាប់ ដែលលោកបានថតសំឡេងរបស់លោក ទូច-ពីន ភ្នាក់ងារប៉ូលិសក្រុងកំពង់ស្ពឺ និទានហូរហែអំពីរឿងព្រេងបឹងគេ ៗ ដំបូងលោក ទូច-ពីន បញ្ជាក់ពីពេលវេលាថា កាលនោះលោកត្រូវ

រាជការខេត្តបានចាត់ឲ្យលោកទៅបំពេញបេសកកម្មតាមស្រុក ឃុំ នានា ជាមួយដំណើរពិនិត្យការនៃលោកប្រមុខខេត្ត ។ ពេលយប់មួយនៅសំណាក់ក្នុងឃុំសង្កែសាខុប លោកក៏បានសួរទៅអ្នកស្រុក ដែលមកចោមរោមថា ពូម៉ង់ណាចេះចាំរឿងព្រេងសុំនិទានមក ចែកចាយគ្នាស្តាប់កែអផ្សុក ។ កាលនោះមានតាម្នាក់អាយុ ៧០ ឆ្នាំ បានឆ្លើយថា គាត់ចេះរឿងត្រពាំងបឹងតេ ព្រោះគាត់ធ្លាប់ស្តាប់ម្តាយគាត់និទានពីដើមមក ។ រឿងនោះ មានសេចក្តីជាសង្ខេបដូចតទៅនេះ ៖

កាលពីបុរាណព្រេងព្រឹទ្ធយូរយារណាស់មកហើយ មានសេដ្ឋីម្នាក់ មានទ្រព្យយ៉ាងស្តុកស្តម្ភ រស់នៅមានកូម៉ករ ត្រង់ត្រពាំងបឹងតេនេះ ។ សេដ្ឋីទាំងពីរនាក់ប្តីប្រពន្ធ ពិតមែនតែសម្បូណ៌សម្បត្តិទ្រព្យមែនហើយ ប៉ុន្តែមានចិត្តកំណាញ់ពន់ពេកណាស់ ។ គោគសម្បត្តិចូលមកទាំងអម្បាលម៉ានមិនហ៊ានចំណាយឲ្យរបេះទៅវិញទេ ទោះបីការចំណាយនោះជាការចាំបាច់យ៉ាងណាក៏ដោយ ហើយពុំសូវចេះយោគយល់មុខអ្នកក្រខ្សត់ទាំងឡាយផង ។ សេដ្ឋីមានកូនពីរនាក់ ប្រុសមួយ ស្រីមួយ ដែលជាទីស្រឡាញ់ពេញចិត្តណាស់ ទៅណាមកណាម្តង ៗ មានរទេះពិសេសដែលបិទមាសដាំពេជ្រដាំត្បូងត្អឹមត្អែង ជាយានយ៉ាងប្រសើរនាំឲ្យអ្នកស្រុកគួទៅ យល់ហើយទឹកស្ញើចដល់គោគសម្បត្តិនៃសេដ្ឋីនេះពន់ពេកមានមនុស្សជាបរិវារនោះ ៥០០ នាក់ ព្រមទាំង គោ ក្របី សេះ ដំរី ៥០០

មួយមុខ ៗ ជាធនធានផង ៗ នៅក្នុងស្រះខាងក្រោយផ្ទះដែលមានទឹកថ្លាធ្វន់ សម្រាប់ជាទីសម្រាកលំហែទុក្ខសោកនៃគ្រួសារសេដ្ឋីនោះ មានចិញ្ចឹមក្រពើមួយយ៉ាងធំ ៗ ប្រមាត់ស្រះមានដំបូលមួយកន្លែងដែលជាទីតាំងខ្ទមអ្នកតា រក្សាក្រពើរក្សាក្បូមករនោះទាំងមូល ៗ គ្រួសារសេដ្ឋីក្តី គ្រួសារអ្នកព្រៀងលានជិតខាងក្តី តែងមកបែបន់អ្នកតានេះឲ្យបានសម្រេចសមប្រាថ្នារៀង ៗ ខ្លួន ៗ

ថ្ងៃមួយសេដ្ឋីនិយាយពិគ្រោះនឹងភរិយាថា ៖

— ឧកាណាអើយ ! កូនប្រុស កូនស្រីយើង ធំល្មមមានគូស្រកររៀងខ្លួនហើយ ប៉ុន្តែខ្ញុំគិតទៅឃើញថា បើយើងទៅដណ្តឹងកូនអ្នកដទៃមកផ្សំផ្គុំនឹងកូនប្រុសយើង ឬទុកកូនស្រីយើងឲ្យជាគូនឹងអ្នកដទៃទៅ ឃើញថាយើងពិតជាពិបាកខាតបង់ចែករំលែកទ្រព្យសម្បត្តិជាមិនខាន ៗ ហេតុនេះ កុំឲ្យពិបាក គួរតែរៀបផ្សំផ្គុំកូនប្រុស កូនស្រីយើងជាប្តីប្រពន្ធតែម្តងទៅ ដើម្បីនៅថែទាំសម្បត្តិយើងតទៅកុំឲ្យពិបាក ៗ

ប្រពន្ធកាលបើបានស្តាប់ហើយ សមនឹងចិត្តមច្ឆរិយៈកំណាញ់របស់គាត់ផង ក៏ព្រមព្រៀងតាមប្តី ហើយក៏ចាត់ធ្វើពេងក្រសាលអញ្ជើញភ្ញៀវជិតឆ្ងាយមកក្នុងពិធីអាពាហ៍ពិពាហ៍កូនប្រុស·ស្រីនេះ ៗ កាន់តែជិតដល់ថ្ងៃណាស់ហើយ ប្រពន្ធសេដ្ឋីនឹកស្តាយប្រាក់កាសដែលនឹងចំណាយទិញម្ហូបអាហារក្នុងពេលរៀបការកូន ទើបគាត់នឹកឃើញគំនិត

មួយ និយាយពិគ្រោះទៅប្ដីវិញថា ៖

- ឱការណាអើយ ! ក្នុងពេលរៀបការកូនយើងនេះ ខ្ញុំស្ដាយប្រាក់កាសទិញជួរម្ហូបអាហារណាស់ បើយើងកាប់គោក្របីក៏ឃើញថានឹងខាតសត្វដែលជួយធ្វើការរកស៊ីយើងដែរ ។ ដូច្នេះ ខ្ញុំយល់ថា បើយើងសំឡាប់ក្រពើដែលយើងចិញ្ចឹមនៅក្នុងស្រះក្រោយផ្ទះ យកសាច់វាមកធ្វើម្ហូបលៀងភ្ញៀវវិញ ខ្ញុំយល់ឃើញថាមិនខាតបង់ឡើយ ព្រោះសត្វថៃ្ងក្រពើគ្មានបានជួយរកស៊ីអ្វីយើងទេ !

សេដ្ឋីឮពាក្យប្រពន្ធ ពេញចិត្តណាស់ ទើបម្នីម្នាហៅឲ្យអ្នកបំរើប្រុងការសំឡាប់ក្រពើយកសាច់ធ្វើម្ហូបតាមគំនិតប្រពន្ធគិត ។

និយាយពីបាវស្រីម្នាក់របស់សេដ្ឋីឈ្មោះនាងតី ដែលជាអ្នកឲ្យអាហារដល់ក្រពើ រាល់ថ្ងៃ យប់មួយនាងយល់សប្ដិឃើញអ្នកតាក្រពើប្រាប់ថា «តីឯងកុំស៊ីការកូនសេដ្ឋីឲ្យសោះហ្នា ព្រោះការនេះគេកាប់ក្រពើយកសាច់លៀងភ្ញៀវហើយ ហើយតីឯងចាំមើលចុះ អ្នកណាស៊ីការនេះខ្វះនឹងឃើញទាន់ហន់ក្ដាមជាមិនខាន» ។ នាងតីភ្ញាក់ឡើងសញ្ជឹងគិតតែម្នាក់ឯង ។ លុះដល់ថ្ងៃគេរៀបការគគ្រឹកគគ្រេង មានភ្ញៀវជិតឆ្ងាយមកអឹងអរ នាងតីគេចវេះចេញពីផ្ទះបាត់ទៅ ។ ពេលកំពុងស៊ីផឹកអឹកធិកជួបជុំគ្នានោះ ស្រាប់តែព្រះធរណីស្រុតទាំងផែនចំត្រង់ផ្ទះសេដ្ឋីដែលកំពុងការកូន លិចបាត់អស់ទៅ ។

នាងគីកាលបើឃើញហេតុកេទអស្ចារ្យដូច្នេះ នាងព្រួយចិត្តរលឹកអាល័យដល់ចៅហ្វាយក្មេងៗ ទាំងពីរនាក់ដែលធ្លាប់មានចិត្តសន្ដោសមេត្តាដល់ខ្លួនកាលពីមុនរៀងមក ៗ ស្មានតែសោកហើយ នាងនឹកដល់គុណអ្នកតាដែលបានមកប្រាប់នាងឲ្យជៀសផុតពីគ្រោះថ្នាក់ ។ ម្ល៉ោះហើយនាងក៏ទៅការសក់ថ្វាយអ្នកតា ជាការតបស្នងសងគុណអ្នកតាវិញ ។ មុននឹងការ នាងចុះទៅក្នុងស្រះកក់សក់ឲ្យជោក គឺស្រះជាលំនៅរបស់ក្រពើប្របនឹងខ្ទមអ្នកតា ។ ហេតុនេះហើយបានជាស្រះនេះ សព្វថ្ងៃអ្នកស្រុកហៅថា «ត្រពាំងកក់» គឺជាត្រពាំងដែលនាងគីកក់សក់ ។ រួចនាងឡើងទៅលើទួលការសក់ទៀត បានជាទួលនេះគេឲ្យឈ្មោះថា «ទួលការសក់នាងគី» ហើយហៅក្លាយ ៗ មកថា «ទួលការគាគី ៗ» ជាប់រហូតសព្វថ្ងៃ ។ ដោយនឹកអាល័យម្ចាស់ស្រី-ប្រុសពុំមានក្លេបនាងគីក៏ទៅតាំងលំនៅ នៅក្បែរកន្ទុងព្រះធរណីស្រូបផ្ទះសេដ្ឋី ហើយដែលស្រុតទៅជាត្រពាំងធំមួយ គឺជាត្រពាំងដែលគេហៅថា «ត្រពាំងថីងគេ-សព្វថ្ងៃនេះ ។ មិនយូរប៉ុន្មានមានបុរសម្នាក់មកទាក់ទងដណ្ដឹងនាងគី ធ្វើជាប្រពន្ធបាននៅជាមួយគ្នាជាសុខសាន្ត ប្រកបរបរដាំដំណាំផ្សេងៗ ។ លុះនាងគីមានផ្ទៃពោះបាន ៦ ខែ បុរសនោះក៏នឹកឃើញនឿយណាយក្នុងកងទុក្ខក្នុងលោកិយ ក៏លួចរត់ចោលប្រពន្ធទៅបួសធ្វើជាអ្នកសច្ចំនៅឯកំខ្ពល ។

ចំណែកនាងគីនាងនៅតែម្នាក់ឯងរហូតដល់គ្រប់ខែហើយ ក៏សំពលបានកូនប្រុសមួយ ។ វេលាប្រសូតបុត្រអ្នកភូមិជិតខាង មកជួយអបអរសាទរ ក៏សន្មតនាមកូនប្រុសនេះថា « បុត្តកុមារ » កាលបើបានចំរើនវ័យបាន ១៣ ឆ្នាំ បុត្តកុមារចេះតែសួររកឪពុក លុះញឹកញយពេកម្តាយក៏ប្រាប់ត្រង់ថាៈ ឪពុកឯងទៅបួសចម្រើនភាវនានៅភ្នំខ្លោលនោះទៅហើយ បើឯងចង់ឃើញត្រូវដើរស្វែងរកក្នុងព្រៃនោះទៅ កាលបើឃើញហើយ ត្រូវឯងរំលឹកពីរឿងដើមរបស់ម្តាយ កាលដែលជួបនឹងឪពុកឯងកាលពីដំបូងនោះប្រាប់ឲ្យហូរហែទើបគេស្គាល់» ។ នាងនិយាយរឿងដើមរបស់ខ្លួនប្រាប់កូនសព្វគ្រប់ ហើយកូនក៏លាចេញទៅ ។ បុត្តកុមារស្វែងរកឪពុក អស់ពេលយ៉ាងយូរនៅក្នុងព្រៃ ទើបបានទៅប្រទះឃើញតាបសមួយអង្គគង់ភាវនានៅក្រោមដើមឈើ លើថ្មមួយផ្ទាំងធំ ។ កុមារថ្វាយបង្គំហើយ ក៏រ៉ាយរ៉ាប់រឿងខ្លួនសព្វគ្រប់ឲ្យតាបសស្តាប់ តាបសពុំទាន់ជឿថាកូនទេ ក៏តាំងអធិដ្ឋានថា ប្រសិនកុមារនេះជាកូនខ្ញុំមែន កាលណាខ្ញុំទះកុមារមួយដៃទៅ សុំឲ្យកុមារអណ្តែតមកលើស្មាខ្ញុំ» ។ ថាហើយតាបសយកដៃស្តាំទះទៅ ស្រាប់តែកុមារអណ្តែតមកនៅលើស្មាត្រង់ដូចសេចក្តីប្រាថ្នា ទើបតាបសជឿថា ជាកូនខ្លួនពិតតាំងពីនោះមក តាបសចាប់បង្រៀនវិជ្ជាសិល្បសាស្ត្រដល់កូនជារៀងរាល់ថ្ងៃ ។ លុះប្រមាណជាច្រើនឆ្នាំតមក កូនក៏សុំលាឪពុកទៅរកម្តាយវិញ ឪពុកគ្មានអ្វីជា

ប្រសើរទុកជាកេរ្តិ៍ឡើយ មានតែគ្រាប់ត្រសក់បីគ្រាប់ ហុចទៅឲ្យកូន ហើយផ្តាំថា «គ្រាប់ត្រសក់បីគ្រាប់នេះនឹងផ្តល់កិត្តិយសយ៉ាងធំឲ្យកូនទៅពេលមុខជាប្រាកដ ដល់កូនដាំទៅហើយបានផ្លែជាដំបូង ត្រូវតែបេះផ្លែនោះទៅថ្វាយស្តេចកុំខាន (១) ឯទីកន្លែងដាំ ត្រូវដាំនៅមាត់ត្រពាំងដែលជាលំនៅស្ថានរបស់ម្តាយឯង ហើយត្រូវសន្មតហៅកន្លែងនោះថា «បឹងតី ៗ» តាមឈ្មោះម្តាយឯងរហូតទៅ» ។

កុមារថ្វាយបង្គំឪពុកបីដង ហើយលាធ្វើដំណើរទៅរកម្តាយដែលកាន់តែចាស់ ហើយក៏ប្រាប់ម្តាយឲ្យសន្មតនាមត្រពាំងក្បែរផ្ទះនេះហៅថា បឹងតី ៗ តាមបណ្តាំឪពុក ហើយដែលសព្វថ្ងៃនេះក្លាយទៅជា «បឹងកេ» ទៅវិញ ។ រឿងរ៉ាវដើមនៃបឹងកេ មានប៉ុណ្ណោះឯង គឺកើតមកពីពាក្យតាបសបុសី សន្មតតាមឈ្មោះនាងតី ដែលជាអ្នកស្ថិតនៅត្រង់មាត់ត្រពាំង គឺជាកន្លែងដែលព្រះធរណីស្រុតស្រូបយកពួកសេដ្ឋីទ្រឹស្ដីខុសប្រពៃណី ។ ដូច្នេះហើយ បានជាទម្លាប់ខ្មែរយើងមិននិយមបរិភោគសាច់ក្រពើ ហើយមានជំនឿមួយថា ចង្រៃណាស់ផង ។

---

(១) សូមអានបន្តទៅរឿងតាត្រសក់ផ្អែម ដែលមានក្នុងព្រះរាជពង្សាវតារខ្មែរ ។

## ផ្នែកកំណាត់នៃប្រវត្តិការណ៍

# ប្រវត្តិនៃវត្តប្រាង្គ (ត)

រៀបរៀងដោយ ព្រះពោធិវង្ស ហួត-តាត

អគ្គាធិការនៃពុទ្ធិកសិក្សា

កាលសម្តេចព្រះមហាសង្ឃរាជព្រះនាម នៀង ទ្រង់ផ្តើមចាត់ការជួសជុលព្រះប្រាង្គនោះ នៅរាងដើមនៃរជ្ជកាលព្រះបាទសម្តេចព្រះស៊ីសុវត្ថិ ក្នុងពុទ្ធសករាជ ២៤៤៨ គ.ស. ១៩០៥ បានហើយស្រេចក្នុងពុទ្ធសករាជ ២៤៥១ គ.ស. ១៩០៨ ក្នុងឆ្នាំនោះ សម្តេចព្រះមហាសង្ឃរាជទ្រង់ប្រារព្ធនឹងដង្ហែព្រះបរមសារីរិកធាតុ ពីក្រុងភ្នំពេញ ដោយក្បួននាវាតាមផ្លូវទឹកទៅកាន់វត្តប្រាង្គ ដើម្បីធ្វើបុណ្យសម្ពោធព្រះប្រាង្គ ហើយនឹងតំកល់ព្រះបរមសារីរិកធាតុក្នុងព្រះប្រាង្គ ដែលទើបនឹងជួសជុលរួចថ្មី ៗ នៅក្នុងរដូវចេញវស្សា ព្រោះក្នុងសម័យនោះ ពុំទាន់មានផ្លូវថ្នល់សម្រាប់ទៅមក ទាំងរថយន្តតូច-ធំក៏ពុំទាន់មាន ៗ ទឹកទន្លេក្នុងឆ្នាំនោះ ស្រកយ៉ាងរហ័សតាំងពីក្នុងវស្សា ដល់ពេលចេញវស្សា ទឹកស្រកអស់ជាច្រើន ៗ សម្តេចព្រះមហាសង្ឃរាជទ្រង់បរិវិតក្កថា បើទឹកទន្លេស្រកអស់យ៉ាងនេះ ការដង្ហែព្រះបរមសារីរិកធាតុដោយក្បួននាវា តាមផ្លូវទឹកត្រោះទៅកំពង់ហ្លួង ហើយចូលទៅតាមព្រែកពាមជំនីករហូតទៅដល់ទុង្គនោះ នឹងពុំសម្រេច

ឡើយ ៗ ទើបសម្តេចព្រះមហាសង្ឃរាជទ្រង់អធិដ្ឋានចំពោះព្រះបរមសារីរិកធាតុថា បើព្រះបរមសារីរិកធាតុនេះជារបស់ព្រះសម្មាសម្ពុទ្ធបរមគ្រូពិតមែន សូមឲ្យទឹកទន្លេត្រឡប់ឡើងមកវិញ ដើម្បីនឹងបានរៀបចំធ្វើពិធីដង្ហែព្រះបរមសារីរិកធាតុនេះ តាមផ្លូវទឹកឲ្យបានជាមហោឡារិកអធិកអធម សមតាមព្រះកិត្តិយសរបស់ព្រះអង្គ ៗ

ទឹកទន្លេក៏ត្រឡប់ឡើងម្តងទៀត សមតាមសេចក្តីអធិដ្ឋានរបស់សម្តេចព្រះមហាសង្ឃរាជ ៗ ទឹកទន្លេដែលឡើងនោះ ច្រើនជាងមុន ហូរចូលទៅតាមព្រែកសាយភាយពេញបឹងបួ ទឹកចូលរហូតដល់ស្រះកែវ ជិតផ្សារឧដុង្គ នៅប្រមាណជា ១៥០ ម៉ែត្រ នឹងដល់ទៅវត្តប្រាង្គ ៗ

សម្តេចព្រះមហាសង្ឃរាជ ទ្រង់មានព្រះរាជហឫទ័យសោមនស្សណាស់ ទើបទ្រង់ព្រះរាជបញ្ជាឲ្យចាត់ការរៀបពិធីក្បួនហែព្រះបរមសារីរិកធាតុ ដោយព្រះករុណាជាម្ចាស់ជីវិតទ្រង់សព្វព្រះរាជហឫទ័យឲ្យយកក្បួនហែព្រះរាជទ្រព្យទៅជួយដង្ហែ ឲ្យបានទៅជាពិធីដ៏មហោឡារិកអធិកអធម ហែពីទួលក្រុងភ្នំពេញ ៣ ថ្ងៃ រួចទើបដង្ហែដោយក្បួននាវា តាមផ្លូវទឹកឡើងទៅកំពង់ហ្លួង ៗ កាលដែលដល់ទៅកំពង់ហ្លួង មានការរៀបចំពិធីដង្ហែព្រះបរមសារីរិកធាតុ តាមផ្លូវគោកអស់រយៈ ៦ គីឡូម៉ែត្រ ដោយក្បួនដង្ហែដ៏អធិកអធមក្រៃលែង រហូតដល់ទៅវត្តប្រាង្គ ៗ រីឯនាវាទាំងប៉ុន្មានដែលដង្ហែព្រះបរមសារីរិកធាតុ ពីភ្នំពេញទៅ បានចូលទៅតាម



ព្រះព្រាង្គដ៏ល្អផើតឆាយនេះ មានតំកល់ព្រះបរមសារីរិកធាតុព្រះពុទ្ធជាម្ចាស់ ហើយឋិតនៅឰដ៏ខាងជើង

ព្រះវិហារវត្តប្រាង្គ ( ឧដុង្គ )

ព្រែកពាមជំនីក រហូតដល់ទៅស្រះកែវ ។

សម្តេចព្រះមហាសង្ឃរាជព្រះនាម ទៀង ទ្រង់បានចាត់ឲ្យរៀបចំតំកល់ព្រះបរមសារីរិកធាតុ ក្នុងធម្មសាលាវត្តប្រាង្គ ហើយធ្វើបុណ្យសម្ពោធព្រះប្រាង្គ ៣ ថ្ងៃ ទើបដង្ហែព្រះបរមសារីរិកធាតុ ទៅតំកល់លើព្រះប្រាង្គនៅថ្ងៃព្រហស្បតិ៍ ១២ កើត ខែអស្សុជ ឆ្នាំវកសំរិទ្ធិស័ក ក្នុងពុទ្ធសករាជ ២៤៥១ គ.ស. ១៩០៨ ពេលថ្ងៃរសៀល ក្រោមព្រះរាជាធិបតីភាពនៃព្រះករុណាជាអម្ចាស់ជីវិត ព្រះបាទសម្តេចព្រះស៊ីសុវត្ថិ ។

ក្នុងពិធីបុណ្យនោះ តាមគតិមានក្នុងព្រះរាជពង្សាវតារថា ព្រះករុណាជាអម្ចាស់ជីវិត ទ្រង់ធ្វើព្រះរាជដំណើរពីភ្នំពេញ ទៅតាមព្រះទីនាំងនាវា នៅថ្ងៃពុធ ១១ កើត ខែអស្សុជ ឆ្នាំវកសំរិទ្ធិស័ក នៅវេលាម៉ោង ១៧,៣០ ដល់ម៉ោង ២៤,៣០ ដល់កំពង់ហ្លួងហើយ ទ្រង់ផ្ទំនៅក្នុងព្រះទីនាំងនាវានោះ ។ លុះព្រឹកឡើងថ្ងៃ ១២ កើត ពេលម៉ោង ៦ ព្រឹក ព្រះទីនាំងនាវាចូលតាមព្រែកពាមជំនីក ដល់ទៅស្រះកែវម៉ោង ១០ ព្រឹក ។ ដល់ម៉ោង ១៤ ទ្រង់យាងដោយព្រះបាទចូលទៅវត្តប្រាង្គ គោរពព្រះបរម-សារីរិកធាតុ ហើយទ្រង់ប្រារព្ធដង្ហែព្រះបរមសារីរិកធាតុប្រទក្សិណវិហារវត្តប្រាង្គ ៣ ជុំ ទើបដង្ហែទៅតំកល់លើព្រះប្រាង្គ ក្រោមមុខព្រហ្ម រួចទ្រង់ព្រះរាជនិវត្តន៍មកកាន់ព្រះទីនាំងនាវាវិញ ទ្រង់ផ្ទំនៅស្រះកែវនោះ ១

យប់ទៀត ។ លុះដល់ថ្ងៃ ១៣ កេច ពេលម៉ោង ១០ ទើបទ្រង់ព្រះរាជនិវត្តន៍មកកាន់ព្រះរាជធានីភ្នំពេញ ។

សូមពុទ្ធបរិស័ទទាំងឡាយជ្រាបថា ព្រះប្រាង្គដែលបានតំកល់ព្រះបរមសារីរិកធាតុនៅខាងលើនេះ ជាបូជនីយវត្ថុមួយប្រសើរ សម្រាប់ពុទ្ធសាសនិកជនទាំងបព្វជិត-គ្រហស្ថ គោរពធ្វើសក្ការបូជា ដោយចិត្តជ្រះថ្លា ហើយអាចធ្វើឲ្យកើតផលប្រយោជន៍ ចំពោះពុទ្ធសាសនិកជនទាំងឡាយបាន ។

លុះតមក ដល់ពេលក្រោយអំពីពេលដែលសម្តេចព្រះមហាសង្ឃរាជព្រះនាម ទៀង ទ្រង់ព្រះទិវង្គតទៅ ក្នុងពេលនោះខ្លួនខ្ញុំ (ព្រះពោធិវង្ស ហួត តាត) នៅជាយុវភិក្ខុនៅឡើយ បានដឹងថា រាជការបានជំនុំសម្រេចថា បូជនីយដ្ឋានទាំងប៉ុន្មាន មានព្រះប្រាង្គជាដើមដែលសម្តេចព្រះមហាសង្ឃរាជទ្រង់បានស្ថាបនា ត្រូវទុកជាសម្បត្តិព្រះរាជទ្រព្យទាំងអស់ ។ ហេតុនោះបានជា តមក ដល់ក្នុងរជ្ជកាលព្រះករុណាជាម្ចាស់ជីវិតព្រះបាទសម្តេចព្រះស៊ីសុវត្ថិមុនីវង្ស ព្រះប្រាង្គនេះមានប្រេះបែកធ្លុះធ្លាយដោយហេតុគ្រឿងសម្ភារៈដែលយកមកកសាងក្នុងសម័យនោះ ឥតមានស៊ីម៉ង់ត៍-ដែកសោះឡើយ មានតែកំបោរសនឹងខ្សាច់ប៉ុណ្ណោះៗ គ្រានោះ លោកឡឺរេស៊ីដង់ខេត្រកំពង់ស្ពឺ បានប្តឹងមករាជការក្នុងព្រះបរមរាជវាំង។ បានចាត់ការឲ្យវិស្វករជាតិបារាំងសេសទៅពិនិត្យមើលព្រះប្រាង្គ



ព្រះវិហារវត្តប្រាង្គ (ឧដុង្គ) បញ្ចុះសីមានឹងផ្លូង នៅថ្ងៃទី ១៩ កុម្ភៈ ១៩៦៤

នេះ ហើយបានឲ្យជួសជុល ព្រមទាំងបានទម្លុះព្រះប្រាង្គដាក់បំពង់ទឹក ឲ្យទឹកហូរចុះមក ចូលទៅក្នុងស្រះខាងមុខវិហារ ។

តពីនោះមក ព្រះប្រាង្គនេះ ឥតមានការជួសជុលអ្វីធំដុំទេ មានបន្តិចបន្តួចដោយលោកចៅអធិការវត្តប្រាង្គបានថែទាំឲ្យដំរះកូនឈើតូច ៗ ដែលដុះជ្រៀតជ្រែកតាមចន្លោះកំពោរ ឥដ្ឋ នាំឲ្យបើករបកកំពោរបូកគ្រប់ថ្នាក់ ។ ក្រៅពីនេះ មានឧបាសកម្នាក់ឈ្មោះ ស្រី ជាង់ និងឧបាសិកា ហុ គា នៅផ្សារឧដុង្គ បានលាបទឹកកំពោរម្តង ៗ លុះមកដល់ឆ្នាំខាលចត្វាស័ក ព.ស. ២៥០៥ គ.ស. ១៩៦៣ គហបតី តាង់ ង្លួឈអាង និងអ្នកស្រី ស-គិមសេង ជាភរិយា នៅក្រុងភ្នំពេញ មានសទ្ធាជ្រះថ្លាបានជួសជុលព្រះប្រាង្គ ត្រង់កន្លែងដែលប្រេះបាក់បែកទាំងប៉ុន្មានឲ្យបានល្អឡើងវិញ ទាំងកំពែងក្រៅក៏ឲ្យជួសជុលផងដែរ រួចហើយឲ្យដុសជម្រះស្មៅឲ្យស្អាត ហើយបានឲ្យលាបលនជាថ្មី តាំងពីខាងលើហូតមកខាងក្រោម ហើយបានដាក់ភ្លើងអគ្គិសនីជាពន្លឺបូជា នៅគ្រប់ថ្នាក់រហូតដល់កំពូលខាងលើ ។

---

## វិហារ

វិហារដែលមានរូបភាពភ្ជាប់ក្នុងសៀវភៅនេះជាឧបោសថាគារដែលទើបកសាងរួចថ្មី ៗ នេះ ។ ឯវិហារចាស់បានត្រូវរុះរើចេញ ឥតមានសេសសល់គ្រឿងសម្ភារៈអ្វីបន្តិចបន្តួចសោះឡើយ ព្រោះវិហារចាស់នោះ

មានសភាពទ្រុឌទ្រោមណាស់ ដោយបានកសាងយូរអង្វែងហើយ ។ តាមព្រះរាជពង្សាវតារប្រទេសកម្ពុជាថា ព្រះបាទសម្តេចព្រះហរិរក្សរាមា (ព្រះអង្គឌួង) ទ្រង់មានព្រះបញ្ញាឲ្យកសាងវិហារវត្តពោធិ៍ប្រាង្គក្នុងឆ្នាំរកាឯកស័ក ព.ស. ២៣៩៣ គ.ស. ១៨៤៩ គិតមកដល់ឆ្នាំជូតទោស័ក ព.ស. ២៥០៣ គ.ស. ១៩៦០ នេះ ឃើញ ១១០ ឆ្នាំហើយ ។

វិហារចាស់ដែលព្រះបាទសម្តេចព្រះហរិរក្សរាមាទ្រង់មានព្រះបញ្ញាឲ្យកសាងនោះ មានទំហំទទឹង ១៧ ម៉ែត្រ បណ្តោយ ៣១ ម៉ែត្រ កសាងដោយគ្រឿងឈើ តែជញ្ជាំងធ្វើដោយឥដ្ឋមានកម្រាស់ ១ម.២០ ព្រោះជញ្ជាំងស្រោបសសរឈើធំ ៗ ដំបូលប្រកក្បឿង ។

ក្នុងរយៈកាល ១១០ ឆ្នាំ ដែលបានគណនាពីឆ្នាំកសាងក្នុងគ.ស. ១៨៤៩ ដល់ ១៩៦០ នេះ វិហារនោះត្រូវបានជួសជុលពីរលើកគឺ :

ជួសជុលលើកទី ១ ក្នុងពេលដែលលោកគ្រូព្រះធម្មឃោសាចារ្យ មាស ធ្វើជាចៅអធិការ តែជួសជុលក្នុងពេលនោះគ្រាន់តែផ្លាស់គ្រឿងឈើខាងលើ ។

ជួសជុលលើកទី ២ ក្នុងពេលចុងរជ្ជកាលនៃព្រះករុណាជាម្ចាស់ជីវិត ព្រះបាទសម្តេចព្រះស៊ីសុវត្ថិ ក្រោយពេលដែលព្រះអង្គបានជ្រាបថាវិហារវត្តប្រាង្គទ្រុឌទ្រោមពុកផុយធ្លាយជាច្រើន ព្រះអង្គមានព្រះរាជហឫទ័យនឹកឃើញថា វិហារវត្តប្រាង្គនោះជាព្រះកេរ្តិ៍របស់សម្តេចព្រះហរិរក្សរាមា



សម្ដេចសហជីវិនព្រះប្រមុខរដ្ឋ កំពុងទ្រង់ទទួលអបអរសាទរនឹងកូនចៅប្រុសស្រី ក្មេងចាស់ ដែលចោមរោមថ្វាយបង្គំព្រះអង្គ ក្នុងពិធីសម្ពោធឆ្លងព្រះវិហារវត្តប្រាង្គ (ខត្តុង្គ) នៅថ្ងៃទី ២២-២-៦៤

ជាព្រះរាជបិតារបស់ព្រះអង្គ ព្រមទាំងព្រះអង្គសោត កាលនៅជាព្រះរាជកុមារ ក៏បានចូលកាន់បព្វជ្ជាជាសាមណេរក្នុងវិហារវត្តប្រាង្គនោះដែរ ទើបទ្រង់មានព្រះរាជបញ្ជាឲ្យជាងជួសជុលវិហារនោះ ។ ការជួសជុលក្នុងពេលនោះ បានរើយកសសរឈើចេញទាំងអស់ ហើយចាក់ស៊ីម៉ងត៍ធ្វើជាសសរជំនួសវិញ ។ ឯគ្រឿងឈើ គ្រាន់តែជួសជុលផ្លាស់ឈើដែលពុក ៗ ចេញខ្លះប៉ុណ្ណោះ ជហា ជង្គារ នាគ ដែលពីដើមធ្វើដោយឈើបានរើយកចេញ ហើយធ្វើដោយស៊ីម៉ងត៍ជំនួស ក្រៅពីនោះគ្រឿងចាស់ទាំងប៉ុន្មាន ត្រូវទុកនៅដូចដែល ។ ការជួសជុលនោះ មិនទាន់ទាំងបានរួចស្រេចផង ព្រះអង្គក៏សោយព្រះទិវង្គតទៅ ។

## ការរុះរើវិហារចាស់ និងការកសាងវិហារថ្មី

វិហារចាស់ដែលព្រះបាទសម្តេចព្រះស៊ីសុវត្ថិ ទ្រង់មានព្រះរាជបញ្ជាឲ្យជួសជុលទើបតែទិនបានប្រមាណ ៣០ ឆ្នាំប៉ុណ្ណោះ ក៏បានត្រូវទ្រុឌទ្រោមយ៉ាងខ្លាំង មិនអាចនឹងប្រើប្រាស់តទៅទៀតបាន ព្រោះគ្រឿងឈើកាលដែលជួសជុល គេពុំបានផ្លាស់យកចេញ ក៏ពុកផុយអស់លើងទៅ ឯគ្រឿងទព្វសម្ភារៈដំបូលដែលបានផ្លាស់ប្តូរក្នុងពេលដែលជួសជុលនោះក៏ពុកទៅដែរ ដោយកណ្តៀរឡើងតាមជញ្ជាំងទៅបំផ្លាញខូចខ្ទិអស់ឥតសេសសល់ឡើយ ។

(នៅមានត)

# បុណ្យឆ្លងវត្តប្រាង្គ និងបញ្ចុះសីមា

យើងគួរកត់សំគាល់ថាកិច្ចកសាងវិហារវត្តប្រាង្គ អស់ប្រាក់ចំនួន ២.៥០៧០៥៩ រៀល ។ ឯសម្តេចព្រះមហាក្សត្រិយានី ព្រះអង្គប្រទានប្រាក់ចំនួន ១០.០០០ រៀល ជាព្រះវិភាគទានក្នុងការកសាងព្រះវិហារនេះដែរ ។

លុះចប់ព្រះសុន្ទរកថារបស់ព្រះពោធិវង្សហើយ សម្តេចព្រះបិតាឯករាជ្យជាតិ ទ្រង់ប្រទានព្រះរាជសង្កថាមួយ ប្រកបដោយអត្ថន័យយ៉ាងពិរោះអស្ចារ្យ ដែលយើងចុះផ្សាយដោយសង្ខេប នៅក្នុងទំព័រជាបន្ទាប់ ។

លុះចប់ហើយ សម្តេចព្រះមាតាជាតិនិងសម្តេចព្រះប្រមុខរដ្ឋ ស្តេចយាងទៅកាត់និមិត្តសីមា ហើយព្រះសង្ឃស្វាធ្យាយធម៌មង្គលសូត្រ និងពុទ្ធមន្ត ជាពិធីសម្ពោធឆ្លងវិហារថ្មី ថ្វាយព្រះពរសព្ទសាធុការចំពោះសម្តេចទាំងពីរព្រះអង្គ ។

## ព្រះរាជសង្កថានៃសម្តេចឪក្នុងឱកាសពិធីបញ្ចុះសីមា វត្តប្រាង្គ

ខាងក្រោយការថ្លែងសុន្ទរកថា ព្រះតេជព្រះគុណ ព្រះពោធិវង្ស សម្តេចឪទ្រង់សព្វព្រះរាជហឫទ័យ ថ្លែងព្រះសង្កថាឥតព្រាងទុកយ៉ាងពិរោះក្បោះក្បាយ ។ នៅក្នុងព្រះរាជសុន្ទរថានោះ ព្រះអង្គទ្រង់សរសើរដ៏ស្មោះស្ម័គ្រចំពោះព្រះតេជព្រះគុណព្រះពោធិវង្ស ហួត-តាត ដែលជាមេគំនិតកសាងព្រះវិហារវត្តប្រាង្គនេះ ។ ព្រះអង្គទ្រង់ដៅថាព្រះសង្ឃមិនត្រឹមតែស្វែងរកនូវមោក្ខធម៌ទេ ព្រះអង្គបានរាំងជួយដល់អាណាចក្រ



សម្តេចព្រះបិតាឯករាជ្យជាតិ ព្រះប្រមុខរដ្ឋ ទ្រង់អន្ទូងកំពុងប្រារព្ធកាត់ឬសសីមាកិលក្នុងពិធីបញ្ចុះសីមាវត្តប្រាង្គ ( ឧត្តុង្គ ) ដោយមានសហជីវិន ម៉ែន-ឈុំ អនុរដ្ឋលេខាធិការ ក្រសួងធម្មការ ជាអ្នកកាន់កាំបិត នៅថ្ងៃទី ២២-២-៦៤

ទៀត ដូចជាព្រះពោធិវង្សដែលជួយខ្នះខ្នែងកសាងវត្តប្រាង្គនេះ ដែលជាកិត្តិយសមួយដ៏អស្ចារ្យ នៅក្នុងយុគ្គនេះ ដែលជាអតីតកាលជាទីរុងរឿងមួយជាប់នៅក្នុងប្រវត្តិសាស្ត្រខ្មែរ ៗ សង្គមរាស្ត្រនិយមដែលមានការលូតលាស់រហ័សដូច្នេះ ព្រោះមានព្រះសង្ឃជួយជាវិភាគទាន ក្នុងការកសាងដូចជាសាលា ស្ពានជាដើម ៗ

ខាងនយោបាយវិញ សម្តេចព្រះប្រមុខរដ្ឋ ទ្រង់ប្រទានឲ្យកូនចៅដឹងថា :

- សារពត៌មានក្រុមលោកសេរី បានចាត់ព្រះអង្គទុកជាមនុស្សឆ្កួតជាព្រះអង្គជាអ្នកដឹកនាំប្រជាពលរដ្ឋកូនចៅព្រះអង្គ ឲ្យចូលទៅរករបបកុម្មុយនិស្ត នៅពេលដែលប្រទេសយើងកំពុងតែជួបប្រទះនឹងសន្តិសុខ ក្នុងមាគាអត្យាក្រិត ៗ ថ្ងៃនេះ ដែលយើងកំពុងពិនិត្យនូវវិធានការមួយដើម្បីធ្វើជាបក្សសម្ពន្ធសឹកជាមួយបក្សសង្គមនិយម ក្នុងបំណងនឹងចៀសវាងឲ្យប្រទេសផុតពីការគំរាមកំហែងជាអាយុជីវិតរបស់ខ្មែរយើង ដែលសហរដ្ឋអាមេរិកទាំងបក្សពួករបស់វា កំពុងតែធ្វើសកម្មភាពសព្វថ្ងៃនេះ ៗ ចំណែកសារពត៌មានហ្វីល្វីពីន នឹងម៉ាឡេស៊ីយ៉ា បានចំលាក់កំហុសនេះទាំងស្រុងចោទប្រកាន់ដោយអយុត្តិធម៌ថាព្រះអង្គហ៊ឹកហ៊ឺន ប្រជាពលរដ្ឋទៅរកផ្លូវកុម្មុយនិស្ត នឹងបង្កសង្គ្រាម ដោយវាកាន់លេសត្រង់សេចក្តីសំរេចចិត្ត ដែលព្រះអង្គប្រកាន់យកជាការចំបាច់ ដល់អាយុជីវិតប្រជា

ពលរដ្ឋខ្មែរ ដែលស្ថិតនៅក្នុងបច្ចុប្បន្ននេះ ដើម្បីការពារនិងរក្សាទុកនូវឯករាជ្យ និងអព្យាក្រឹតរបស់ខ្មែរ ដោយហេតុមានការគំរាមកំហែងដ៏អស្ចារ្យក្នុងការប៉ុនប៉ងបំណងកំទេចជីវិតខ្មែរ ដែលមានពួកចក្រពត្តិនិយមបស្ចិម និងពួកបក្សវា ។ មិនតែប៉ុណ្ណោះ វាបានទាំងមួលបង្កាច់ចោទទាំងលើថា ព្រះអង្គជាអ្នកបង្កសង្គ្រាមក្នុងប្រទេសនិងក្នុងអាស៊ីទាំងមូល ។

សម្តេចព្រះបិតាសន្តិភាព ទ្រង់បានគូសបញ្ជាក់ថា សន្និសីទហ្សឺណែវស្តីអំពីស្រុកលាវនោះជាការបង្កសង្គ្រាម ឬ ជាការស្វែងរកសន្តិភាពឲ្យលាវ (នៅក្នុងអាស៊ី) ? ។

ដោយយើងតែងតែទទួលរងគ្រោះជានិច្ច ពីយួនសៀម គ្រប់មធ្យោបាយអមិត្តក្រៅប្រទេស ការចាំបាច់ យើងត្រូវតែសុំមិត្តដែលតែងតែជួយគាំទ្រជួយការពារយើង មានមិត្តចិនប្រជាមានិតជាអាទិ៍នោះ ឲ្យគេជួយការពារ ។

គំនិតរបិលរប៉ូចរបស់អង់គ្លូសាក់·សុង (អង់គ្លេស) បានប្រើនីតិក្រមមួយមកពន្យឺតពន្យារពេល ដោយមិនព្រមទទួលយកការស្នើសុំឲ្យនានាប្រទេសគាំពារអព្យាក្រឹតភាពរបស់យើងតាំងពីឆ្នាំ ១៩៦១ ។ នៅពេលដែលពួកនេះពន្យឺតពន្យារពេល ពួកចក្រពត្តិនិយម បានមកកាប់សម្លាប់ខ្មែរទំលាក់គ្រាប់បែកលើដីខ្មែរលើ គ្មានលោះពេលណាឡើយ ។

នៅទីបំផុត ព្រះអង្គបានប្រទានដំណឹងដល់កូនចៅថា ពួកចាញ់



សម្តេចព្រះមហាក្សត្រិយានីព្រះមាតាជាតិ សម្តេចព្រះឧបយុវរាជ និងព្រះតេជព្រះគុណព្រះពោធិវង្ស ហួត - តាត អគ្គាធិការពុទ្ធិកសិក្សា ទ្រង់កំពុងសន្ទនានៅឯព្រះវិហារ ក្នុងឱកាសពិធីសម្ពោធឆ្លងព្រះវិហារវត្តប្រាង្គ (ឧត្តុង្គ) នៅថ្ងៃទី ២២-២-៦៤

សារីកថានឹងមកធ្វើពិធីចូលឆ្នាំថ្មីនៅភ្នំពេញ ក្នុងឆ្នាំថ្មីខាងមុខនេះ ។ ហើយព្រះអង្គបានបញ្ជាក់ថា កូនចៅត្រេកអររង់ចាំទទួលនៅកន្លែង ដែលការព្រាប-អ៊ុន ជាស្ពានការនយោបាយ ទើបនឹងទទួលរង្វាន់ជីវិតាវសានពីប៉ុន្មានថ្ងៃនោះ ចំណែកកងខេមរភូមិន្ទ ក៏ប្រុងប្រៀបរៀបចំការពារយុទ្ធភណ្ឌទុកជាស្រេច ដើម្បីទទួលជាកិត្តិយសដូចព្រាប-អ៊ុន ទៀត ។ សូមជ្រាបថា គ្រឿងសាស្ត្រាវុធនេះ មិនមែនបានពីនរណាក្រៅពីប្រទេសចិនប្រជាមានិតទេ ។ គ្រឿងអាវុធនេះ បានមកត្រៀមចាំមុនស្រេចដល់ខេមរិនា ជំនួយសឹករបស់បាកាំង និងសូវៀត ដែលឥតមានចំណងនឹងមកដល់ទៀត ដូច្នេះសម្ភារៈទាំងនេះហើយ ដែលកងខេមរភូមិន្ទទុកចាំទទួលថាន់-សារី ក្នុងឱកាសចូលឆ្នាំថ្មីនេះ ទល់គ្នានឹងសម្ភារៈសឹកដែលខ្មែរសេរី បានទទួលពីព្រៃនគរ និងបាងកក ។

នៅចំបញ្ចប់នៃព្រះសង្កថា ព្រះអង្គបានព្រះរាជទាន ចាប់កុសលចំនួន ២០ ០០០ រៀល និងព្រះតេជៈព្រះគុណព្រះពោធិវង្ស ដើម្បីជាភាគទានដល់ការចំណាយចាំបាច់ ក្នុងពិធីបុណ្យបញ្ចុះសីមានេះ ។

# អំពីព្រះនាមព្រះតេជព្រះគុណ

## ដែលបានទទួលសញ្ញាបត្រតាត់តាំងជាចៅអធិការនិងគ្រូសូត្រ

## ក្នុងវត្តនានា (ក្នុងព្រះរាជអាណាចក្រ)

## (ក)

---

៥៨– ព្រះតេជព្រះគុណ ខុន-សាលី នាមឆាយា ចរិបុណ្ណោ កើតឆ្នាំថោះ អាយុ ៤៤ ឆ្នាំ វស្សា ៥ បានទទួលតែងតាំងជាគ្រូសូត្រស្តាំ ក្នុងវត្តអម្ពនទិយារាម ឃុំពាមក្រសោប ស្រុក-ខេត្តកោះកុង លេខ-សញ្ញាបត្រ ៣៤៤២ ចុះថ្ងៃទី ១៥–១ ៦៣ ។

៥៩– ព្រះតេជព្រះគុណ សេង-វៀង នាមឆាយា អមរោ កើតឆ្នាំម្សាញ់ អាយុ ២២ ឆ្នាំ វស្សា ៣ បានទទួលតែងតាំងជាគ្រូសូត្រឆ្វេង ក្នុងវត្តអម្ពនទិយារាម ឃុំពាមក្រសោបស្រុក-ខេត្តកោះកុង លេខសញ្ញាបត្រ ៣៤៤៣ ចុះថ្ងៃទី ១៥–១-៦៣ ។

៦០– ព្រះតេជព្រះគុណ យ៉េ-ចំប៉ា នាមឆាយា សមាចារោ កើតឆ្នាំជូត អាយុ ២៦ ឆ្នាំ វស្សា ៧ បានទទួលតែងតាំងជាគ្រូសូត្រស្តាំក្នុងវត្តអម្ពវ័ន ឃុំពាមក្រសោប ស្រុក-ខេត្តកោះកុង លេខសញ្ញាបត្រ ៣៤៤៤ ចុះថ្ងៃទី ១៥-១-៦៣ ។

៦១– ព្រះតេជព្រះគុណ ឈុំ-ឈឿ នាមឆាយា ធម្មទិន្នោ កើតឆ្នាំមមី អាយុ ២១ ឆ្នាំ វស្សា ២ បានទទួលតែងតាំងជាគ្រូសូត្រឆ្វេង ក្នុង

ទៀត ដូចជាព្រះពោធិវង្សដែលជួយខ្នះខ្នែងកសាងវត្តប្រាង្គនេះ ដែលជាកិត្តិយសមួយដ៏អស្ចារ្យ នៅក្នុងទុង្គនេះ ដែលជាអតីតកាលជាទីរុងរឿងមួយជាប់នៅក្នុងប្រវត្តិសាស្ត្រខ្មែរ ៗ សង្គមរាស្ត្រនិយមដែលមានការលូតលាស់រហ័សដូច្នេះ ព្រោះមានព្រះសង្ឃជួយជាវិភាគទាន ក្នុងការកសាងដូចជាសាលា ស្ពានជាដើម ៗ

ខាងនយោបាយវិញ សម្តេចព្រះប្រមុខរដ្ឋ ទ្រង់ប្រទានឱ្យកូនចៅដឹងថា :

- សារពត៌មានក្រុមលោកសេរី បានចាត់ព្រះអង្គទុកជាមនុស្សឆ្កួត ថាព្រះអង្គជាអ្នកដឹកនាំប្រជាពលរដ្ឋកូនចៅព្រះអង្គ ឲ្យចូលទៅរករបបកុ-ម្មុយនិស្ត នៅពេលដែលប្រទេសយើងកំពុងតែជួបប្រទះនឹងសន្តិសុខ ក្នុងមាគ៌ាអព្យាក្រិត ៗ ថ្ងៃនេះ ដែលយើងកំពុងពិនិត្យនូវវិធានការមួយដើម្បីធ្វើជាបក្សសម្ពន្ធសឹកជាមួយបក្សសង្គមនិយម ក្នុងបំណងនឹងចៀសវាងឲ្យប្រទេសផុតពីការគំរាមកំហែងជាអាយុជីវិតរបស់ខ្មែរយើង ដែលសហរដ្ឋអាមេរិកទាំងបក្សពួករបស់វា កំពុងតែធ្វើសកម្មភាពសព្វថ្ងៃនេះ ៗ ចំណែកសារពត៌មានហ្វីលីពីន នឹងម៉ាឡាស៊ីយ៉ា បានចំលាក់កំហុសនេះទាំងស្រុងតទៅប្រកាន់ដោយអយុត្តិធម៌ថាព្រះអង្គហ៊ឹកហ៊ឺន ប្រជាពលរដ្ឋទៅរកផ្លូវកុម្មុយនិស្ត នឹងបង្កសង្គ្រាម ដោយវាគង់លេសត្រង់សេចក្តីសំរេចចិត្ត ដែលព្រះអង្គប្រកាន់យកជាការចំបាច់ ដល់អាយុជីវិតប្រជា

៦៦- ព្រះតេជព្រះគុណ ខាត់-ម៉ុត នាមឆាយា មន្ទត្ថេរ កើតពី គ.ស. ១៩២០ អាយុ ៤៣ ឆ្នាំ វស្សា ២២ បានទទួលតែងតាំងជាចៅអធិការវត្តអង្គត្រាគៀត ឃុំកន្ទោក ស្រុកកំពេញ ខេត្តកណ្ដាល លេខសញ្ញាបត្រ ៣៤៩០ ចុះថ្ងៃទី ៧-២-៦៣ ។

៦៧- ព្រះតេជព្រះគុណ ហ៊ឹម-ប៉ែន នាមឆាយា ធម្មសុវណ្ណ កើតឆ្នាំម្សាញ់ អាយុ ៤៦ ឆ្នាំ វស្សា ២៦ បានទទួលតែងតាំងជាចៅអធិការក្នុងវត្តសុវណ្ណសនាកម ឃុំពោងមាន់ ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង លេខសញ្ញាបត្រ ៣៤៩១ ចុះថ្ងៃទី ៧-២-៦៣ ។

៦៨- ព្រះតេជព្រះគុណ កួន-ហ៊ីង នាមឆាយា ឥន្ទបញ្ញោ កើតពី គ.ស. ១៩៣០ អាយុ ៣៣ ឆ្នាំ វស្សា ៩ បានទទួលតែងតាំងជាគ្រូសូត្រស្ដាំក្នុងវត្តរុន ឃុំរុនតាឯក ស្រុកសូត្រនិគម ខេត្តសៀមរាប លេខសញ្ញាបត្រ ៣៤៩២ ចុះថ្ងៃទី ៧-២-៦៣ ។

៦៩- ព្រះតេជព្រះគុណ បូរ-ឆន នាមឆាយា សុវណ្ណជោតិ កើតពី គ.ស. ១៩៣៣ អាយុ ៣០ ឆ្នាំ វស្សា ៩ បានទទួលតែងតាំងជាគ្រូសូត្រឆ្វេងក្នុងវត្តរុន ឃុំតាឯក ស្រុកសូត្រនិគម ខេត្តសៀមរាប លេខសញ្ញាបត្រ ៣៤៩៣ ចុះថ្ងៃទី ៧-២-៦៣ ។

៧០- ព្រះតេជព្រះគុណ សឿ-ដុង នាមឆាយា សក្កាសហារ កើតពី គ.ស. ១៩៣៤ អាយុ ២៩ ឆ្នាំ វស្សា ៨ បានទទួលតែងតាំងជាចៅអ-

ធិការកុដិវត្តសាលាម្នាង ឃុំត្រពាំង ស្រុកកំពង់សោម ខេត្តកោះកុង លេខសញ្ញាបត្រ ៣៤៩៤ ចុះថ្ងៃទី ៨-២-៦៣ ។

៧១- ព្រះតេជព្រះគុណ ជា-ប៉ែត នាមឆាយា ឥន្ទត្ថេរ កើតឆ្នាំម្សាញ់ អាយុ ៤៦ ឆ្នាំ វស្សា ២៦ បានទទួលតែងតាំងជាចៅអធិការកុដិវត្តសិរីវ័ន ឃុំព្រៃ ស្រុកសំរោង ខេត្តតាកែវ លេខសញ្ញាបត្រ៣៤៩៥ ចុះថ្ងៃទី ១៩-២ ៦៣ ។

៧២- ព្រះតេជព្រះគុណ សរ-សាមឿន នាមឆាយាមុនីវេក កើតពី គ.ស. ១៩៣៥ អាយុ ២៨ឆ្នាំ វស្សា ៨ បានទទួលតែងតាំងជាគ្រូសូត្រស្តាំកុដិវត្តសិរីវ័ន ឃុំព្រៃ ស្រុកសំរោង ខេត្តតាកែវ លេខសញ្ញា-បត្រ ៣៤៩៦ ចុះថ្ងៃទី ១៩-២-៦៣ ។

៧៣- ព្រះតេជព្រះគុណ ទេព-សុខ នាមឆាយាវជិរប្បញ្ញោ កើតពីគ.ស. ១៩៣៩ អាយុ ២៤ ឆ្នាំ វស្សា ៤ បានទទួលតែងតាំងជាគ្រូសូត្រឆ្វេងកុដិវត្តសិរីវ័ន ឃុំព្រៃ ស្រុកសំរោង ខេត្តតាកែវ លេខសញ្ញាបត្រ ៣៤៩៧ ចុះថ្ងៃទី ១៩-២-៦៣ ។

៧៤- ព្រះតេជព្រះគុណ សួរ-ម៉ុម នាមឆាយាគរុធម្មថេរ កើតឆ្នាំច អាយុ ៧៧ ឆ្នាំ វស្សា ៥៦ បានទទួលតែងតាំងជាចៅអធិការវត្តចំការខ្សាច់ ឃុំស្ពានថ្ម ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល លេខសញ្ញាបត្រ-៣៤៩៨ ចុះថ្ងៃទី ២១-២-៦៣ ។

៧៥– ព្រះតេជព្រះគុណ អ៊ូច-សេន នាមឆាយា សុវណ្ណថេរ កើតឆ្នាំរកា អាយុ ៥៤ ឆ្នាំ វស្សា ១៩ បានទទួលតែងតាំងជាគ្រូសូត្រស្តាំក្នុងវត្តចំការខ្សាច់ ឃុំស្ពានថ្ម ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល លេខសញ្ញាបត្រ ៣៤៥៩ ចុះថ្ងៃទី ២១-២-៦៣ ។

៧៦– ព្រះតេជព្រះគុណ ខឹម-ម៉ាក នាមឆាយា ធម្មថេរ កើតឆ្នាំឆ្លូវ អាយុ ៥០ ឆ្នាំ វស្សា ១ បានទទួលតែងតាំងជាគ្រូសូត្រឆ្វេងក្នុងវត្តចំការខ្សាច់ ឃុំស្ពានថ្ម ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល លេខសញ្ញាបត្រ ៣៤៦០ ចុះថ្ងៃទី ២១-២-៦៣ ។

៧៧– ព្រះតេជព្រះគុណ ទាង-ហុង នាមឆាយា សុវណ្ណត្ថេរ កើតពីគ.ស. ១៩៣០ អាយុ ៣៣ ឆ្នាំ វស្សា ១២ បានទទួលតែងតាំងជាចៅអធិការក្នុងវត្តពោធិព្រឹក្ស ឃុំក្ដឿងរាយ ស្រុកកញ្ជ្រៀច ខេត្តព្រៃវែង លេខសញ្ញាបត្រ ៣៤៦១ ចុះថ្ងៃទី ២៥-២-៦៣ ។

៧៨– ព្រះតេជព្រះគុណ ពុត-វង់ នាមឆាយា មុនីសត្ថេរ កើតពីគ.ស. ១៩៣២ អាយុ ៣១ ឆ្នាំ វស្សា ១០ បានទទួលតែងតាំងជាគ្រូសូត្រស្តាំក្នុងវត្តពោធិព្រឹក្ស ឃុំក្ដឿងរាយ ស្រុកកញ្ជ្រៀច ខេត្តព្រៃវែង លេខសញ្ញាបត្រ ៣៤៦២ ចុះថ្ងៃទី ២៥-២-៦៣ ។

៧៩–ព្រះតេជព្រះគុណ មូល-គិន នាមឆាយា ជោតិបញ្ញោ កើតឆ្នាំមមី អាយុ ៥៧ ឆ្នាំ វស្សា ៣៣ បានទទួលតែងតាំងជាចៅអធិការក្នុងវត្តខទ-

ជោតិវនារាម ឃុំមេសរប្រចាន់ ស្រុកពារាំង ខេត្តព្រៃវែង លេខសញ្ញាបត្រ ៣៤៦៣ ចុះថ្ងៃទី ២៥-២-៦៣ ។

៨០– ព្រះតេជព្រះគុណ ទិន-ហ៊ិន នាមឆាយា ចន្ទបញ្ញោ កើតឆ្នាំខាល អាយុ ៣៧ ឆ្នាំ វស្សា ១៣ បានទទួលតែងតាំងជាគ្រូសូត្រស្តាំ ក្នុងវត្តនទិជោតិវនារាម ឃុំមេសរប្រចាន់ ស្រុកពារាំង ខេត្តព្រៃវែង លេខសញ្ញាបត្រ ៣៤៦៤ ចុះថ្ងៃទី ២៥-២-៦៣ ។

៨១– ព្រះតេជព្រះគុណ គិន-ឌិន នាមឆាយា ធម្មសេរី កើតពី គ.ស. ១៩២៣ អាយុ ៤០ ឆ្នាំ វស្សា ៥ បានទទួលតែងតាំងជាគ្រូសូត្រឆ្វេង ក្នុងវត្តនទិជោតិវនារាម ឃុំមេសរប្រចាន់ ស្រុកពារាំង ខេត្តព្រៃវែង លេខសញ្ញាបត្រ ៣៤៦៥ ចុះថ្ងៃទី ២៥-២-៦៣ ។

៨២– ព្រះតេជព្រះគុណ អ៊ុន-កុន នាមឆាយា ធម្មបញ្ញោ កើតពី គ.ស ១៩០៣ អាយុ ៦៣ ឆ្នាំ វស្សា ១០ បានទទួលតែងតាំងជាចៅអធិការក្នុងវត្តទួលគគីរ ឃុំព្រែកអញ្ចាញ ស្រុកមុខកំពូល ខេត្តកណ្ដាល លេខសញ្ញាបត្រ ៣៤៦៦ ចុះថ្ងៃទី ១០-៣-៦៣ ។

# សេចក្ដីផ្សេង ៗ

កម្ពុជសុរិយា សូមអភ័យទោស អំពីសំណាក់នៃមិត្រអ្នកអានទាំងឡាយដែលមានអាសយដ្ឋាន នៅខេត្រនា ៗ ក្នុងព្រះរាជអាណាចក្រឆ្ងាយពីទីក្រុងភ្នំពេញ ហើយដែលបានមានសោមនស្សចេតនា ចង់ដោះស្រាយចំណោទគំនិតនៃខ្លួន រួចចម្លើយពុំបានមកដល់ទីសំណាក់ការទាន់កាលវេលា ព្រោះទស្សនាវដ្ដីក្រទៅដល់ ៗ ឯការក្រទៅដល់នេះ មិនមែនជាកំហុសនៃពុទ្ធសាសនបណ្ឌិត្យក្របញ្ជូនទៅនោះទេ គឺជាកំហុសនៃការធ្វើដំណើរយឺតយូរនៃទស្សនាវដ្ដីមួយ ៗ ជាពិតប្រាកដ ។

ចំពោះចំណោទទី ១ កម្ពុជសុរិយាទើបនឹងបានទទួលចម្លើយជាច្រើនទៀតក្នុងពេលថ្មី ៗ នេះ តែធ្វើដូចម្ដេច បើចម្លើយចំណោទទី ១ ចេញផ្សាយហួសទៅហើយ សូមមិត្រដែលទើបនឹងផ្ញើចម្លើយទៅនោះ មេត្តាអភ័យទោស ដោយពុំបានចុះនាមមិត្រផ្សាយក្នុងទស្សនាវដ្ដី ។

## ចម្លើយចំណោទគំនិតទី ២

(អានសេចក្ដីចោទក្នុងទស្សនាវដ្ដីលេខ ២ ទំព័រ ១៧០ ឆ្នាំ ១៩៦៤)

### ទី ១ ចម្លើយរបស់លោក គិម-យឹន-ស៊ុសាមុត

ចាងហ្វាងទូទៅសាលាឯកជន នៅទីស្ដីការក្រសួងអប់រំជាតិ

ឆ្នោត ): មនុស្សក្នុងលោកនិយមស្រឡាញ់ចូលចិត្តគ្រប់គ្នា
ឆោត ): បើកាត់ជើងចោល ត្រូវក្លាយជាកម្មវត្ថុសម្រាប់តែគេចំអកសើចលេង ។

ទី ២ បម្លើយរបស់លោក គុយ-សូត្រ
ភ្នាក់ងារនៅពុទ្ធសាសនបណ្ឌិត្យ

របស់សម័យ ដែលមនុស្សសព្វថ្ងៃ ចូលចិត្តផ្សងព្រេង គឺឆ្នោត ជាតិពិត បើគិតឲ្យវែង កាត់ជើងចេញចេង គេថា « ឆោតវិញ »។

ទី ៣ បម្លើយរបស់លោក លី-ប៊ុនប៉ា
ក្រសួងអប់រំជាតិ ភ្នំពេញ

គ្មានអ្នកសំគីរ ជួយផ្តល់គំនិត ឆ្លើយតាមប្រធាន ថាមានតែ «ផ្ទិត» កាត់ជើងប្រែ «ផិត» ត្រឡប់អប្រិយ៍ ។ ផ្ទិតឲ្យត្រជាក់ គេចូលចិត្តស្ម័គ្ររាប់រកមេត្រី បើកាត់ជើង «ល» ក្លាយជាសំដី ឡកឡឺយប្រក្រតី ជិតដល់អាត្មា ។

ទី ៤ បម្លើយរបស់លោក សំ-ជ័យ
នៅសាលាដំបូង ព្រៃវែង-ក្រុង

ខ្ញុំជាខោ ដែលជាសម្លៀក សម្រាប់មហាជន ក្នុងលោកស្លៀក មហាជននិយមរាប់អានស្រឡាញ់គ្រប់គ្នា តែបើ «ខោ» នេះ គេកាត់ជើងចោលចេញទៅវិញ មហាជនក្នុងលោក តែងតែចំអកសើចលេង

ទៅវិញជាប្រាកដ ព្រោះរបស់ដែលគេកាត់ជើងហោល ឲ្យនៅជាកំបុត ដូច្នោះ មនុស្សក្នុងលោកពុំអាចនិយមចូលចិត្តឡើយ ហើយតែងចំអកសើចលេងទៅវិញ ដោយចំអកថា «ខោ» កំបុតជើងៗ បើសិនណាជាមាននរណាស្លៀកខោកំបុតជើងនោះ អ្នកនោះនឹងត្រូវគេសើចចំអក ឥតនៅស្ងៀមបានសោះឡើយ ។

## សេចក្តីកោតសរសើរ

ចំពោះចម្លើយទាំង ៤ ខាងលើ កម្ពុជសុរិយា សូមថ្លែងអំណរគុណនឹងកោតសរសើរយ៉ាងស្មោះស្ម័គ្រដល់លោក គឹម-យើន-សុសាមុត និងលោក គុយ-សូត្រ ដែលមានប្រាជ្ញាវាងវៃអាចដោះស្រាយចំណោទគំនិតយើង យ៉ាងត្រឹមត្រូវឥតល្អៀង ។ កម្ពុជសុរិយា ក៏សូមថ្លែងអំណរគុណដែរដល់លោក លី.ប៊ុនចា នឹងលោក សំ-ជ័យ ទោះបីចម្លើយរបស់លោក មិនសូវត្រូវមែនទែនក៏ដោយ តែយើងសង្ឃឹមថាក្នុងចំណោទទី ៣ លោកប្រហែលជានឹងរកឃើញហើយត្រឹមត្រូវជាមិនខាន ។

## សេចក្តីបញ្ជាក់

ចាប់ពីពេលនេះទៅ កម្ពុជសុរិយា នឹងបង្អង់ពេលទុកឲ្យបានយូរបន្តិចមុននឹងយកចម្លើយរបស់អស់លោកមកចុះផ្សាយ ព្រោះទុកពេលឲ្យមិត្តអ្នកអាននៅឆ្ងាយ ៗ ដែលក្របានទទួលនូវទស្សនាវដ្តី បានឆ្លើយផង ។

ពុទ្ធសាសនបណ្ឌិត្យ